ទស្សនាវដ្ដីមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ជុំ ម៉ាញ អ្នកទោសគុកទួលស្លែង ដែលនៅមានជីវិត
- អង្គការតើជាឃាតករគេឬ

[illegible]

លេខ១០ ខែតុលា ឆ្នាំ២០០០

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២២ ខែតុលា ឆ្នាំ២០០១


## មាតិកា


◆ សំបុត្រៈ អង្គការគឺជាឃាតករឥតរូប ....................................១

**ផ្នែកឯកសារ**

◆ អៀង សារី ឆ្នាំ១៩៧៨ ................................................៣

◆ ប៉េកាំង ឆ្នាំ១៩៧៩ .....................................................៤

◆ ផែនការកម្មុច ឌុច នៅមន្ទីរស-២១ ....................................៥

◆ ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍ ..........................៨

◆ កាលប្បវត្តិរបស់ហាណូយ ...........................................១០

◆ សេចក្ដីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា ...........១៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ជុំ ម៉ាញ ៈអ្នកទោសគុកទួលស្លែងដែលនៅមានជីវិត .............១៦

◆ មន្ទីរ ម-១៣ របស់ឌុច ...............................................២១

◆ សម្ភេទពីមន្ទីរ ស-២១ ..................................................២៥

◆ វៀតណាមបរិយាយ ៈ ឈើយឺសឹកកម្ពុជា............................៣០

**ផ្នែកច្បាប់**

◆ ជូនចំពោះ ខៀវ សំផន ..................................................៣៤

◆ តម្លៃនៃភ័ស្ដុតាង ..........................................................៣៦

◆តុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ .................................៤១

◆តើមេដឹកនាំខ្មែរក្រហមគួរតែត្រូវជំនុំជម្រះទោស ..................៤៦

**វេទិកាពិភាក្សាសាធារណៈ**

◆ ការពិភាក្សាគ្នារវាងរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ.........៥១

◆ចិនបរិយាយៈហេតុអ្វីបានជាអាជ្ញាធរវៀតណាមបង្កជម្លោះ ......៥៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ស្វែងរកឪពុក ...............................................................៥៩

◆តាមរកបងប្រុសដែលបាត់ខ្លួន .........................................៦០

**សិល្បៈខ្មែរក្រហមៈ**

◆រូបថត អៀម ចាន់......................................................ក្របក្រោយ




ហ៊ឹម ហ៊ុយ (១៩៧៩)


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**វាគ្មិនលេខនេះ:** ដេវ ពន្សរ៉ាស៊ី, ឡុង ដានី, វ៉ាន់ថាន់ ពៅដារ៉ា, គិញ ខា, សេង ធារី, ចន ឆរធីអារី, វីលៀម ស្កាបាស់, ថូម៉ាស់ ហាម៉ាប៊ឺក, ដេវីដ ឆេនដល័រ, លី ឡា, នេរ **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុខឃីម **និពន្ធនាយករងទី១ៈ** ផាត កុសល **និពន្ធនាយករងទី២ៈ** សឹម សុរិយ៉ា **អ្នកបកប្រែៈ** សួ ប៊ុនស៊ូ **និពន្ធនាយកទូទៅៈ** ឆាំង យុ, **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ទ្រី សុភក្តិ

*សំបុត្រៈ*

# អន្ធការគឺជាឃាតករឥតរូប

*សមមិត្តរបស់តាលីបង់ (Taliban) ឈ្មោះ អូស្មា ប៊ីន ឡាដិន (Osama bin Laden) និងកូនចៅរបស់ខ្លួនបានបង្កឲ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់សហរដ្ឋអាមេរិក ដោយប្រើយុទ្ធសាស្ត្រភេរវកម្មដ៏ទំនើបនិងប៉ិនប្រសប់ ប៉ុន្តែសហរដ្ឋអាមេរិកនឹងកសាងសំណង់អគារបាក់បែកទាំងនោះសាជាថ្មី ហើយនិងមានភាពរឹងមាំព្រមទាំងធានាសន្តិសុខបានល្អប្រសើរជាងមុន ។ ថ្ងៃវិនាសកម្មបង្កឡើងដោយតាលីបង់និងសមមិត្តរបស់ខ្លួន ឥឡូវនេះត្រូវបានរាប់ចំនួនឃើញហើយ ចំណែកឯការវាយប្រហាររបស់ក្រុមភេរវករនេះ ក៏គ្មានប៉ះពាល់ដល់មូលដ្ឋានគ្រឹះរបស់ជាតិនិងប្រជាជនអាមេរិកាំងដែរ ។*

*ផ្ទុយមកវិញ ប៉ុល ពត មិនបានប្រើបច្ចេកវិទ្យាទំនើបដូច ប៊ីនឡាដិន ទេ ប៉ុន្តែ ប៉ុល ពត និងមេដឹកនាំរបស់ខ្មែរក្រហមដទៃទៀតអាចសម្លាប់មនុស្សបានរហូតដល់ទៅរាប់លាននាក់ ហើយបានធ្វើឲ្យប្រទេសកម្ពុជាខ្ទេចខ្ទាំធ្លាក់ដល់ក្រោមសូន្យ ។ អាវុធដ៏គ្រោះថ្នាក់របស់ខ្មែរក្រហមគឺនយោបាយនិងគោលការណ៍របស់«អន្ធការ» ។ មរតកឆ្កួតព្រៃផ្សៃទាំងនេះមានរហូតមកដល់សព្វថ្ងៃ ហើយមិនមែនមានតែនៅក្នុងពេលវេលាដែលកម្ពុជាមិនទាន់មានការអភិវឌ្ឍផ្នែកនយោបាយនិងសេដ្ឋកិច្ចនោះទេ ប៉ុន្តែវាបានជិតដាមនៅក្នុងសង្គមជាតិ ។ អន្ធការខ្មែរក្រហមបានបំផ្លាញមូលដ្ឋានសង្គមខ្មែរនិងគ្រួសារខ្មែរទាំងស្រុង ។ អន្ធការគឺជាឃាតករឥតរូប ។*



*នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៨ លោក ប៊ៀលគ្លីនតុន ប្រធានធិបតីសហរដ្ឋអាមេរិកបានចុះហត្ថលេខាលើ«ច្បាប់យុត្តិធម៌នៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា»ដែលចែងថា«នេះគឺជានយោបាយរបស់សហរដ្ឋអាមេរិកក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការនាំយកក្រុមខ្មែរក្រហមមកកាន់តុលាការដើម្បីកាត់ទោសពីបទប្រឆាំងនឹងមនុស្សជាតិដែលខ្លួនបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជានៅចន្លោះថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ដល់ថ្ងៃ៧មករា ឆ្នាំ១៩៧៩» ។*

*នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាព្រះបាទសម្តេចនរោត្តម សីហនុ ទ្រង់បានឡាយព្រះហស្តលេខាលើច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅក្នុងមាត្រាទី១ចែងថា «ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា រំលោភទៅលើច្បាប់និងទម្លាប់អន្តរជាតិ ហើយនិងរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩» ។*

ទំរាំតែមានការអនុម័តច្បាប់ឲ្យមានការរៀបចំតុលាការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម គឺប្រើរយៈពេលរហូតដល់ទៅ៧ឆ្នាំពោលគឺ៤ឆ្នាំលើពីរយៈពេលដែលខ្មែរក្រហមបានសម្លាប់និងបង្អត់អាហារប្រជាជនកម្ពុជាអស់រាប់លាននាក់ ។ នៅក្នុងរយៈពេល៧ឆ្នាំនេះ អ្នកស្រាវជ្រាវជាន់ខ្ពស់ អ្នកច្បាប់ និងមជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាក្រុមស្រាវជ្រាវនាំមុខក្នុងការចងក្រងឯកសារដែលទាក់ទងនឹងឧក្រិដ្ឋកម្មដ៏ច្រើនអនេកនិងអំពើឃោរឃៅដែលប្រព្រឹត្តឡើងក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។ គោលបំណងដ៏ចម្បងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺដើម្បីការចងចាំនិងយុត្តិធម៌ ។ គោលបំណងទាំងពីរនេះគឺជាមូលដ្ឋានគ្រឹះសម្រាប់បង្កើតវិធាននៃច្បាប់និងការបង្រួបបង្រួមជាតិពិតប្រាកដនៅកម្ពុជា ។ មកទល់សព្វថ្ងៃនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងទុកជាឯកសារនូវរណ្តៅសាកសពចំនួន ១៩ ៤៤០រណ្តៅ គុកចំនួន១៦៧កន្លែងនិងបូជនីយ៍ដ្ឋានតម្កល់អដ្ឋិធាតុចំនួន៧៧ កន្លែងព្រមទាំងប្រមែប្រមូលឯកសារខ្មែរក្រហមបានជាង៦សែនសន្លឹកនិងវត្ថុតាងប្រវត្តិសាស្ត្រជាច្រើនទៀតដែលនៅសេសសល់ពីរបបខ្មែរក្រហម ។

នៅឡើយនោះ គឺអស់រយៈពេល២២ឆ្នាំ ក្រោយពីការដួលរលំនៃរបបខ្មែរក្រហម ដែលជនរងគ្រោះនៅតែបន្តរង់ចាំយុត្តិធម៌និងការពិត ។ ចំណែកឯមេដឹកនាំនៃរបបខ្មែរក្រហមវិញបេះតែបន្តរស់នៅពោរពេញដោយសេរីភាពនៅចំពោះជនរងគ្រោះរបស់ខ្លួន ។ នៅពេលដែលដំណើរតុលាការកាត់ទោសខ្មែរក្រហមកំពុងឈានមកដល់គោលដៅរបស់ខ្លួនក្នុងការផ្តល់យុត្តិធម៌សម្រាប់ជនរងគ្រោះក្នុងកម្រិតណាមួយនោះ គឺជាការសំខាន់ណាស់ក្នុងការធ្វើឲ្យកិច្ចខិតខំប្រឹងប្រែងក្នុងដំណើរការជំនុំជម្រះក្តីនេះទៅមុខប្រកបដោយផ្លែផ្កា ។

**ឆាំង យុ**



# អៀង សារី ឆ្នាំ១៩៧៨

អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបានអញ្ជើញមកប្រទេសកម្ពុជាដើម្បីពិនិត្យទៅលើការគោរពសិទ្ធិមនុស្ស ។

ឧបនាយករដ្ឋមន្ត្រី (ខ្មែរក្រហម) អៀង សារី បាននិយាយកាលពីថ្ងៃសុក្រនេះថា ខ្លួនទើបតែបានអញ្ជើញលោកអគ្គលេខាអង្គការសហប្រជាជាតិ គួត វ៉ាល់ដែម មកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ហើយ «ឲ្យលោកអគ្គលេខាអង្គការសហប្រជាជាតិមើលដោយផ្ទាល់ភ្នែកនូវភាពពិតជាក់ស្តែងនៃការចោទប្រកាន់អំពីការរំលោភសិទ្ធិមនុស្ស»មកលើរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

អ្នកនាំពាក្យអង្គការសហប្រជាជាតិម្នាក់បានពោលថា លោកអគ្គលេខាអង្គការកំពុងតែពិចារណាលើការអញ្ជើញនេះ ។

កាលពីខែមុន សេចក្តីថ្លែងការណ៍មួយរបស់ប្រទេសកាណាដាដែលត្រូវបានផ្ញើទៅឲ្យគណៈកម្មាធិការអង្គការសហប្រជាជាតិទទួលបន្ទុកផ្នែកសិទ្ធិមនុស្ស បានចោទប្រកាន់រដ្ឋាភិបាលប្រទេសកម្ពុជា (កម្ពុជាប្រជាធិបតេយ្យ) ពីបទ «រំលោភស្ទើរតែលើគ្រប់មាត្រាទាំងអស់នៃការប្រកាសជាសកលអំពីសិទ្ធិមនុស្ស» ។ សេចក្តីប្រកាសនេះគឺជាឯកសារដ៏សំខាន់របស់អង្គការសហប្រជាជាតិដែលបានអនុម័តក្នុងឆ្នាំ១៩៤៨ ។

នៅថ្ងៃព្រហស្បតិ៍ សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក ៨០រូប បានសំណូមពរឲ្យមានវិធានការជាលក្ខណៈអន្តរជាតិមួយដើម្បីបញ្ឈប់នូវអ្វីដែលហៅថាជាអំពើប្រល័យពូជសាសន៍នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យមកលើប្រជាជនរបស់ខ្លួន ។ សមាជិកព្រឹទ្ធសភាទាំង៨០រូប ដែលមាន៤៨រូបមកពីគណបក្សប្រជាធិបតេយ្យ និង៣២រូបមកពីគណបក្សសាធារណរដ្ឋបានចុះហត្ថលេខាលើលិខិតមួយច្បាប់ ដែលជាការផ្តើមគំនិតរបស់សមាជិកព្រឹទ្ធសភា ចច មែកហ្គោវិន ។ លិខិតនេះបានសំណូមពរឲ្យសហរដ្ឋអាមេរិកដាក់បញ្ហាកម្ពុជាទៅក្នុងរបៀបវារៈដែលត្រូវពិភាក្សារបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ។

ក្នុងពេលធ្វើទស្សនកិច្ចជាលើកទី៣ទៅកាន់អង្គការសហប្រជាជាតិក្នុងឋានៈជាមេដឹកនាំម្នាក់ទទួលបន្ទុកផ្នែកទំនាក់ទំនងការបរទេស អៀង សារី បានថ្លែងក្នុងសន្និសីទកាសែតមួយថា «តាមពិតនៅឆ្នាំ១៩៧៥ និង ១៩៧៦ រដ្ឋាភិបាលយើងជួបប្រទះនឹងការលំបាកយ៉ាងខ្លាំង» ។

អៀង សារី និយាយសំដៅទៅលើការជម្លៀសប្រជាជនចេញពីក្រុងដោយបន្ទាន់បន្ទាប់ពីពួកកុម្មុយនិស្តវាយយកកម្ពុជាបានភ្លាម ហើយនិយាយទៀតថា ការធ្វើដោយប្រញាប់បែបនេះបណ្តាលឲ្យមាន «បញ្ហាមួយចំនួន» ។

ប៉ុន្តែ អៀង សារី បានពន្យល់បន្ថែមថា «ប្រសិនបើកម្ពុជាប្រជាធិបតេយ្យមិនបានជម្លៀសប្រជាជនចេញពីទីក្រុងទេនោះ មនុស្សជាច្រើនច្បាស់ជានឹងត្រូវស្លាប់រហូតទល់ពេលបច្ចុប្បន្ននេះហើយ» ។ អៀង សារី មិនបានពន្យល់បន្ថែមលើចំណុចនេះទេ ។

អៀង សារី បន្តទៀតថាបន្ទាប់ពីមានបញ្ហាខ្លះក្នុងពេលចាប់ផ្តើមដំបូង «ឥឡូវអ្នកជម្លៀសពីទីក្រុងយល់ឃើញថាប្រជាជនអាចរស់នៅតាមជនបទបានងាយស្រួលជាងពីមុន ។»

ឆ្លើយតបនឹងសំណួរជាច្រើន អៀង សារី បានប្រាប់អ្នកយកសារព័ត៌មានថា ក្នុងពេលនេះអតីតមេដឹកនាំប្រទេសសម្តេចនរោត្តម សីហនុ កំពុងតែគង់ប្រថាប់យ៉ាងស្រួលក្នុងព្រះរាជដំណាក់របស់ព្រះអង្គ ហើយអ្នកសារព័ត៌មានលោកខាងលិចអាចចូលទស្សនាកម្ពុជាបាន ។ កម្ពុជាស្វាគមន៍ជានិច្ចចំពោះទំនាក់ទំនងការទូតជាមួយសហរដ្ឋអាមេរិក ។

អៀង សារី បានពន្យល់ថា សង្គ្រាមបានធ្វើឲ្យកម្ពុជាទទួលរងនូវការខូចខាតយ៉ាងដំណំដែលបណ្តាលឲ្យកម្ពុជាគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីរៀបចំទទួលក្រុមអ្នកសារព័ត៌មានបរទេស ។ ដូច្នេះចំនួនអ្នកដែលត្រូវមកធ្វើទស្សនកិច្ចនៅកម្ពុជាគឺនៅតែមានកំណត់ដដែល ។ ប៉ុន្តែ អៀង សារី បន្ថែមថា «កម្ពុជាគ្មានអ្វីត្រូវលាក់ទេ» ហើយថ្មីៗនេះអ្នកសារព័ត៌មានជប៉ុនទើប

តែបានបញ្ចប់ដំណើរទស្សនកិច្ចនៅកម្ពុជា ។

អៀង សារី បញ្ជាក់ថា សំណូមពរទាំងឡាយទៅលើការសុំមកធ្វើទស្សនកិច្ច ក៏កំពុងតែត្រូវបានរៀបចំយ៉ាងប្រញាប់ប្រញាល់ទៅតាមលទ្ធភាពដែលអាចធ្វើបាន ហើយ"ប្រហែលជាវេនរបស់សហរដ្ឋអាមេរិកនឹងមកដល់នៅខែវិច្ឆិកាឬខែធ្នូខាងមុខ ។ កម្ពុជាកំពុងតែបើកទ្វាររបស់ខ្លួនបន្តិចម្តងៗហើយ ហើយយើងនឹងអញ្ជើញអស់លោកទាំងអស់ឲ្យទៅទស្សនាកម្ពុជាជាមិនខាន" ។

**(សារពត៌មាន ឡូអេជីលេសថែម៍ ថ្ងៃសៅទី១០ តុលា ១៩៧៨)**

# ប៉េកាំង ឆ្នាំ១៩៧៩

សហភាពសូវៀតបានអនុញ្ញាតឲ្យប្រទេសវៀតណាមចូលជាសមាជិក"ក្រុមប្រឹក្សាជំនួយសេដ្ឋកិច្ចនៅថ្ងៃទី២៩ ខែមិថុនាកាលពីឆ្នាំមុន ដើម្បីផ្តល់ការគាំទ្រដល់រដ្ឋាភិបាលក្រុងហាណូយទាំងផ្នែកសេដ្ឋកិច្ចនិងនយោបាយ ។ សូវៀតបានបញ្ជាក់ថាយកប្រទេសវៀមណាមជា"ប៉ុស្តិ៍ជួរមុខពិនិត្យលទ្ធិសង្គមនិយមមួយដ៏គួរឲ្យទុកចិត្តបាន"របស់ខ្លួនប្រចាំតំបន់អាស៊ី-អគ្នេយ៍ ។

នៅពាក់កណ្តាលខែសីហា រដ្ឋាភិបាលក្រុងមូស្គូបានដឹកជញ្ជូនអាវុធយ៉ាងសន្ធឹកសន្ធាប់រួមបញ្ចូលទាំងរ៉ុក្កែតផងទៅកាន់ប្រទេសវៀតណាម ។ ទីប្រឹក្សានិងបុគ្គលិកទាំងក្រុមៗត្រូវបានបញ្ជូនទៅកាន់វៀតណាមយ៉ាងហោចណាស់ក៏៤០០០នាក់ដែរ ។ ក្នុងពេលជាមួយគ្នានេះដែរ សហភាពសូវៀតបានផ្តើមប្រើប្រាស់មូលដ្ឋានទ័ពកាំរាញ់ ។

នៅដើមខែវិច្ឆិកា ឆ្នាំមុន ឡេយន់, ផាមវ៉ាន់ដុង និងមេដឹកនាំម្នាក់សំខាន់វៀតណាមជាច្រើននាក់ទៀតបានធ្វើទស្សនកិច្ចនៅទីក្រុងមូស្គូជាកន្លែងដែលមេក្រុមទាំងនេះ ឯកភាពជាមួយសហភាពសូវៀតលើ"សន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការ" ដែលរួមបញ្ចូលទាំងសម្ព័ន្ធភាពផ្នែកយោធា ហើយបានប្រកាសជាសាធារណៈថា "សហប្រតិបត្តិការយោធា" ត្រូវបានបង្កើតឡើងរវាងប្រទេសទាំងពីរ ។ សូវៀតបានផ្តល់ជំនួយដល់ប្រទេសវៀតណាមនូវយន្តហោះចម្បាំងធុនមីក-២៣ជាច្រើនគ្រឿង និងនាវាចម្បាំងទម្ងន់២០០០តោនចំនួនពីរគ្រឿងទៀត ។

នៅក្នុងកិច្ចប្រជុំកំពូលនៅទីក្រុងមូស្គូ ចុងខែវិច្ឆិកា ចូលរួមដោយក្រុមប្រទេសដែលស្ថិតនៅក្រោមកតិកាសញ្ញា ក្រុងវ៉ារស៊ូវី សហភាពសូវៀតបានជំរុញឲ្យប្រទេសទាំងនោះបង្កើនការចំណាយលើផ្នែកយោធា ហើយសហភាពសូវៀតអំពាវនាវឲ្យមានកិច្ចគាំទ្ររួមគ្នា ជួយដល់ការឈ្លានពានរបស់ប្រទេសវៀតណាម ។ នេះគឺជាកិច្ចខិតខំប្រឹងប្រែងមួយដើម្បីបង្កើនភាពប្តូរផ្តាច់នៃប្លុកយោធារបស់សូវៀតពីអឺរ៉ុបខាងកើតទៅតំបន់ចិន ។

នៅថ្ងៃទី៣ ខែធ្នូ អាជ្ញាធរវៀតណាមបានបង្កើតអង្គការអាយ៉ង"រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា" ធ្វើជាអង្គការមួយសម្រាប់រៀបចំការឈ្លានពានទ្រង់ទ្រាយដ៏ធំមួយរបស់ខ្លួន ។ ក្រោយពីមានការបង្កើតរណសិរ្សរួចភ្លាម ប្រភពពត៌មាន *TASS* ផ្សព្វផ្សាយនូវការបង្កើតនេះ ហើយប្រព័ន្ធសារពត៌មានធំៗរបស់សូវៀតបានស្រែកក្តែងៗថា "កងទ័ពដ៏ពិតប្រាកដនិងពោរពេញទៅដោយភាពស្នេហាជាតិកំពុងតែរីកចំរើនឡើងក្រោមការតស៊ូយ៉ាងម៉ឺងម៉ាត់ ដើម្បីសង្គ្រោះជាតិរបស់ខ្លួន" ក្នុងប្រទេសកម្ពុជា ហើយថាកងទ័ពនឹងក្លាយជា"វិភាគទានសំខាន់បំផុត"សម្រាប់ការផ្តួលរំលំរបបដែលកំពុងតែដឹកនាំប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ។

នៅថ្ងៃទី២៥ ខែធ្នូ ទ័ពឈ្លានពានវៀតណាមបានចាប់ផ្តើមបើកការវាយលុកជាទ្រង់ទ្រាយធំចេញពីទិសជាច្រើនមកលើទឹកដីនៃប្រទេសកម្ពុជា ។ នៅថ្ងៃទី៧ ខែមករា កងទ័ពឈ្លានពានវៀតណាមបានកាន់កាប់ទីក្រុងភ្នំពេញទាំងមូល ។ កម្ពុជាប្រជាធិបតេយ្យ ក៏ចាប់ផ្តើមធ្វើសង្គ្រាមប្រជាជនទូទាំងប្រទេសវិញ ហើយការប្រយុទ្ធប្រឆាំងនឹងអនុត្តរភាពនិយមរបស់វៀតណាមនិងសូវៀតបានឈានចូលក្នុងឆាកថ្មីមួយទៀត ។

**(កាសែតប៉េកាំងរីវីយូ ថ្ងៃទី១៩ មករា ១៩៧៩)**

# ផែនការកម្ទេចខ្មោចនៅមន្ទីរស-២១

ឈូ ប៊ុនលាត ឈ្មោះបដិវត្ត ហៅ លាត អាយុ ៣៧ឆ្នាំ ជាជនជាតិខ្មែរ ភេទប្រុស មានទីលំនៅនៅភូមិព្រែកតាវ៉ា ឃុំទឹកវិល ស្រុក២០ តំបន់២៥ ខេត្តកណ្តាល ។ ឪពុកឈ្មោះ ឈូ ហ៊ី និងម្តាយឈ្មោះ សាយ ហ៊ុន ។ នៅឆ្នាំ១៩៦២ លាត បានរៀបការជាមួយនារីម្នាក់ឈ្មោះ ស៊ូ កិ ឈ្មោះបដិវត្តហៅ សាត អាយុ៣០ឆ្នាំ ស្រុកកំណើតនៅភូមិស្តុក ឃុំតាំងយ៉ាប ស្រុក៥៥ តំបន់៣៣ ហើយបានចូលបម្រើអង្គការបដិវត្តនៅឆ្នាំ ១៩៧៤ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លាត មានតួនាទីជាជំនួយការកងពល៧០៣ ។

លាត មានកូនបីនាក់ ស្រី១នាក់ និងប្រុស២នាក់ ។ កូនស្រីអាយុ១២ឆ្នាំ ត្រូវអង្គការបញ្ជូនឲ្យនៅមន្ទីរពេទ្យ៧០៣ កូនប្រុសអាយុ៩ឆ្នាំឋិតនៅក្នុងកង១៨២ និងកូនប្រុសម្នាក់ទៀតនៅក្នុងអង្គភាពកុមារ៣១ ។

លាត មានប្អូន៤នាក់ៈ ប្អូនទី១ស្រីឈ្មោះ ណាំ, ប្អូនទី២ស្រីឈ្មោះ ហ៊ីង, ប្អូនទី៣ប្រុសឈ្មោះសុង យាង និងប្អូនទី៤ស្រីឈ្មោះហោ ។

លាត ជាយុវជនក្រីក្រមួយរូប ក្រោយពីឪពុកស្លាប់ គ្រួសាររបស់ លាត កាន់តែមានសភាពដុនដាបទៅៗ ដីធ្លីទាំងប៉ុន្មានត្រូវធ្លាក់មកលើម្ចាស់ដីទាំងអស់ ។ ក្រោយមក លាត ត្រូវបានព្រះសង្ឃព្រះនាម ម៉ាក ហៅលោកគ្រូ ម៉ាក ជួយយកអាសាឧបត្ថម្ភឲ្យរៀនសូត្រអស់រយៈពេលជាច្រើនឆ្នាំ ។

ក្រោមការគ្រប់គ្រងរបស់លោកគ្រូម៉ាក លាត ក៏ត្រូវបានលោកគ្រូបញ្ជូនឲ្យទៅធ្វើការនៅគុកធំមួយ មូលហេតុថាចង់ឲ្យ លាត ទាក់ទងនឹងខ្មែររបស់លោកគ្រូដែលជាប់នៅក្នុងគុកនោះ ។ នៅក្នុងគុកធំ លាត មានតួនាទីជាអ្នកយាមនិងបណ្តើរអ្នកទោសពីកន្លែងមួយទៅដាក់កន្លែងមួយទៀត ហើយក៏ជាអ្នកនាំសំបុត្រពីលោកគ្រូ ម៉ាក ទៅឲ្យ នន់ សួន និងបងៗជាច្រើននាក់ដែលជាប់នៅក្នុងគុកនោះ ។ លាត ក៏ត្រូវចូលបម្រើការនៅក្នុងជួរបដិវត្តន៍តាំងពីពេលនោះមក ។ ក្រោយមកទៀត លាត បានទៅបន្តការទាក់ទងជាមួយនឹង ម៉ែន សាន ឬអាចារ្យ សៀង ហៅ យ៉ា ជាអនុរក្សសាលាចម្រើនវិជ្ជា ។

យោងតាមចម្លើយសារភាពដែលមានតម្កល់ទុកនៅសារមន្ទីរទួលស្លែងនោះ លាត បានសារភាពថាគាត់បានបម្រើក្រុមខ្មែរសេរីចាប់តាំងពីឆ្នាំ១៩៥៨(បង្កប់ខ្លួននៅក្នុងសាលាចម្រើនវិជ្ជា) រហូតថ្ងៃរំដោះក្រុងភ្នំពេញ ដោយធ្វើសកម្មភាពបំផុសចលនាផ្សេងៗទាក់ទងជាមួយខ្សែបដិវត្តចាស់ៗជាច្រើន ។ គាត់បានស្គាល់ និងទំនាក់ទំនងធ្វើសកម្មភាពជាច្រើនជាមួយខ្សែបណ្តាញមានដូចជាៈ ចក្រី, សុខប៊ុត ចំរើន, នន សួន, ឈឹម វ៉ាន់សាត, ប៉ុល ខាត់, យ៉ា,...និងឈ្មោះជាច្រើននាក់ដែលមាននៅក្នុងបញ្ជីឈ្មោះពាក់ព័ន្ធចំនួន១០៦នាក់ ពិសេសទៅទៀតគឺការទាក់ទងជាមួយខ្សែរយៈធ្វើការនៅមន្ទីរស-២១ដើម្បីរៀបចំផែនការកម្ទេចកម្មាភិបាលស-២១ ។ អ្នកទាំងអស់នោះភាគច្រើន ក្រោយមកក៏ត្រូវបានចាប់ខ្លួនដែរ ។ នៅឆ្នាំ១៩៧២ លាត ត្រូវទទួលបន្ទុកជាអនុមេបញ្ជាការកងវរសេនាធំ៣៣ កងពល៧០៣ ដែលមានឈ្មោះ ប៉ុល ខាត់ ជាមេបញ្ជាការក្រោមការចាត់តាំងរបស់ តាជ័យ (គណៈតំបន់២៥) ។

នៅខែមករា ឆ្នាំ១៩៧៦ មុនពេលបង្កើតផែនការប្រឆាំងបដិវត្តន៍ លាត បានទៅជួបចក្រី និង ភួន ។ ចក្រី បានប្រាប់ឲ្យដឹងថា ចាប់ពីខែមករានេះ យើងមានផែនការមួយគឺវាយយករដ្ឋអំណាចឲ្យបានដោយកំណត់ពេលវេលាច្បាស់លាស់គឺនៅខែ ៧-៧៦ ត្រូវតែបញ្ចប់ ។ លាត មានតួនាទីក្តាប់កង៧០៣និងជាជំនួយខាងកង១៧០ ។ នៅក្នុងអំឡុងពេលធ្វើការនៅកង ៧០៣ លាត ធ្លាប់បានរាយការណ៍អំពីសភាពការណ៍ទៅ ចក្រី ពីរ-បីដងដែរ មុនពេលដែល ចក្រី ត្រូវអង្គការចាប់ខ្លួន ។

បន្ទាប់ពីការចាប់ខ្លួនរបស់ ចក្រី ទៅ លាត បានរៀបចំផែនការមួយគឺកម្ទេចកម្មាភិបាលស-២១ ។

នៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៦ វេលាម៉ោង៧យប់ នៅក្នុងមន្ទីរ(ក-១៧) សាលាបឹងត្របែក លាត បានអញ្ជើញ

សមាជិករបស់ខ្លួនបីនាក់ៈ ឈុន, អេង, ស្រស់ មកប្រជុំកិច្ចការសម្ងាត់មួយដើម្បីរៀបចំផែនការធ្វើសកម្មភាពនៅក្នុងមន្ទីរ ស-២១ ។ លាត បានឲ្យកម្មាភិបាលដែលខ្សែរយៈទាក់ទងពីមុន ដែលដកចេញពីកងពល៧០៣ទៅធ្វើការបន្ត ។ ខ្លឹមសារនៃការប្រជុំនោះផ្តោតទៅលើចំណុចសំខាន់បីៈ ទី១ ចាត់តាំងឲ្យពិនិត្យសភាពការណ៍នៅក្នុងមន្ទីរស-២១ ។ ទី២ ទាក់ទងឡើងវិញចំពោះកម្មាភិបាលសំខាន់ៗនៅស-២១ ។ ទី៣) ផែនការនិងទិសត្រៀមកម្ទេចកម្មាភិបាលទៅថ្ងៃមុខ ។ ចំណុចទី១នេះ លាត បាននិយាយថា ខ្លួនត្រូវតែចាត់ឲ្យមនុស្សនៅខាងក្នុង(ស-២១) សម្រាប់ផ្តល់ពត៌មានមកខាងក្រៅ ។ ឈុន, អេង, ស្រស់ បានមានយោបល់ នៅក្នុងខណៈនោះថា នៅក្នុងមន្ទីរស-២១នោះមានតែ សុន ទេដែលអាចនឹងផ្តល់ពត៌មាន ពីព្រោះថា សុន ជាមនុស្សមានឥទ្ធិពលនិយាយទៅច្រើនតែគេស្តាប់ ។ លាត បានប្រគល់ការងារនេះទៅឲ្យឈ្មោះ អេង ទាក់ទង សុន ដែលធ្វើការនៅស្រែជិតគ្នា ដើម្បីឲ្យ សុន បន្តការទាក់ទងដោយសម្ងាត់បំផុតជាមួយកម្មាភិបាលសំខាន់ៗនៅមន្ទីរស-២១បន្តរួមមានឈ្មោះ សារ៉ាត, នារី គាង គ្រប់គ្រងនារី(នៅស-២១) ប៉េង និង ប៉ូលី ។ អេង បាននិយាយបន្ថែមថាឲ្យ សុន ប្នរណាម្នាក់ដឹកនាំបំផុសចលនាឲ្យពួកជាប់ពិរុទ្ធនិងយុទ្ធជនទើបនឹងចូលថ្មីឲ្យរត់ចេញពីមន្ទីរស-២១ ធ្វើយ៉ាងណាអាចបង្កភាពប្របូកប្របល់ និងធ្វើឲ្យរាំងស្ទះដល់ការធ្វើស្រែវស្សាក្នុងការលើកទំនប់លើកភ្លឺនិងជីកប្រឡាយ ។ បន្ទាប់មក ឈុន បានបន្តថា នៅក្នុងស-២១ត្រូវចាត់មនុស្សក្តាប់សភាពការណ៍ ហើយឲ្យ សុន ក្តាប់រួមតាមដានសភាពការណ៍ខាងក្នុងស-២១ ក្តាប់កម្មាភិបាលនិងយុទ្ធជននៅកន្លែងនោះផង ។ ស្រស់ និយាយថាៈ ដាក់ទិសកម្ទេចកម្មាភិបាលស-២១ចោលខ្លះទៅឲ្យកម្លាំងក្តាប់នៅក្នុងនោះ កម្ទេចអ្នកដែលធំជាងគេនៅស-២១ ប្រសិនបើ ឌុច ធំជាងគេនោះគឺសម្លាប់តែ ឌុច បានហើយ ។ នៅមន្ទីរស-២១ លាត បានស្គាល់ ឌុច, ចាន់ និង កម្មាភិបាលដែលចេញពីកងមកធ្វើការនៅស-២១មួយចំនួន មាន ហ៊ិរ, ហ៊ុយ និង ម៉ុនៗ ។ អេង បានឲ្យយោបល់បន្ថែមថា មិនចាំបាច់ទៅរកអ្នកណាទៀតសារ៉ាត នៅក្នុងស-២១ស្រាប់ ។ បន្ទាប់ពីផ្លាស់ប្តូរយោបល់រួចមក លាត ក៏បានបន្តថា ផែនការនៅមន្ទីរស-២១ គឺត្រូវតែធ្វើឲ្យស្របនឹងផែនការរបស់ខាងកង១៧០ ហើយប្រសិនបើផែនការខែ៧-៧៦ របស់កង១៧០ផ្ទុះឡើងគឺ "យើងរំដោះសមមិត្តយើងទាំងអស់ចេញពីកន្លែងនោះព្រមគ្នាតែម្តង ព្រោះជាកម្មាភិបាលដែលនៅស-២១ សារ៉ាត, ចាន់, នារី សៅ និង នារី គាង គឺជាមនុស្សល្អ អ្នកទាំងអស់នោះធ្វើការក្តាប់សភាពការណ៍រាល់ថ្ងៃ ។ ប្រសិនបើបែកការណ៍ ហើយផែនការបរាជ័យនោះ មានតែរត់ចេញទៅជាមួយខាងកង១៧០ដែលមានត្រៀមផែនការចាញ់សម្រាប់គេចខ្លួនទៅនៅព្រៃតាមផ្លូវលេខ១(គគីរធំ)" ។ ឈុន បន្ថែមទៀតថា"មានតែអ៊ីចឹងធ្វើចោរស្រុកមិនបានមានតែធ្វើចោរព្រៃ" ។ ការប្រជុំនេះបានសម្រេចថា នឹងធ្វើសកម្មភាពរយៈពេលបីខែ គឺចប់នៅខែ៧-៧៦ តាមផែនការបីចំណុចដែលបានពិភាក្សាពីខាងលើ ។

អតីតមន្ទីរលត់ដំក-១៧ របស់ខ្មែរក្រហម
បច្ចុប្បន្នៈ វិទ្យាល័យបឹងត្របែក

**វិទ្យាល័យបឹងត្របែក**



នៅចុងខែមីនា ឆ្នាំ១៩៧៦ លាត បានទទួលសេចក្តីរាយការណ៍រួមមួយថា សុន បានយល់ព្រមតាមផែនការដែលប្រជុំនោះ ហើយថែមទាំងបានផ្សព្វផ្សាយផែនការដល់ ប៉ូលី,

ប៉េង, ចាន់ និងនារី គាង ។ ចំណែកផែនការនៅភ្នំពេញ សុន មិនទាន់បានទាក់ទងនៅឡើយ ដោយសារតែខ្លួនគាត់មិនហ៊ាន មកពីព្រោះអង្គការស-២១កំពុងតាមដានស្អិតពេក (មិនមែនតែ សុន ម្នាក់ប៉ុណ្ណោះទេដែលត្រូវតាមដាន សូម្បីតែអ្នកទើប មកពីកង៧០៣ចូលមកស-២១ក៏ត្រូវតាមដានដែរ) ។ ដោយ ឃើញថាលទ្ធផលទទួលបានស្ងួចស្ងើងពេក នៅដើមខែ៤ លាត បានធ្វើដំណើរទៅជួបសមមិត្ត ឈុន នៅបាគូ ប្រាប់អំពីដំណឹង នេះ ។ ឈុន សុំឲ្យ លាត រង់ចាំពេលបន្តិចក្រែងថា សុន អាច មានឱកាសធ្វើបាន ។

នៅថ្ងៃបន្តបន្ទាប់មក អេង បានរាយការណ៍មកថា ផែនការ




ត្រៀមកម្ទេចកម្មាភិបាលនៅក្រុងភ្នំពេញមិនទាន់ទទួលបានលទ្ធផល ចំណែកនៅជនបទបំផុសបានតែអ្នកជាប់ពិរុទ្ធនិងយុទ្ធជនឲ្យរត់ ចេញពីកងបានមួយចំនួនតែប៉ុណ្ណោះ ។

មកដល់ខែ៤ លាត ត្រូវអង្គការផ្លាស់ចេញពីមន្ទីរកងពល ភ្នំពេញឲ្យទៅនៅបាគូជាមួយ ឈុន ទទួលបន្ទុកខាងជំនួយកងពល ផ្នែកបង្កបង្កើនផលវិញ ។

នៅវេលាម៉ោង៩ព្រឹក ខែ៥ ឆ្នាំ១៩៧៦ លាត បានជួប សុន កំពុងជីកប្រឡាយនៅខាងលិចវត្តហា ដើម្បីសាកសួរអំពី ផែនការនោះ ប៉ុន្តែត្រូវបាន សុន ប្រាប់ថាខ្លួនគាត់មិនអាចធ្វើ បានទេ ។ នៅវេលាម៉ោង៧យប់នាថ្ងៃដដែលនេះ នៅបាគូ លាត និង ឈុន បានយកបញ្ហាខាងលើមកពិភាក្សា ។ ក្នុងការ ពិភាក្សាបានបង្ហាញថាលទ្ធផលគឺនៅតែអវិជ្ជមាន មូលហេតុមក ពីការក្តាប់សភាពការណ៍នៅស-២១មិនទាន់ច្បាស់លាស់ក្តាប់ បានតែជារួមធ្វើអ្វីមិនកើត ហើយការទាក់ទងរវាងភ្នំពេញនិង ជនបទក៏ក្តាប់ផ្ទៃក្នុងមិនបាន ចំណែកកម្មាភិបាលនិងយុទ្ធជននៅ ស-២១អង្គការរឹតតែមានវិន័យម៉ឺងម៉ាត់ចង់ចូលទៅក្តាប់សភាព ការណ៍ពេលណាអង្គការដឹងទាំងអស់ ។ ម្យ៉ាងទៀតខ្សែទាក់ទង សកម្មភាពរបស់ លាត មិនមានភាពដាច់ខាត ម្នាក់ៗខ្លាច មានគ្រោះថ្នាក់ដល់ខ្លួនគ្មាននរណាម្នាក់ក្លាហានឡើយ ។ ដូច្នេះ ផែនការកម្មាភិបាលមន្ទីរស-២១នេះត្រូវបរាជ័យទាំងស្រុង ។

ក្រោយពីការចាប់ខ្លួនចក្រីនិងផែនការ បរាជ័យ នៅថ្ងៃទី១៥ ខែមិថុនា វេលាម៉ោង ៦ លាត បានបន្តជួបជាសម្ងាត់ជាមួយខ្សែ របស់ ចក្រី ឈ្មោះ ម៉ាត់(នៅខាង១៧០) និងភួន ។ ភួន បានបញ្ជាក់ពីតួនាទីខ្លួនប្រាប់ លាត និង ម៉ាត់ ថាគាត់បានទទួលធ្វើ កិច្ចការទាំងអស់បន្តពី ចក្រី គឺនៅតែធ្វើ បន្តទៅទៀតដូចដែល ចក្រី បានប្រាប់ ។ នៅក្នុងខណៈនោះ លាត សុំឲ្យ ម៉ាត់ ចាត់ចែងខ្សែរបស់គាត់ ឈ្មោះ អេង, ស្រស់...ជាអ្នកបាចខិត្តប័ណ្ណ ចំណែកខ្លួន គាត់ (លាត) ត្រូវត្រឡប់ទៅបាគូជាមួយ និរសាជាបន្ទាន់ក្រោយពេលពិភាក្សាចប់ ដើម្បីគេចខ្លួនពីការ តាមដាន ។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ១៩៧៦ លាត ត្រូវ អង្គការចាប់ខ្លួនបាន ។

**លី សុផល**

## ពាក្យស្លោកខ្មែរក្រហម

**«ក្របីលាក់ខ្លួនពួនសម្រួចស្នែង ដល់ពេលទឹកលិចត្រែង ទើប ចេញខាល។» ពាក្យស្លោកនេះមានន័យថា «លាក់ខ្លួននៅ ក្នុងបដិវត្ត ដើម្បីកសាងកម្លាំងវាយបដិវត្តវិញ។»**

**(ឯកសារ TSL C177 )**

# ទិន្នន័យទីតាំងរួមនៃអំពើប្រល័យពូជសាសន៍

## ការធ្វើផែនទីវាលពិឃាតនៃប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៥-២០០០

(តពីលេខមុន)

| ល.រ | ល.រទីតាំង | ឈ្មោះទីតាំង | ទិន្នន័យរណ្តៅនិងជនរងគ្រោះតាមជាក់ស្តែង | | ទិន្នន័យរណ្តៅនិងជនរងគ្រោះតាមរបាយការណ៍ | | របាយការណ៍ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|
| | | | ប៉ាន់ស្មានរណ្តៅ | ប៉ាន់ស្មានជនរងគ្រោះ | ប៉ាន់ស្មានរណ្តៅ | ប៉ាន់ស្មានជនរងគ្រោះ | |
| ១០៦ | ០១០២០១ | ចម្ការយាយហ៊ឹម | ៤០ | ២០០ | គ្មាន | គ្មាន | ១៩៩៧ |
| ១០៧ | ០១០២០២ | ល្អាងភ្នំគួយយំ | ១០ | ៥០០ | ១ | ១០០-២០០ | ១៩៩៧ |
| ១០៨ | ០១០២០៣ | វត្តបន្ទាយនាង | ២០០ | ៥០០០ | ១០០-២០០ | ៣៥០០-៥០០ | ១៩៩៧ |
| ១០៩ | ០១០២០៤ | វត្តបន្ទាយនាង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១១០ | ០១០៤០១ | ចម្ការតាលីង | ៦ | ៧២០ | ៦ | ៦៦០-៧២០ | ១៩៩៧ |
| ១១១ | ០១០៤០២ | ចម្ការតាលីង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១១២ | ០១០៤០៣ | ព្រៃតារត់ | ២០០ | ៣៩០០ | គ្មាន | ៣៨៩០ | ១៩៩៧ |
| ១១៣ | ០១០៤០៤ | ភូមិចក្រី | គ្មាន | ៣៥៧០ | គ្មាន | ៣៥៨០ | ១៩៩៧ |
| ១១៤ | ០១០៦០១ | ចម្ការខ្នុរ | ១០០ | ២០០០០ | គ្មាន | ២០០០០-២៥០០០ | ១៩៩៧ |
| ១១៥ | ០១០៦០២ | វត្តសុភមង្គល | គ្មាន | គ្មាន | ប្រហែល១០០ | គ្មាន | ១៩៩៧ |
| ១១៦ | ០២០១០១ | ចន្លោះក្តោង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១១៧ | ០២០១០២ | ល្អាងគិរីរម្យ | ៥ | ១៥៧០០ | គ្មាន | ១៥៧០០ | ១៩៩៧ |
| ១១៨ | ០២០១០៣ | ល្អាងគិរីរម្យ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១១៩ | ០២០១០៤ | ល្អាងគិរីរម្យ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១២០ | ០២០៥០១ | វត្តសំរោង | ១០០ | ១០០០៨ | ៩០-១០០ | ១០០៨ | ១៩៩៧ |
| ១២១ | ០២០៥០២ | វត្តសំរោង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១២២ | ០២០៥០៣ | វត្តសំរោង | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១២៣ | ០២០៥០៤ | វត្តឯកភ្នំ | ២០០ | ៥០០០ | ប្រហែល២០០ | គ្មាន | ១៩៩៧ |
| ១២៤ | ០២០៥០៥ | វត្តឯកភ្នំ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១២៥ | ០២០៦០១ | វត្តតាលាស់ចាស់ | ១០០ | ៥០០-៦០០ | ច្រើនរយ | ៥០០-៦០០ | ១៩៩៧ |
| ១២៦ | ០២០៦០២ | វត្តតាលាស់ចាស់ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១២៧ | ០២០៦០៣ | វត្តតាលាស់ចាស់ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១២៨ | ០២០៦០៤ | វត្តជ្រៃ | គ្មាន | គ្មាន | គ្មាន | ១០០-២០០ | ១៩៩៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១២៩ | ០២០៦០៥ | វត្តធម្មយុត្តិ | ១៥ | ១០០០ | លើសពី១ | ៣០០-១០០០ | ១៩៩៧ |
| ១៣០ | ០២០៦០៦ | វត្តធម្មយុត្តិ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៣១ | ០២០៦០៧ | ពោធិ៍១ | ២ | ១៥០ | គ្មាន | ១៥០ | ១៩៩៧ |
| ១៣២ | ០៣០៦០៣ | គោកព្រីង | ៥០ | ២៥០០០ | ៥០-៧០ | ប្រហែល២៥០០០ | ១៩៩៧ |
| ១៣៣ | ០៣១០០១ | ក្រូក | ២ | ៣០០ | ៤ | ប្រហែល៣០០ | ១៩៩៧ |
| ១៣៤ | ០៣១០០២ | វត្តក្រោកចាស់ | ១ | ៥០ | គ្មាន | គ្មាន | ១៩៩៧ |
| ១៣៥ | ០៣១០០៣ | វត្តក្រោកចាស់ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៣៦ | ០៣១២០១ | ចម្ការម៉ៃសាក់ | ២ | ៦០០ | ១២ | ៦០០ | ១៩៩៧ |
| ១៣៧ | ០៣១២០២ | ភូមិឡូ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៣៨ | ០៣១២០៣ | ចុងភូមិឡូ | ២០ | គ្មាន | ២០-២៥ | ៥០០-១០០០ | ១៩៩៧ |
| ១៣៩ | ០៣១២០៤ | ត្រពាំងសង្កែ | ១៥ | គ្មាន | ១០-១៥ | ៥០០-១០០០ | ១៩៩៧ |
| ១៤០ | ០៣១២០៥ | ត្រពាំងឬស្សី | ១០ | ២០០០ | ១០ | ប្រហែល២០០០ | ១៩៩៧ |
| ១៤១ | ០៣១២០៦ | អណ្តោត | ៤ | ២៣៤៨ | ៤ | ២៣៤៤ | ១៩៩៧ |
| ១៤២ | ០៣១២០៧ | អណ្តោត | ១៨៥ | ៨៩៤៦ | ១៨៥ | ៨៩៥០ | ១៩៩៧ |
| ១៤៣ | ០៣១២០៨ | ព្រៃស្វឹងតូច | ៣ | ១៨០៣ | ៤ | ១៨០៣ | ១៩៩៧ |
| ១៤៤ | ០៣១២០៩ | ស្វឹងតូច | ១ | គ្មាន | ១ | គ្មាន | ១៩៩៧ |
| ១៤៥ | ០៣១២១០ | ស្វឹងតូច | ៤ | គ្មាន | ៤ | គ្មាន | ១៩៩៧ |
| ១៤៦ | ០៣១២១១ | ឡូ៣៧ | ៥ | ៧២៨៦ | លើសពី១ | ប្រហែល៧២៨៦ | ១៩៩៧ |
| ១៤៧ | ០៤០៣០១ | វត្តខ្សាម | គ្មាន | ១៣០ | គ្មាន | ១៥០០ | ១៩៩៧ |
| ១៤៨ | ០៤០៥០១ | វត្តចំប៉ី | គ្មាន | ១២០ | គ្មាន | គ្មាន | ១៩៩៧ |
| ១៤៩ | ០៤០៥០២ | វត្តចំប៉ា | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៥០ | ០៤០៥០៣ | ស្រែតាកន | ៤ | គ្មាន | ៤ | គ្មាន | ១៩៩៧ |
| ១៥១ | ០៤០៥០៤ | វាលថ្លូវ | ៧ | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៥២ | ០៤០៨០១ | បន្ទាយចាស់ | ៤ | ៤០០០ | ៤ | ៤០០០ | ១៩៩៧ |
| ១៥៣ | ០៤០៨០២ | វត្តសុវណ្ណេ | ១៦-២០ | ១០០ | ១៦-២០ | ១០០ | ១៩៩៧ |
| ១៥៤ | ០៤០៨០៣ | បន្ទាយចាស់ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |
| ១៥៥ | ០៤០៨០៤ | វត្តសុវណ្ណេ | គ្មាន | គ្មាន | គ្មាន | គ្មាន | ១៩៩៧ |

**(នៅមានត)**

តួលេខដែលចុះផ្សាយក្នុងលេខនេះសម្រាប់ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តកំពង់ឆ្នាំង ។

◆ ចំពោះពត៌មានដែលដាក់ថា "គ្មាន" ន័យថាពុំមានសាក្សីឬតួលេខ ប៉ុន្តែវត្តមានទីតាំងបានមកពីប្រភពផ្សេង ។

◆ ចំពោះពត៌មានដាក់ស្តែងនិងពត៌មានតាមរបាយការណ៍ មានន័យខុសគ្នាត្រង់ថា ពត៌មានដាក់ស្តែងគឺបានមកពីសាក្សីដែលបញ្ជាក់ប្រាប់នៅទីតាំងកើតហេតុ ។ ពត៌មានតាមរបាយការណ៍មានន័យថា សាក្សីផ្សេងទៀតដែលប្រាប់តួលេខអំពីទីតាំងដដែល ។

# កាលប្បវត្តិរបស់ហាណូយ
## (១៩៦០-១៩៧៨)

**(តពីលេខមុន) ១៩៧១**

***២៦ មករា-៩ កុម្ភៈ*** *ប្រមុខរដ្ឋកម្ពុជា សម្តេចនព្រះ រោត្តម សីហនុ និងអ្នកម្នាង មុនីនាថ សីហនុ ធ្វើព្រះរាជទស្សនកិច្ចមិត្តភាពនៅប្រទេសវៀតណាម និងបានចូលរួមក្នុងពិធីបុណ្យចូលឆ្នាំជាប្រពៃណីនៅទីក្រុងហាណូយ ។ សម្តេចព្រះ នរោត្តម សីហនុ និងអ្នកម្នាង យាងទៅទីក្រុងហាណូយក្នុងឱកាសតែមួយដូចកាលពីឆ្នាំ១៩៧២និងឆ្នាំ១៩៧៣ដែរ ។*

***១០ វិច្ឆិកាៈ*** *គណៈប្រតិភូរបស់រណសិរ្សរួបរួមជាតិនិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាមួយក្រុម ដឹកនាំដោយ អៀង សារី តំណាងពិសេសនៃរណសិរ្សរួបរួមជាតិនិងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា មកដល់ទីក្រុងហាណូយដើម្បីធ្វើទស្សនកិច្ចជាមិត្តភាព ។ នៅក្នុងសេចក្តីថ្លែងការណ៍រួមគ្នាមួយរវាងកម្ពុជានិងវៀតណាមដែលចេញផ្សាយនៅទីក្រុងហាណូយ គណបក្សទាំងពីរបញ្ជាក់សាជាថ្មីអំពី«ការតាំងចិត្តក្នុងការអនុវត្តគោលការណ៍ទាំង៥ចំណុចដើម្បីសន្តិភាពរួម ពោលគឺៈ គោរពអធិបតេយ្យភាពនិងបូរណភាពដែនដីរបស់គ្នាទៅវិញទៅមក ការមិនឈ្លានពានគ្នា ការគោរពរបបនយោបាយគ្នាទៅវិញទៅមក និងមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងផងគ្នា សមភាពនិងផលប្រយោជន៍គ្នាទៅវិញទៅមក និងសន្តិសហវិជ្ជមាន» ។*

**១៩៧៣**

***មករាៈ*** *ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីការបញ្ចប់សង្គ្រាមនិងការស្តារសន្តិភាពឡើងវិញនៅប្រទេសវៀតណាម ។ ទាក់ទងបញ្ហាកម្ពុជានិងឡាវវិញ មាត្រាទី២០ (ជំពូក VII) នៃកិច្ចព្រមព្រៀង ចែងថាៈ «បក្សទាំងឡាយដែលចូលរួមនៅក្នុងសន្និសីទទីក្រុងប៉ារីសស្តីពីបញ្ហាវៀតណាមត្រូវគោរពអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៥៤ស្តីអំពីបញ្ហាកម្ពុជា និងកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវឆ្នាំ១៩៦២ស្តីអំពីបញ្ហាឡាវដែលទទួលស្គាល់សិទ្ធិជាមូលដ្ឋានរបស់ប្រជាជនកម្ពុជានិងប្រជាជនឡាវ ពោលគឺ ឯករាជ្យភាព អធិបតេយ្យភាព ឯកភាព និងបូរណភាពទឹកដីរបស់ប្រទេសទាំងនេះ ។ ភាគីទាំងអស់ត្រូវគោរពអព្យាក្រឹតភាពរបស់កម្ពុជានិងឡាវ» ។*

***កុម្ភៈ-មីនាៈ*** *សម្តេចព្រះ នរោត្តម សីហនុ និងព្រះរាជអគ្គអ្នកម្នាង មុនីនាថ សីហនុ យាងធ្វើព្រះរាជទស្សនកិច្ចជាផ្លូវការនៅតំបន់រំដោះនៃប្រទេសកម្ពុជាអស់រយៈពេលជាងមួយខែ ។*

***៦ មេសាៈ*** *នៅពេលយាងត្រឡប់មកពីដំណើរទស្សកិច្ចនៅតំបន់រំដោះសម្តេចព្រះ នរោត្តម សីហនុ និងអ្នកម្នាង មុនីនាថ សីហនុ បានយាងមកធ្វើព្រះរាជទស្សនកិច្ចជាមិត្តភាពនៅទីក្រុងហាណូយទៀត ។*

***១៥ សីហាៈ*** *ការបញ្ចប់ការទម្លាក់គ្រាប់បែកអាមេរិកាំងមកលើប្រទេសកម្ពុជា ។*

***៩វិច្ឆិកាៈ*** *យោងតាមប្រភពពត៌មានខ្មែរ អាគី (AKI) បានឲ្យដឹងថា សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាប្រកាសថា រដ្ឋមន្ត្រីរបស់ខ្លួនទាំងអស់ត្រូវផ្ទេរមកកម្ពុជាវិញ ។*

**១៩៧៤**

***៤មីនាៈ*** *សំបុត្រមកពី ប៉ុល ពត លេខាគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជា ជូនចំពោះ ឡេ ឌឹកថ សមាជិកគណៈកម្មាធិការនយោបាយនៃគណៈកម្មាធិការកណ្តាលបក្សពលករវៀតណាម សរសេរក្រៅពីរឿងផ្សេងៗទៀតថា «ខ្ញុំសូមធានាយ៉ាងស្មោះស្ម័គ្រនិងអស់ពីដួងចិត្តថា ក្នុងកាលៈទេសៈណាក៏ដោយ ក៏ខ្ញុំនៅតែមានភក្តីភាពចំពោះមាគ៌ាសាមគ្គីភាពភាតរភាពបដិវត្តរវាងកម្ពុជានិងវៀតណាមជានិច្ច ទោះជាមានការលំបាកនិងបច្ចាមិត្របែបណាក៏ដោយ» ។*

***៣០ មីនាៈ*** *ខៀវ សំផន ប្រធានរណសិរ្សរួបរួមជាតិកម្ពុជានិងគណៈប្រតិភូនៃរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលកំពុងធ្វើទស្សនកិច្ចនៅទីក្រុងហាណូយ បានប្រកាសនៅក្នុងកិច្ចប្រជុំមួយ*

ដែលរៀបចំដោយប្រជាជនទីក្រុងហាណូយថា "យុទ្ធសាមគ្គីភាព និងភាតរភាពរវាងប្រជាជនយើងទាំងពីរត្រូវបានពង្រឹងជាលំដាប់ ដោយសារមានមូលដ្ឋានត្រឹមត្រូវៈ ការជួយគ្នាទៅវិញទៅមក ដោយឈរលើមូលដ្ឋានស្មើភាពគ្នា និងគោរពអធិបតេយ្យភាពគ្នាទៅវិញទៅមកតាមស្មារតីនៃសេចក្តីប្រកាសរួមក្នុងសន្និសីទកំពូលប្រជាជនឥណ្ឌូចិនឆ្នាំ១៩៧០" ។

**១២ សីហាៈ** នៅក្នុងទូរសារស្តីអំពី "សភាពការណ៍បដិវត្តបច្ចុប្បន្ននៅកម្ពុជា" ដែលផ្ញើជូនគណៈកម្មាធិការមជ្ឈិមបក្សពលករកម្ពុជា គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាគូសបញ្ជាក់ថា "ដោយសង្គ្រាមខិតជិតដល់ទីបញ្ចប់ហើយនោះ ស្ថានការណ៍លំបាកស្មុគស្មាញកាន់តែកើនឡើងឥតឈប់ឈរ ។ ប៉ុន្តែជំហររបស់យើងគឺជឿជាក់យ៉ាងម៉ឺងម៉ាត់ថា ដោយសារមានជំនួយនិងការឧបត្ថម្ភគាំទ្រដោយឥតលក្ខខណ្ឌពីបក្សនិងប្រជាជនវៀតណាម យើងទាំងអស់រីករាយនឹងស្ថានការណ៍នេះក្នុងការសម្រេចជ័យជម្នះទាំងស្រុង" ។

## ១៩៧៥

**២៥ មករាៈ** នៅក្នុងសារលិខិតជូនចំពោះ ឡេ ឌឹកថ សមាជិកការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមនៃបក្សពលករវៀតណាម ប៉ុល ពត អគ្គលេខាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាសរសេរថា "ជ័យជម្នះផ្សេងៗរបស់យើងគឺបានមកពីជំនួយគ្រប់បែបយ៉ាងដែលផ្តល់ដោយខ្លួនយើងផ្ទាល់និងបក្សពលករវៀតណាមព្រមទាំងប្រជាជនវៀតណាម ។ យើងចាត់ទុកជ័យជម្នះថា ជាការសម្តែងនូវអារម្មណ៍អស្ចារ្យនិងប្រសើរក្រៃលែងនៃយុទ្ធសាមគ្គីភាពនិងភាតរភាពបដិវត្ត" ។

**៣០ មករាៈ** សារលិខិតស្វាគមន៍ដែលផ្ញើមកពីគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជាជូនចំពោះមជ្ឈិមបក្សនៃបក្សពលករវៀតណាម នៅក្នុងឱកាសខួបកំណើតបង្កើតបក្សពលករវៀតណាមសង្កត់ធ្ងន់ថា "តាមរយៈការតស៊ូអស់រយៈពេលជាងមួយសតវត្សរ៍ប្រឆាំងនឹងខ្មាំងសត្រូវគ្រប់ប្រភេទមានដូចជាពួកអាណានិគមបារាំង ហ្វាស៊ីសជប៉ុន និងជាពិសេសចក្រពត្តិអាមេរិក បក្សកុម្មុយនិស្តកម្ពុជានិងប្រជាជនកម្ពុជាព្រមទាំងបក្សពលករវៀតណាមនិងប្រជាជនវៀតណាមបានបញ្ជាក់នូវយុទ្ធសាមគ្គីភាពនិងភាតរភាពជាបងប្អូនដែលគ្មានអ្វីមកបំបែកបានឡើយ...។

**១៧ មេសាៈ** រំដោះទីក្រុងភ្នំពេញ ។ រដ្ឋអំណាចថ្មីនៅកម្ពុជាបង្ខំឲ្យប្រជាជនចាកចេញពីទីក្រុងទៅនៅជនបទនិងធ្វើការបង្កបង្កើនផល ។ មិនត្រឹមតែមាននយោបាយអមនុស្សធម៌ប្រឆាំងនឹងប្រជាជនកម្ពុជាទេ ប៉ុន្តែទន្ទឹមពេលនេះដែរ រដ្ឋអំណាចចាប់ផ្តើមបង្ក្រាបយ៉ាងឃោរឃៅប្រឆាំងនឹងអាណិកជនវៀតណាម ។ កម្ពុជានឹងកាត់ផ្តាច់ទំនាក់ទំនងពីពិភពលោក ។ ក្រោយពីថ្ងៃរំដោះគ្មានអ្នកកាសែតបរទេសណាម្នាក់ត្រូវបានអនុញ្ញាតឲ្យចូលទីក្រុងភ្នំពេញឡើយ ។

**៤ ឧសភាៈ** កងកម្លាំងប្រដាប់អាវុធកម្ពុជាវាយប្រហារមកលើកោះ ហ្វូ កុក ដែលជាផ្នែកមួយនៃទឹកដីវៀតណាម ។

**៨ ឧសភាៈ** កងកម្លាំងប្រដាប់អាវុធកម្ពុជាវាយលុកចូលទឹកដីវៀតណាមនៅកន្លែងជាច្រើនតាមព្រំប្រទល់រវាងខេត្តហាទៀងនិងខេត្តតាយនិញ ។

**១០ ឧសភាៈ** កងកម្លាំងប្រដាប់អាវុធកម្ពុជាវាយកាន់កាប់កោះ ថ ជូ ហើយចាប់អ្នករស់នៅលើកោះនោះអស់ចំនួន ៥១៥នាក់ ។

**២ មិថុនាៈ** នៅក្នុងកិច្ចចរចាជាមួយ ង្វៀន វ៉ាន់លិញ តំណាងឲ្យបក្សពលករវៀតណាម ប៉ុល ពត លេខាបក្សកុម្មុយនិស្តកម្ពុជានិយាយថាទាហានកម្ពុជា"ក្តាប់ភូមិសាស្ត្រមិនបានបណ្តាលឲ្យមានការប៉ះទង្គិចបង្ហូរឈាមដ៏ឈឺចាប់បែបនេះ"ជាមួយវៀតណាមទេ ។

**២ សីហាៈ** គណៈប្រតិភូមួយក្រុមរបស់បក្សពលករវៀតណាមដឹកនាំដោយ ឡេ យន់ លេខាទី១នៃគណៈកម្មាធិការមជ្ឈិមបក្សមកធ្វើទស្សនកិច្ចនៅកម្ពុជា ។ គោលបំណងនៃដំណើរទស្សនកិច្ចនេះ គឺសំដៅពង្រឹងសាមគ្គីភាពនិងមិត្តភាពរវាងបក្សនិងប្រទេសទាំងពីរ ។

**១០ សីហាៈ** ក្នុងជំនួបជាមួយ ប៉ុល ពត, ង្វៀន វ៉ាន់លិញ តំណាងឲ្យបក្សពលករវៀតណាម ប្រកាសថា កងទ័ពកម្ពុជាចំនួន ៦០០នាក់ដែលត្រូវបានចាប់ជាឈ្លើយសឹកក្នុងពេលវាយប្រហារមកលើទឹកដីវៀតណាម នឹងត្រូវដោះលែង។ ប៉ុន្តែខាង

ភាគីកម្ពុជានៅតែបន្តឃុំឃាំងជនជាតិវៀតណាមចំនួន៥១៥នាក់ ដែលត្រូវបានចាប់ខ្លួននៅលើកោះ ថ ជូ ដដែល ។

**១៥ កញ្ញា:** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមប្រចាំនៅភ្នំពេញវិលត្រឡប់មកកាន់តំណែងនៅក្នុងទីក្រុងភ្នំពេញវិញ បន្ទាប់ពីអាក់ខានក្នុងអំឡុងពេលរដ្ឋប្រហាររបស់ លន់ ណុល-សិរិមតៈ (ឆ្នាំ១៩៧០-១៩៧៥) ។

**ធ្នូ:** កងកម្លាំងប្រដាប់អាវុធកម្ពុជាបន្តទន្ទ្រានមកលើទឹកដីវៀតណាមជាច្រើនកន្លែងនៅខេត្ត ហ្សា ឡាយ-កុនទុំ និង ដាឡាក់ ។

## ឆ្នាំ១៩៧៦

**៥ មករា:** ការផ្សព្វផ្សាយរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ។

**១១-១៣ មេសា:** សម័យប្រជុំលើកទីមួយរបស់សភាប្រជាជនកម្ពុជា ដែលទើបតែបោះឆ្នោតជ្រើសតាំងថ្មីដើម្បីដឹកនាំអង្គការរដ្ឋ÷

- ◆គណៈប្រធានរដ្ឋៈ ខៀវ សំផន
- ◆គណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រជាជនៈនួន ជា ជាប្រធាន
- ◆រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យៈ ប៉ុល ពត ជានាយករដ្ឋមន្ត្រី ។

**៤-៨ ឧសភា:** ដើម្បីរៀបចំកិច្ចប្រជុំកំពូលរវាងបក្សពលករវៀតណាមនិងបក្សកុម្មុយនិស្តកម្ពុជា ដែលនឹងរៀបចំធ្វើនៅខែមិថុនា ឆ្នាំ១៩៧៦ ភាគីវៀតណាមនិងកម្ពុជាបានរៀបចំកិច្ចប្រជុំត្រៀមលក្ខណៈមួយនៅទីក្រុងភ្នំពេញ ។ នៅក្នុងឱកាសនេះភាគីកម្ពុជាយល់ព្រមប្រើប្រាស់ផែនទីដែលមានមាត្រដ្ឋាន១:១០០.០០០ដែលបង្កើតនិងចេញផ្សាយដោយអង្គការសេវាកម្មភូមិសាស្ត្រឥណ្ឌូចិននិងដែលត្រូវបានប្រើប្រាស់នៅមុនឆ្នាំ១៩៥៤ ធ្វើជាមូលដ្ឋានក្នុងការកំណត់ព្រំប្រទល់រវាងប្រទេសទាំងពីរ ។ ភាគីទាំងពីរមិនយល់ស្របគ្នាលើបញ្ហាព្រំដែនទឹកទេ ។ កិច្ចប្រជុំត្រៀមលក្ខណៈនេះត្រូវបានផ្អាកវិញតាមសំណើរបស់ភាគីកម្ពុជា ។ ក្រោយមកភាគីវៀតណាមបានស្នើជាច្រើនលើកច្រើនសាឲ្យមានកិច្ចចរចាសាជាថ្មី ប៉ុន្តែមិនបានទទួលចម្លើយពីភាគីកម្ពុជាឡើយ ។

ក៏ប៉ុន្តែភាគីទាំងពីរយល់ស្របគ្នាលើវិធានការទាំងបីដូចខាងក្រោមនេះ÷

១) បក្សទាំងពីរនឹងខិតខំអប់រំកម្មាភិបាល យុទ្ធជន និងប្រជាជនរបស់ប្រទេសទាំងពីរអំពីបញ្ហាព្រំដែនក្នុងគោលបំណងពង្រឹងសាមគ្គីភាព មិត្តភាព និងដើម្បីចៀសវាងមិនឲ្យមានជម្លោះនឹងគ្នា ។

២) ជម្លោះទាំងអស់ត្រូវតែដោះស្រាយតាមស្មារតីសាមគ្គីភាព មិត្តភាព និងគោរពគ្នាទៅវិញទៅមក ។

៣) គណៈទាក់ទងនៃភាគីទាំងពីរត្រូវស៊ើបអង្កេតករណីជម្លោះផ្សេងៗនិងរៀបចំកិច្ចប្រជុំដើម្បីដោះស្រាយ ។

**ខែធ្នូ:** សេចក្តីដកស្រង់ពីសេចក្តីសម្រេចរបស់សមាជជាតិលើកទីបួនរបស់បក្សពលករវៀតណាមៈ «យើងនឹងថែរក្សានិងបង្កើនទំនាក់ទំនងជាពិសេសរវាងប្រជាជនវៀតណាមនិងប្រជាជនឡាវ-កម្ពុជាជាបងប្អូន ពង្រឹងយុទ្ធសាមគ្គីភាព ការទុកចិត្តគ្នា កិច្ចសហប្រតិបត្តិការយូរអង្វែង និងការជួយគ្នាទៅវិញទៅមកនៅក្នុងវិស័យផ្សេងៗតាមគោលការណ៍ស្មើភាពគោរពឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី និងការគោរពផលប្រយោជន៍ស្របច្បាប់របស់ផងគ្នា...» ។

## ឆ្នាំ១៩៧៧

**៤-១១ មករា:** កងកម្លាំងប្រដាប់អាវុធកម្ពុជារំលោភទឹកដីវៀតណាមម្តងហើយម្តងទៀតនៅខេត្តឡុងអាន, កៀនហ្សាង, តាយនិញ, ដាឡាក់ និង ដុងថាប ។ ព្រឹត្តិការណ៍ធ្ងន់ធ្ងរបានកើតឡើងនៅព្រឹកថ្ងៃទី១១ ខែមករា ដែលនៅពេលនោះយោធាខាងកម្ពុជាពីរកងវរសេនាធំបានវាយចូលទឹកដីវៀតណាមក្នុងខេត្តអានហ្សាង ដោយប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនមកលើជនស៊ីវិល ។

**១៥-១៨ មករា:** កងកម្លាំងប្រដាប់អាវុធកម្ពុជាបន្តវាយប្រហារក្នុងខេត្តអានហ្សាង តទៅទៀត ។

**១៥-១៨ មីនា:** កងកម្លាំងប្រដាប់អាវុធកម្ពុជារំលោភម្តងហើយម្តងទៀតមកលើទឹកដីខេត្ត កៀនហ្សាង និង អានហ្សាង ដែលមានព្រំប្រទល់ជាប់ខេត្តកំពត និងខេត្តតាកែវចំនួន១០០គីឡូម៉ែត្រ ។ កងកម្លាំងប្រដាប់អាវុធកម្ពុជាប្រព្រឹត្តការសម្លាប់រង្គាលមកលើជនស៊ីវិលគ្រប់ទីកន្លែង តាមទិសស្លោករបស់ខ្លួនថា «លួច ឆក់ សម្លាប់ និងបំផ្លាញអ្វីៗទាំងអស់» ។

***៣០ មេសាៈ*** នៅពេលប្រជាជនវៀតណាមរៀបចំប្រារព្ធទិវាពលកម្មអន្តរជាតិ (១ឧសភា) កងអនុសេនាតូចពីរអន្តរភាព និងកងវរសេនាតូចឯករាជ្យនៃកងប្រដាប់អាវុធកម្ពុជាប្រជាធិបតេយ្យ ដោយមានការបាញ់ផ្លោងកាំភ្លើងធំគាំទ្របានធ្វើការវាយប្រហារមកលើភូមិចំនួន១៣នៅតាមព្រំដែនក្នុងខេត្តអានហ្យាង ។ ក្នុងអំឡុងពេលប្រយុទ្ធនេះមានការប្រព្រឹត្តឧក្រិដ្ឋកម្មដ៏សាហាវជាទីបំផុតៈ ស្ត្រី ត្រូវរំលោភ ហើយក្មេងៗត្រូវវះពោះ និងត្រូវកាត់ជាពីរកំណាត់វត្តអារាមនិងសាលារៀនត្រូវដុតបំផ្លាញចោល ។ មានគ្រួសារមួយមានគ្នា៩នាក់ត្រូវសម្លាប់ចោលទាំងអស់គ្មានសល់ម្នាក់ ។

***១២ ឧសភាៈ*** រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាមចេញសេចក្តីប្រកាសមួយ ស្តីអំពីតំបន់ដែនសមុទ្រជាប់នឹងដែនដីតំបន់សេដ្ឋកិច្ច និងខ្ពង់រាបបាតសមុទ្រវៀតណាម ។ មាត្រាទី៧នៃសេចក្តីប្រកាសនេះចែងថា "រដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមនឹងដោះស្រាយតាមរយៈការចរចាជាមួយប្រទេសដែលពាក់ព័ន្ធទៅលើបញ្ហាទាំងឡាយទាក់ទងនឹងតំបន់សមុទ្រ ខ្ពង់រាបនិងបាតសមុទ្រនៃប្រទេសទាំងពីរដោយឈរលើមូលដ្ឋានគោរពឯករាជ្យភាពនិងអធិបតេយ្យភាពគ្នាទៅវិញទៅមក យោងតាមច្បាប់និងការអនុវត្តជាក់ស្តែងជាលក្ខណៈអន្តរជាតិ" ។

***១៩ ឧសភាៈ*** យោងតាមរបាយការណ៍ស្ថិតិនៃមេបញ្ជាការយោធាខេត្តអានហ្យាងបានឲ្យដឹងថា ចាប់ពីថ្ងៃទី២៥ ខែមេសា ដល់ថ្ងៃទី១៩ ខែឧសភា កងកម្លាំងប្រដាប់អាវុធកម្ពុជានៅក្នុងខេត្តនេះបានសម្លាប់ប្រជាជនអស់ចំនួន២២២នាក់ ភាគច្រើនជាមនុស្សចាស់ ស្ត្រី និងកូនក្មេង ។ ដុតផ្ទះអស់ចំនួន៥៥២ខ្នងដោយមិនរាប់ផ្ទះដែលត្រូវបានកម្ទេចចោលនៅក្រុងជូដុក (នៅថ្ងៃទី១៧ ខែឧសភា) ទេ ។ ដុតបំផ្លាញស្រូវអស់១៣៤តោននិងបណ្តេញ ប្រជាជនចេញពីស្រុកភូមិគ្មានសល់ម្នាក់ ។

***៧ មិថុនាៈ*** សំបុត្រមកពីគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តវៀតណាមនិងរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម ជូនចំពោះគណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនិស្តកម្ពុជានិងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ស្នើឲ្យបញ្ឈប់ការប្រទូសរ៉ាយនិងបើកការចរចាស្តីអំពីបញ្ហាព្រំដែនរវាងប្រទេសទាំងពីរ ។ សំណើនេះបានត្រូវបដិសេធដោយភាគីកម្ពុជា ។

**មិថុនា-សីហាៈ** ការវាយប្រហារដោយកាំភ្លើងធំរបស់កងកម្លាំងប្រដាប់អាវុធកម្ពុជាចេះតែបន្តទៅនៅតាមព្រំប្រទល់ខេត្តអានហ្យាង, កៀនហ្យាង, ឡុងអាន, តាយនិញ ។ល ។

**៧ កញ្ញាៈ** ការផ្លោងកាំភ្លើងធំរបស់កម្ពុជាចូលជ្រោយហ្វាញ់ ហ្សូវ ភាគពាយ័ព្យនៃកោះភូគួក ។

១៨-២០ កញ្ញាៈ ឃុំទាំង៦នៅជាប់ព្រំដែនក្នុងខេត្តដុងថាប (ព្រំប្រទល់ជាប់ខេត្តព្រៃវែង) ត្រូវបានកងកម្លាំងកម្ពុជាវាយប្រហារ ។

**២៤កញ្ញា-៣០វិច្ឆិកាៈ** កងទ័ពកម្ពុជាបីកងពលបានបោះទីតាំងប្រចាំការអចិន្ត្រៃយ៍នៅតំបន់ជាប់ព្រំដែននៃខេត្តតាយនិញតាមខ្សែត្រៀមចម្ងាយ២៤០គីឡូម៉ែត្រ ។ កងទ័ពកម្ពុជាកាន់កាប់ទឹកដីវៀតណាមជាច្រើនកន្លែងជាពិសេសនៅតំបន់មួយមានចម្ងាយ១០គីឡូម៉ែត្រចូលក្នុងទឹកដីវៀតណាមនៅត្រើយម្ខាងខាងកើតស្ទឹងវាមកូ ។ ស្ថិតិដំបូងបង្ហាញថាជនស៊ីវិលវៀតណាមចំនួន១០០០នាក់ត្រូវស្លាប់និងរងរបួស ហើយមួយចំនួនធំត្រូវចាប់ជាឈ្លើយ ចំណែកគោក្របីចំនួន១០០០ក្បាលរួមជាមួយទ្រព្យសម្បត្តិផ្សេងៗទៀតត្រូវបានរឹបអូសយកដែរ ។**(នៅមានត)**

## ពាក្យស្លោកខ្មែរក្រហម

- **វាយខ្លាំងដោយគ្មានសម្រុះសម្រួល វាយទាល់តែអស់ចក្រពត្តិអាមេរិកនិងបរិវារខាងក្រៅរបស់វាពីផែនដីកម្ពុជា វាយឱ្យទាល់តែរលំរលាយនូវបក្សពួកអាយ៉ង លន់ ណុល, សិរិមតៈ, សឺង ង៉ុកថាញ់ ដើម្បីឯករាជ្យ អព្យាក្រឹត្យ សន្តិភាព បូរណភាពដែនដី អធិបតេយ្យភាព ប្រជាធិបតេយ្យ និងសម្បូររុងរឿង។** (សៀវភៅកំណត់ហេតុអ៊ីវ)
- **រក្សាប្រៀបលើខ្មាំង ហើយវាយសម្រុកខ្មាំងគ្រប់មុខ និងជាប់ជានិច្ច ដើម្បីកុំឱ្យខ្មាំងដកដង្ហើមរួច។**

*សៀវភៅកំណត់ហេតុ អ៊ីវ (អ៊ីវ ប៊ុនឈឿន)*

# សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា: អំពីគោលនយោបាយរបស់បក្ស ចំពោះអ្នកភ័ន្តច្រឡំចូលសេ.អ៊ី.អា ឬធ្វើភ្នាក់ងារយួន ឬចូលកា.ហ្សេ.បេ ប្រឆាំងបក្ស បដិវត្ត ប្រជាជននិងកម្ពុជាប្រជាធិបតេយ្យ

ចំពោះអ្នកដែលបានភ័ន្តច្រឡំទទួលការចាត់តាំងពីខ្មាំង ចូល សេ.អ៊ី.អា ឬធ្វើភ្នាក់ងារយួន ឬចូល កា.ហ្សេ.បេ ប្រឆាំងបក្សបដិវត្តប្រជាជននិងកម្ពុជាប្រជាធិបតេយ្យ បក្សយើងមានមាគ៌ាដូចតទៅ÷

**ទី១) ចំពោះអ្នកចូល សេ.អ៊ី.អា ឬចូលយួន ឬចូល កា.ហ្សេ.បេ ពីឆ្នាំ១៩៤៦-១៩៦៧:**

អ្នកណាក៏ដោយទោះបីបានចូលសេ.អ៊ី.អា ឬចូលយួន ឬចូល កា.ហ្សេ.បេ ពីឆ្នាំ១៩៤៦-១៩៦៧មកហើយក្តី តែបើក្រោយមកទៀតគ្មានធ្វើសកម្មភាពក្បត់ទេ បុគ្គលនោះមិនមានទោសពៃរ៍អ្វីទេ ។ បក្សកំណត់ថា ចូលសេ.អ៊ី.អា ឬចូលយួន ឬចូលកា.សេ.បេពេលនោះជាការសារភាពសភាពការណ៍ក្នុងកាលៈទេសៈដែលខ្មាំងវាពាតត្បាតខ្លាំងជាបន្តបន្ទាប់សម្តែងកម្លាំងរបស់វាឱយគេខ្លបខ្លាចវា ហើយកម្លាំងបដិវត្តនៅកំពុងជួបការលំបាកនៅឡើយ ។ចូលសេ.អ៊ី.អា ឬចូលយួន ឬចូលកា.ហ្សេ.បេ មិនត្រូវទេតែបក្សយើងអនុគ្រោះបាន បើក្រោយមកគ្មានសកម្មភាពក្បត់ទេ ។

**ទី២) ចំពោះអ្នកចូលសេ.អ៊ី.អា ឬចូលយួន ឬចូល កា.ហ្សេ.បេ ពីឆ្នាំ១៩៦៨-១៩៧០:**

ចំពោះអ្នកណាដែលចូលសេ.អ៊ី.អា ឬចូលយួន ឬចូល កា.ហ្សេ.បេពីឆ្នាំ១៩៦៨-១៩៧០ ក៏បក្សមិនយកទោសពៃរ៍អីដែរបើក្រោយមកគ្មានធ្វើសកម្មភាពក្បត់ទេ ។ ពីឆ្នាំ១៩៦៨មកឆ្នាំ១៩៧០ អត្តភាពនយោបាយរបស់បក្សយើងកាន់តែឡើង ហើយកម្លាំងបដិវត្តក៏កាន់តែរីកចំរើន ហើយពន្លឺមាគ៌ាខ្លួនឧបត្ថម្ភមានអស់ហើយ ។ ប៉ុន្តែខ្មាំងនៅមានកម្លាំងជាងយើងនៅឡើយ ហើយវាធ្វើសកម្មភាពពាតត្បាតយ៉ាងព្រៃផ្សៃតទៅទៀត នាំឱយអ្នកខ្លះធ្លាក់ក្នុងទុទិដ្ឋិនិយមសារភាពសភាពការណ៍ពេលនោះ ហើយទៅចូល សេ.អ៊ី.អា ចូលយួន ឬចូលកា.ហ្សេ.បេ. ធ្វើយ៉ាងនេះខុសហើយ តែបក្សយើងមិនប្រកាន់ទោសពៃអ៊ីទេ បើក្រោយមកគ្មានធ្វើសកម្មភាពក្បត់ទេ ។

**ទី៣) ចំពោះអ្នកចូលសេ.អ៊ី.អា ឬចូលយួន ឬចូល កា.ហ្សេ.បេ ពីឆ្នាំ១៩៧០-១៩៧៥:**

ពីឆ្នាំ១៩៧០ ដល់ថ្ងៃ១៦មេសា ឆ្នាំ១៩៧៥អត្តនោម័តិរបស់បក្សយើងនិងបដិវត្តន៍យើងកាន់តែខ្លាំងហើយ ។ តែទោះជាមានការភ័ន្តច្រឡំទៅចូលយួនឬសេ.អ៊ី.អាឬកា.ហ្សេ.បេ ពេលនោះក៏បក្សយើងមិនយកទោសពៃអីដែរ ។ ចូលសេ.អ៊ី.អា ឬចូលយួន ឬចូលកា.ហ្សេ.បេគឺខុសហើយ ។ តែបក្សសន្តោសមិនឱយមានទោសពៃរ៍ទេ បើក្រោយមកគ្មានធ្វើសកម្មភាពក្បត់ទេ ។

**ទី៤) ចំពោះអ្នកចូល សេ.អ៊ី.អា ឬចូលយួន ឬចូល កា.ហ្សេ.បេ ពីឆ្នាំ១៩៧៥-១៩៧៨**

ចំពោះអ្នកណាដែលចូលសេ.អ៊ី.អាឬចូលយួន ឬកា.ហ្សេ.បេនៅក្រោយរំដោះហើយបក្សបែងចែកជាពីរប្រភេទដូចតទៅ÷

ប្រភេទទី១: អ្នកណារឹងរូសបន្តធ្វើសកម្មភាពប្រឆាំងបក្សកុម្មុយនិស្តកម្ពុជា ប្រឆាំងរដ្ឋអំណាចបដិវត្តកម្មករ-កសិករ ប្រឆាំងរបបសមូហភាពសង្គមនិយម ប្រឆាំងប្រជាជនកម្ពុជា និងប្រឆាំងកម្ពុជាប្រជាធិបតេយ្យទៅទៀត អ្នកនោះត្រូវមានទោសពីព្រោះអ្នកនោះធ្វើសកម្មភាពក្បត់ដោយចេតនា ដោយគោលជំហរប្រឆាំងដាច់ខាត ដោយគោលជំហរពេញចិត្តពេញថ្លើមបម្រើខ្មាំងសត្រូវជាសេ.អ៊ី.អា ឬជាយួន ជាកា.ហ្សេ.បេ ។ អ្នកនោះគេបែងចែកព្រំដែនរបស់គេច្បាស់ហើយ ដូច្នេះបក្សកុម្មុយនិស្តកម្ពុជាត្រូវតែកម្ចាត់ ។

ប្រភេទទី២: ចំពោះបុគ្គលណាដែលឈប់ធ្វើសកម្មភាពក្បត់ចាប់ពីខែ៧-១៩៧៨នេះតទៅ ហើយខិតខំកែប្រែខិតខំ

បំពេញភារកិច្ចបដិវត្ត អ្នកនោះមិនមានទោសពៃរ៍ទេ ។ គោលនយោបាយរបស់បក្សគឺកសាងទាំងអស់ដែលអាចកសាងបាន ហើយបក្សនិងប្រជាជនខំកសាងអ្នកដែលភ័ន្តច្រឡំឱយទៅជាសាច់ឈាមល្អរបស់ខ្លួន ហើយល្អជារៀងរហូត ដើម្បីរួមកម្លាំងការពារប្រទេសកសាងប្រទេសនិងលោកស្ទួយជីវភាពប្រជាជនឱយបានរីកចំរើនឆាប់រហ័សណាស់ ហើយឈានទៅសំបូរសប្បាយគ្រប់ផ្នែក ។

សូម្បីតែអ្នកដែលធ្វើសកម្មភាពប្រឆាំងក៏បក្សបែងចែកជាច្រើនប្រភេទទៀតៈ





ប្រភេទទី១ៈ ធ្វើសកម្មភាពប្រឆាំងដាច់ខាតជាខ្មែរសន្ធាក់ដោយអំពើប្រព្រឹត្តជាក់ស្តែងបន្តបន្ទាប់ ។

ប្រភេទទី២ៈអ្នកដែលគ្រាន់តែធ្វើសកម្មភាពប្រឆាំងខ្លះៗដោយរួមសកម្មភាពតាមពួកប្រភេទទី១វាណែនាំ ។

ប្រភេទទី៣ៈអ្នកដែលគ្រាន់តែចេញជាពាក្យសម្តីវាយប្រហារ ឆ្លឺះឆ្លៀល ញុះញង់ បំបែកបំបាក់ តាមការណែនាំរបស់ពួកប្រភេទទី១និងតាមការឃោសនារបស់វា ។

ប្រភេទទី៤ៈ ពួកដែលគ្រាន់តែគេអូសទាញឃោសនា ហើយដែលគេគ្រាន់តែកត់ឈ្មោះថាចូលសេ.អ៊ី.អា ថាចូលនេះចូលនោះជាមួយគេ ដោយយល់ដឹង ដោយមិនយល់ដឹង ។

ចំពោះប្រភេទទី២ ប្រភេទទី៣ ប្រភេទទី៤ បក្សមាននយោបាយអប់រំនិងកសាងឱយភ្ញាក់រឭកមកនៅខាងបក្សបដិវត្តនិងប្រជាជនវិញ ។

អ្នកដែលនៅក្នុងប្រភេទទី៤ បក្សកំណត់ថាមិនមានទោសពៃរ៍ទេ ដោយការភ័ន្តច្រឡំតាមការឃោសនារបស់ពួកប្រភេទទី១វាបំភ័ន្ត ។ ដូច្នេះអ្នកទាំងនោះត្រូវខិតខំកសាងខ្លួនឱយជ្រះស្រឡះ ហើយឈរខាងបក្សខាងបដិវត្តខាងប្រជាជនបំពេញភារកិច្ចឱយល្អ ហើយប្រឆាំងនិងពួកក្បត់វិញ ។ បក្សនិងប្រជាជនយកចិត្តទុកដាក់អប់រំកសាងអ្នកភ័ន្តច្រឡំទាំងនេះឱយបានទៅជាអ្នកស្អាតស្អំ និងជាជនបដិវត្តល្អ ។

ចំពោះអ្នកដែលនៅក្នុងប្រភេទទី៣និងទី២ ក៏ដូច្នេះដែរ អ្នកទាំងនេះត្រូវខិតខំកសាងខ្លួនឡើងវិញ ឱយជ្រះស្រឡះដើម្បីខ្លួនឯងជ្រះថ្លាកសាងខ្លួនឱយបានប្រសើរឡើងវិញ ។

សុំបញ្ជាក់ថា ចំពោះអ្នកដែលនៅក្នុងប្រភេទទី១ក៏ដោយ ក៏បក្សមាននយោបាយអប់រំកសាងគេឱយអស់លទ្ធភាពដែលអាចកសាងបានឱយគេកម្ចាត់ចោលនូវការភ័ន្តច្រឡំឱយគេភ្ញាក់រឭកមកនៅខាងបក្សបដិវត្តនិងប្រជាជនកម្ពុជាយើងវិញ ។ លើកលែងតែពួកដាច់ខាតប្រឆាំងបក្ស បដិវត្តប្រជាជននិងកម្ពុជាប្រជាធិបតេយ្យប្រឆាំងជាខ្មែរសន្ធាក់ជាបន្តបន្ទាប់មិនព្រមកែប្រែមិនសុខចិត្តរស់នៅជាមួយបក្សបដិវត្តនិងប្រជាជនកម្ពុជា ហើយដាច់ខាតលូនក្បាលទៅបម្រើយួនឈ្លានពានវាតទីលេបទឹកដីវាតទីនិយមសូវៀតនិងបក្សពួកចក្រពត្តិអាមេរិក និងបរិវារ បក្សនិងប្រជាជនកម្ពុជាត្រូវតែកម្ចាត់ ។

បក្សអំពាវនាវឱយអ្នកភ័ន្តច្រឡំទាំងអស់ឱយមកចូលរួមចិត្តរួមថ្លើមជាមួយប្រជាជាតិនិងប្រជាជនយើងវិញ ការពារប្រទេស កសាងប្រទេស និងលើកស្ទួយជីវភាពប្រជាជនបានរីកចំរើនឆាប់រហ័ស ហើយឈានទៅសំបូរសប្បាយគ្រប់ផ្នែក ។

**(ឯកសារ D21228 )**

# ជុំ ម៉ាញៈ អ្នកទោសគុកទួលស្លែងដែលនៅមានជីវិត

លោកតា ជុំ ម៉ាញ ហៅ ម៉ី និងភរិយាតែងតែទៅវត្តអារាមជាមួយគ្នា ប៉ុន្តែចាប់តាំងពីឆ្នាំ១៩៧៩មក លោកតាមិនអាចទៀតទេ ដោយសារភរិយារបស់គាត់ត្រូវខ្មែរក្រហមបាញ់សម្លាប់ ។ លោកតា ជុំ ម៉ាញ ជាអ្នកទោសគុកទួលស្លែងម្នាក់ដែលនៅមានជីវិត ។ គាត់ប្រាប់ថា ពេលភ្ជុំបិណ្ឌជាពេលដែលគាត់នឹកដល់ភរិយាខ្លាំងជាងធម្មតា ហើយឆ្នាំនេះគាត់កន្ទុងទៅនេះ ។

លោកតាបានបួងសួងដោយមានភក្តីភាពស្មោះស្ម័គ្រ ប៉ុន្តែនៅក្នុងជម្រៅចិត្តមួយដែលនៅតែភ័យខ្លាចខ្មែរក្រហម ។ គាត់ធ្លាប់ត្រូវបានខ្មែរក្រហមធ្វើទារុណកម្ម ហើយឥឡូវត្រូវបន្តទទួលទារុណកម្មទៀត ដោយគាត់យល់ថាខ្មែរក្រហមអាចនឹងសម្លាប់គាត់បំបិទមាត់កុំឲ្យនិយាយពីការទាក់ទងរបស់មេដឹកនាំខ្មែរក្រហម



ជុំ ម៉ាញ

បានបួងសួងសុំឲ្យព្រលឹងភរិយាគាត់បានស្ងប់និងបានទៅកាន់សុគតិភពទៅចុះ ដ្បិតអីមេដឹកនាំអ្នកដែលសម្លាប់ភរិយាគាត់នោះនឹងត្រូវតុលាការរកខុសត្រូវឲ្យហើយ ។ តាមពិតទៅគាត់អាចបួងសួងបែបនេះបាន ហើយព្រលឹងភរិយាអាចទៅកាន់សុគតិភពបាន អាស្រ័យលើភាពឆាប់រហ័សនៃដំណើរការរៀបចំតុលាការខ្មែរក្រហម ដែលច្បាប់ត្រូវបានសម្តេចព្រះនរោត្តម សីហនុឡាយព្រះហស្តលេខាកាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ថ្មីៗទៅនឹងគុកទួលស្លែង ។ គាត់យល់ថា ខ្មែរក្រហមមិនទាន់អស់នៅឡើយទេ ។ គាត់សួរថា តើត្រូវធ្វើយ៉ាងម៉េចនៅពេលដែលសាធារណជនស្គាល់គាត់ច្រើនហើយអាចនឹងមានគ្រោះថ្នាក់ដល់ជីវិតនោះ ។ “ខ្ញុំនិយាយប្រាប់ក្មួយដោយយល់ថា ក្មួយនិយាយថែរក្សាប្រវត្តិសាស្ត្រនិងនិយាយការពិតប្រាប់មេដឹកនាំក្រោយៗពីអ្វីដែលមានការខុសឆ្គង ហើយកុំឲ្យធ្វើដូចនោះទៀត” ។

លោកតា ជុំ ម៉ាញ កើតនៅឆ្នាំ១៩៣៣ ក្នុងខេត្តព្រៃវែង ។

គាត់កំព្រាឪពុកម្តាយតាំងពីនៅក្មេង ។ គាត់បានរៀនអក្សរបន្តិចបន្តួចនៅវត្តអារាមតែប៉ុណ្ណោះ ។ គាត់បានប្រកបរបរជាជាងឡាននិងគ្រឿងអគ្គិសនីគឺដែលជាជំនាញមួយ បានជួយជីវិតហើយនិងបានធ្វើទារុណកម្មដល់គាត់ផងនៅក្នុងរបបខ្មែរក្រហម ។

ខែមេសាឆ្នាំ១៩៧៥ លោកតា ជុំ ម៉ាញ និងគ្រួសារត្រូវជម្លៀសចេញពីក្រុងភ្នំពេញ ។ ផ្លូវជាតិលេខ៥មានមនុស្សច្រើនកកកុញ ។ ពីព្រលឹមទល់ព្រលប់ គាត់ដើរទៅមុខបានតែប្រហែល ២គីឡូម៉ែតពីកប់ស្រូវដល់ព្រែកព្នៅ ។ លោកតាព្រមទាំងគ្រួសារសម្រាកនៅតាមផ្លូវក្បែរមាត់ទន្លេ ជិតសាកសពដែលទើបស្លាប់ថ្មីៗ ។ គាត់ឃើញមានសាកសពនៅពាសពេញលើថ្នល់មនុស្សម្នាដើរជាន់ពីលើសាកសពនៅលើច្រាំង និងអណ្តែតក្នុងទឹក ។ គាត់យល់ថា អ្នកស្លាប់ទាំងនោះពិតជាបានតវ៉ាជាមួយខ្មែរក្រហមមិនព្រមចាកចេញពីផ្ទះ ។

អស់រយៈពេល១០ថ្ងៃទើបក្រុមគ្រួសាររបស់គាត់មកដល់ព្រែកក្តាម ។ គាត់បានឮអង្គការប្រកាសថាត្រូវការមនុស្សដែលមានជំនាញផ្សេងៗក្នុងនោះមានជំនាញជាងឡាននិងគ្រឿងអគ្គីសនីដូចគាត់ដែរ ។ គាត់បានឮនៅពេលដែលគ្រួសារគាត់ឈប់សម្រាក ហើយគាត់កំពុងដើររកថ្នាំមកឲ្យភរិយាដែលគ្រុនសន្ធំ ។ ភរិយានិងកូនៗរបស់លោកតា ជុំ ម៉ាញ ត្រូវអង្គការមិនអនុញ្ញាតឲ្យមកភ្នំពេញវិញជាមួយគាត់ទេ ។ ភរិយានិងកូនៗត្រូវទុកឲ្យនៅព្រែកក្តាមចម្ងាយប្រហែល៣០គីឡូម៉ែតពីក្បែរមាត់ទន្លេ ស្រុកឬស្សីកែវ ។ លោកតា ជុំ ម៉ាញ ត្រូវមកធ្វើកប៉ាល់នៅទីនោះរយៈពេល៣ខែ ។ ក្រោយបន្តិចមក ភរិយានិងកូនៗរបស់គាត់ត្រូវបានអនុញ្ញាតឲ្យមកនៅច្រាំងចំរេះជិតឫស្សីកែវនេះដែរ ។ លោកតាជួសជុលកប៉ាល់យកម៉ាស៊ីនឡានមកច្នៃធ្វើកប៉ាល់បានចំនួន៣០គ្រឿង ដែលអង្គការយកទៅដឹកទាហានខ្មែរក្រហមទៅទិសខាងជើង(ប្រហែលជាឆ្ពោះទៅខេត្តក្រចេះ) ។

លោកតាត្រូវបានចាត់តាំងឲ្យប្រមូលនិងជួសជុលគ្រឿងម៉ាស៊ីននិងអេឡិចត្រូនិចដូចជា ត្រាក់ទ័រ ឡាន មីក្រូហ្វូន មួយរយៈតូចនៅផ្សារអូរឫស្សីនៃក្រសួងកាត់ដេររដ្ឋ ដែលរហូតក្រោយមកទៀតលោកតាជួសជុលឡាននិងម៉ាស៊ីនដេរ ។ លោកតាបានមានប្រសាសន៍ថា មានពេលមួយនោះ គណៈប្រតិភូចិនមកថតខ្សែពានម៉ាស៊ីនដេរនិងម៉ាស៊ីនកាត់ដែលគាត់បានច្នៃយកទៅប្រទេសចិនធ្វើជាហ្វីលឯកសារ ។ ពេលនោះភរិយានិងកូនម្នាក់នៅធ្វើការកាត់ដេរនៅផ្សារអូរឫស្សីជាមួយគ្នា ហើយកូនរបស់លោកតាម្នាក់ទៀត នៅមន្ទីរកុមារផ្សារដើមគ ។ គណៈក្រសួងកាត់ដេរឈ្មោះ គុន ធាត់ហើយសម្បុរស ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជានាខែមេសា ឆ្នាំ១៩៧៦ បានចាត់តាំងឈ្មោះ គុន ជាសមាជិក គណៈកម្មការក្រសួងកាត់ដេររដ្ឋ ។ លោកតា ជុំ ម៉ាញ បន្តថា ក្រោយមក តាគុន ត្រូវចាប់ខ្លួនដោយចោទថាជាប់ពាក់ព័ន្ធនឹងផែនការពួកបូព៌ា ។ លោកតានៅចាំថា ប្រហែលខែសីហា ឆ្នាំ១៩៧៨ ខៀវ សំផន បានមកពិនិត្យចង្ក្រានរួមដែលគាត់បានធ្វើ ។ លោកតាពន្យល់ថា ចង្ក្រាននោះ តដោយបំពង់មួយ ហើយដុតអុសតែមួយកន្លែងទេ ប៉ុន្តែអាចដាំបាយឆ្អិនគ្រប់ឆ្នាំង ។ មានពេលមួយនោះ លោកតាបានរៀនវគ្គនយោបាយខុទ្ទេសនាមដោយសមមិត្ត នួន ជា នៅបូរីកីឡាទៀតផង ។

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៨ លោកតាជុំ ម៉ាញ ត្រូវបានអង្គការចាប់ខ្លួនមកដាក់នៅគុកទួលស្លែង ឬមន្ទីរស-២១ ។ នាល្ងាចមួយមានសមមិត្តម្នាក់មកប្រាប់លោកតាថា “អង្គការត្រូវការមិត្តទៅជួសជុលឡានដើម្បីវាយវៀតណាម ព្រឹកឡើងសមមិត្តនោះមកទទួលខ្ញុំជិះឡានឡាំប្រឺតាទៅ ។” នៅពេលលោកតាត្រូវចាប់ខ្លួននោះ ប្រពន្ធរបស់គាត់កំពុងមានផ្ទៃពោះ ។ តាមដែលលោកតាឃើញទួលស្លែងគឺជាកន្លែងហាមឃាត់ មានស័ង្កសីព័ទ្ធជុំវិញ ពីមហាវិថីព្រះសីហនុដល់មហាវិថីម៉ៅសេទុងពីមហាវិថីព្រះមុនីវង្សដល់ផ្លូវលេខ១៦៣ ។ នៅពេលមកដល់ទួលស្លែង លោកតាត្រូវអូសចុះពីឡាន ហើយរុំមុខដោយក្រមាររបស់គាត់ ។ លោកតាបានឆ្លៀតផ្តាំថា “ទៅប្រាប់ប្រពន្ធខ្ញុំផង ថាខ្ញុំប្រហែលមិនរស់ទេ” ។ ពេលនោះគាត់ត្រូវធាក់មួយជើងដួលផ្កាប់មុខងើបមិនរួចដោយសារជាប់ចំណងស្លាបសេក ។ គាត់ត្រូវបានបណ្តើរទៅទាំងដៃជាប់ចំណង ដោះខោអាវ វាស់កម្ពស់ រួចថតរូប ។ ទៅដល់បន្ទប់ឃុំឃាំង លោកតាត្រូវបានដាក់ខ្នោះជើង រួចស្រាយចំណងដៃស្រាយក្រមារុំមុខ ហើយមានសល់តែខោក្នុងមួយជាប់ខ្លួនតែប៉ុណ្ណោះ ។ លោកតា ជុំ ម៉ាញ ត្រូវជាប់ខ្នោះរហូត ។

មានបីដុងទឹកសម្រាប់នោម និងកេសគ្រាប់សម្រាប់ដាក់លាមក ហើយនៅពេលផ្លូតទឹកលោកតាត្រូវដោះខោលើកឲ្យខ្ពស់ ហើយសន្តិសុខម្នាក់មកជះទឹកពីលើ ។ លោកតាមានប្រសាសន៍ថា ពេលណាគាត់នឹកឃើញរឿងខ្មោះនិងកេសគ្រាប់នោះ គាត់ទប់ទឹកភ្នែកមិនបានទេ។ លោកតាត្រូវសមមិត្ត ទិត, សមមិត្ត ហ៊ីរ និង សមមិត្ត សេង វាយសួរចម្លើយ ។ ថ្ងៃមួយ ហ៊ីរ ចូលមកជួនពេល សេង កំពុងវាយលោកតា ។ សេង រាយការណ៍ប្រាប់ ហ៊ីរ ថា «បងមើលវា វាយប៉ុណ្ណឹងហើយ វាមិនព្រមឆ្លើយទៀត» ។ ហ៊ីរ បានវាយបន្តរហូតលោកតា ជុំ ម៉ាញ បាក់ម្រាមដៃមួយរហូតដល់សព្វថ្ងៃ។ សេង ស្រែកគំរាមថា «ឯងមានផ្លូវពីរ មួយស្លាប់ បើមិនប្រាប់មួយអាចរស់បើប្រាប់។ អង្គការមិនដែលចាប់នរណាខុសទេ» ។ លោកតាត្រូវសារភាពពីខ្សែសេ.អ៊ី.អា ឬកា.ហ្សេ.បេ សូម្បីតែគាត់មិនដឹងទាំងពាក្យនោះមានន័យថាម៉េចក៏ដោយ ។ ចុងក្រោយមក លោកតានៅចាំបានថា គាត់បានប្រឌិតរឿងយ៉ាងណាឲ្យតែអាចពន្យារពេលការវាយដំនិងសេចក្តីស្លាប់ ។ បើមិនអ៊ីចឹងទេគាត់យល់ថា គាត់ពិតជាស្លាប់ឆាប់ៗ ។ ពេលខ្លះលោកតាគិតថាចង់លោតឲ្យស្លាប់តែម្តង ជាជាងទ្រាំទ្រការវាយដំ ។

ក្រោយមកទៀត ជំនាញជាងរបស់លោកតា ជុំ ម៉ាញ បានជួយដល់ជីវិតគាត់ ។ គាត់ត្រូវបានដោះខ្នោះ ឲ្យស្លៀកពាក់ខោអាវនិងបានអាហារហូបគ្រប់គ្រាន់ ដោយសារគាត់ត្រូវបានឲ្យមកជួសជុលម៉ាស៊ីនដេរ និងព្រមទាំងបង្រៀនជំនាញនេះដល់បណ្តាសមមិត្តនៅក្នុងគុកទួលស្លែងដែលនោះ ។ លោកតាបានជួបអ្នកទោសម្នាក់ទៀតគឺ អ៊ឹង ប៉ិច ។ លោកតា ជុំ ម៉ាញ និង អ៊ឹង ប៉ិច ហ៊ានត្រឹមតែលួចញញឹមដាក់គ្នា ហើយពេលខ្លះលួចឲ្យអាហារគ្នាទៅវិញទៅមក ។ មានពេលមួយនោះគាត់បានឮសំឡេងជនជាតិស្បែកស ហើយបានឃើញស្ត្រីនិងក្មេងៗវៀតណាមក្នុងគុក ។



◆ អ្នកទោសដែលនៅមានជីវិតពីគុកទួលស្លែង (១៩៧៩)

សេង ដែលមានបញ្ជាក់នៅលើបញ្ជីសម្លាប់នៅគុកទួលស្លែង ជាអ្នកសួរចម្លើយលោកតា ជុំ ម៉ាញ ។ នៅលើចម្លើយសារភាពក៏មាន ឈ្មោះ សេង ដែលជាអ្នកបានសួរហើយចប់នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ បញ្ជីសម្លាប់នោះមានឈ្មោះ ជុំ ម៉ាញ ក្រោមចំណងជើងថា ឈ្មោះអ្នកទោសមកពីក្រសួងកាត់ដេររដ្ឋ ហើយមានចារអក្សរថា "ទុកសិន" ។

លោកតា ជុំ ម៉ាញ បន្តថា នៅទួលស្លែងគាត់ស្គាល់ ហ៊ុយ, ហ៊ីរ, ខន និង ឌុច ជាប្រធានធំ ។ ឯកសារដែលនៅសេសសល់បង្ហាញថា ហ៊ីរ បានសួរចម្លើយអ្នកទោសយ៉ាងហោចណាស់ ២២នាក់ ។ ទិត បានសួរចម្លើយអ្នកទោសយ៉ាងហោចណាស់ ៥៥នាក់ ហើយ សេង បានសួរចម្លើយអ្នកទោសយ៉ាងហោចណាស់១១២នាក់ ។

លោកតា ជុំ ម៉ាញ បានប្រាប់ថា ចម្លើយសារភាពនោះត្រូវប្រើពេលអស់១២ថ្ងៃ១២យប់ ។ សេង បានវាយគាត់រួចសួរបន្ទាប់មកវាយអង្គុលីលេខជាច្រើនលើកច្រើនសាទើបចប់ ។ នៅពេលដែលសួរគាត់ថាតើ សេង មានដែលសង្ស័យចំណុចមិនប្រក្រតីណាខ្លះនៃសកម្មភាពប្រឌិតនោះដែរឬទេ? លោកតា ពន្យល់ថា សេង ចង់បានតែសាច់រឿងមួយតែប៉ុណ្ណោះ រឿងយ៉ាងម៉េចក៏ដោយឲ្យតែទាក់ទងនឹងពាក្យថា សេ.អ៊ី.អា ឬ កា.ហ្សេ.បេ ។ លោកតាគិតថា សេង ទំនងដូចជាមិនជឿអ្វីដែលគាត់និយាយទេ ។ លោកតាបន្តថា សេង មិនអាចស្គាល់ឈ្មោះ ទាំងអស់ដែលដាក់ថា ខ្សែរក្បត់នោះឡើយ ។

លោកតាបញ្ជាក់ថា ផ្នែកដំបូងនៃចម្លើយសារភាពដែលនិយាយអំពីប្រវត្តិរបស់គាត់នោះគឺជាការពិតមែន ។ ផ្នែកនេះមានរៀបរាប់ពីឈ្មោះឪពុកម្តាយ បងប្អូន ថ្ងៃខែឆ្នាំកំណើតឈ្មោះវត្តដែលគាត់ទៅរៀន សាច់ញាតិដែលគាត់បានរស់នៅជាមួយ អ្នកបើកតាក់ស៊ី ថៅកែតាក់ស៊ីដែលគាត់បានធ្វើការជាមួយ ជាព្រូឡាន និងប្រាក់ខែដែលគាត់បានទទួល ។ ក្នុងចំណោមមនុស្ស៦៤នាក់ដែលមានក្នុងបញ្ជីខ្សែរក្បត់មានប្រហែល១០នាក់ប៉ុណ្ណោះដែលលោកតាបានប្រាប់ថា ជាឈ្មោះមនុស្សពិត ។ ករណីនេះក៏ដូចជាករណីចម្លើយសារភាពផ្សេងៗទៀតដែរ គឺឈ្មោះពិតច្រើនជាអ្នកដែលខ្មែរក្រហមបានចាប់ខ្លួនរួចមកហើយ ដូចជា គុន ដែលមាននិយាយខាងលើ ជុំ យ៉ុង វ៉ាន់ ដែលបានមក ជំនួស គុន រួចក៏ត្រូវចាប់បន្តបន្ទាប់ ព្រមទាំងសមមិត្ត ម៉ន ដែលជាប្រធាន កាលលោកតា ជុំ ម៉ាញ នៅជួសជុលកប៉ាល់ ។ ក្នុងករណីនេះជាទូទៅច្រើនមានជាការពិតក្នុងចម្លើយសារភាពដូចជា ឈ្មោះ តួនាទី ឬស្ថាប័ន ដែលមានមនុស្សស្គាល់ច្រើនដូចជាមន្ទីរ ម-១១និងមន្ទីរគ-៩ ដែលមានក្នុងចម្លើយសារភាព ត្រូវបានលោកតាបញ្ជាក់ថាមានពិត ។ គាត់បន្ថែមថា "ម" តំណាងឲ្យ ឈ្មោះ ម៉ន ប្រធានក្រសួងដឹកជញ្ជូនជើងទឹក ហើយ "គ" តំណាងឲ្យឈ្មោះ គុន ប្រធានក្រសួងកាត់ដេររដ្ឋ ។


ជុំ ម៉ាញ

នៅចុងទំព័រទី២នៃចម្លើយសារភាពសរសេរថា អ្នកបើកឡានតាក់ស៊ីនោះបានប្រាប់លោកតា ជុំ ម៉ាញ ឲ្យអូសទាញអ្នកស្គាល់ទាំងអស់កុំឲ្យចូលកុម្មុយនិស្ត ហើយជួយការពាររបបសេរី ធ្វើដូចនេះលោកតានឹងបានឡើងប្រាក់ខែ ។ លោកតាថា ផ្នែកនេះនិងផ្នែកបន្តបន្ទាប់សុទ្ធតែមិនពិតទាំងអស់ ។ លោកតាថា ដល់កន្លែងហ្នឹងគឺទៅមុខសុទ្ធតែមិនពិតទាំងអស់ ព្រោះដល់ពេលដែលខ្មែរក្រហមវាយគាត់កាន់តែខ្លាំង ។ ចម្លើយសារភាពផ្នែកបន្តមកទៀត មានសរសេរថា ថៅកែតាក់ស៊ីបានឲ្យលោកតាស្បថចំពោះមុខទង់ មានផ្កាយច្រើន ដែលជាទង់ជាតិអាមេរិក តំណាងឲ្យលោកសេរីនិងឲ្យបម្រើសេ.អ៊ី.អា អស់មួយជីវិត ។ ផ្នែកបន្តបន្ទាប់ភាគច្រើនក៏មិនពិត ត្រង់ថានៅគ្រប់កន្លែងការងារ កន្លែងរស់នៅ លោកតាតែងបានរៀបចំផែនការប្រជុំខ្សែរក្បត់កសាងខ្សែរក្បត់ជាដើម ។

នៅពេលដែលកងទ័ពវៀតណាមចូលមកដល់ភ្នំពេញនៅឆ្នាំ ១៩៧៩ លោកតា ជុំ ម៉ាញ ព្រមទាំងអ្នកទោសនិងកម្មាភិបាលគុកបានរត់ទៅទិសខាងលិចកាត់តាមព្រៃសដែលមានក្លិនស្អុយអសោច ដោយសារអ្នកទោសជាច្រើនត្រូវបានសម្លាប់នៅម្តុំនោះ ។

ពេលរត់ឆ្លងកាត់តាមព្រៃស លោកតាមិនបានដឹងថា ភរិយាគាត់បានជាប់គុកនៅព្រៃសនោះឡើយ រហូតដល់ពេលដែលគាត់បានជួបភរិយានិងកូនពៅរបស់គាត់នៅតាមផ្លូវជាតិលេខ៤ ទើបដឹងរឿងរ៉ាវនេះ ។


ផន ថនចាន់

ចំណែកកូនពីរនាក់របស់គាត់ទៀតត្រូវបញ្ជូនទៅពោធិសាត់តាមរថភ្លើងជាមួយប្រជាជនដែលត្រូវបញ្ជូនមកពីភូមិភាគបូព៌ា ។ នៅពេលយប់ឈប់សម្រាកនៅវត្តស្រះធុល ភរិយាព្រមទាំងកូនតូចបីជាប់ដៃ ត្រូវបានខ្មែរក្រហមហៅយកទៅបាញ់សម្លាប់មុនគេ ។ សំឡេងភរិយាជាចុងក្រោយដែលលោកតា ជុំ ម៉ាញ ចាំជានិច្ចនោះគឺ "រត់ប៉ាវ៉ា រត់ប៉ាវ៉ា គេបាញ់ខ្ញុំហើយ" ។ សំឡេងនេះបានព្រួប្រណាំងគ្នានឹងស្នូរគ្រាប់កាំភ្លើង ។ លោកតា ជុំ ម៉ាញ បានរត់គេចរួចខ្លួន ហើយបាននាំយកស្រមោលភរិយាក្នុងចិត្តជាប់ជានិច្ច ជាពិសេសគឺនៅពេលភ្ជុំបិណ្ឌនេះឯង ជាពេលដែលលោកតាធ្លាប់ជួបជុំគ្រួសាររស់នៅយ៉ាងសុខដុមរមនា ។

បច្ចុប្បន្ននេះ លោកតា ជុំ ម៉ាញ នៅតែប្រកបរបរជាជាងឡានដដែល ។ គាត់បានតាមដានគ្រប់ពត៌មានដែលទាក់ទងរឿងខ្មែរក្រហម ។ លោកតា ជុំ ម៉ាញ ជាអតីតអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសគុកទួលស្លែងទាំង១៤នាក់ ដែលតាមពត៌មានថានៅរស់រានមានជីវិតក្នុងឆ្នាំ១៩៧៩ ។ លោកតា ជុំ ម៉ាញ និងអតីតអ្នកទោសពីរនាក់ទៀត នៅរស់ដល់សព្វថ្ងៃគឺឈ្មោះ វ៉ាន់ ណាត និងឈ្មោះ ផន ថនចាន់ ។ ចំណែកឈ្មោះ រុយ នាគង់, ប៊ូ ម៉េង, អ៊ីង ប៉ិច, អៀម ចាន់, និង ឌី ផុន បានស្លាប់បាត់ទៅហើយ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតាមរកអាសយដ្ឋានពិតប្រាកដនិងសម្ភាសអ្នកទោសផ្សេងទៀត ។ អ្នកទោសសរុបជិត២០០០០នាក់ត្រូវបានស្លាប់នៅគុកទួលស្លែង ។ លោតា ជុំ ម៉ាញ ធ្លាប់បានស្បថថា បើនរណាជួយគាត់ឲ្យរួចផុតពីគុកទួលស្លែង គាត់នឹងកោរសក់លាបំណន់ ។ រឿងមួយទៀតចំពោះអ្នកដែលគាត់ចេះតែឆ្លើយដាក់ ហើយអាចចំលើមនុស្សពិតណាមួយនោះ គាត់សុំបួងសួងឲ្យអហោសិកម្មផង ។ លោកតាបានសួរថា ចំពោះគាត់ដែលត្រូវខ្មែរក្រហមធ្វើទារុណកម្ម តើអង្គការសិទ្ធិមនុស្សឬអង្គការសហប្រជាជាតិ អាចជួយអ្វីខ្លះដល់គាត់?


ប៊ូ ម៉េង

នៅពេលដែលយុត្តិធម៌បើកទ្វារ តុលាការខ្មែរក្រហមធ្វើការងាររបស់ខ្លួន សំណួររបស់លោកតានឹងត្រូវឆ្លើយបានយ៉ាងពេញលេញ ។ លោកតាមានសិទ្ធិ សួរ ឆ្លើយ និយាយចេញមកបានច្រើន ហើយបានដូច ខៀវ សំផន ឬ នួន ជា ដែរ ។ លោកតាអាចសួរមេខ្មែរក្រហមពីអ្វីដែលពួកនេះបានប្រព្រឹត្តខុស ។ លោកតាអាចសួរបានក្នុងពេលដ៏ខ្លីខាងមុខ ។ ច្បាប់ខ្មែរក្រហមបានបញ្ជូនទៅអង្គការសហប្រជាជាតិរួចហើយដែរ ។ រដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ ត្រូវបានរំពឹងថានឹងពិភាក្សាលើចំណុចលម្អិតនៃច្បាប់និងចុះហត្ថលេខាលើអនុស្សរណៈនៃការព្រមព្រៀងមួយ ។ អ្នកវិភាគខ្លះយល់ថា ច្បាប់នេះផ្តល់នូវយុត្តិធម៌មួយតូចចង្អៀត ប៉ុន្តែអាចជាចំណុចផ្តើមនៃយុត្តិធម៌ទូលំទូលាយមួយ ដែលនឹងរកយុត្តិធម៌ជូនទាំងជនដៃដល់ ទាំងជនរងគ្រោះ ច្បាប់ខ្មែរក្រហមព្រមទាំងតុលាការ ដែលចេញពីច្បាប់នេះនឹងជួយលុបបំបាត់នូវភាពរួចទោស ហើយជាមូលដ្ឋានគ្រឹះដើម្បីកសាងវប្បធម៌នៃការគោរពច្បាប់ ព្រមទាំងដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចបានយ៉ាងរឹងមាំ ។

**សឹម សុរិយ៉ា**

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហមមកកាន់
**ទស្សនាវដ្តី"ស្វែងរកការពិត"**
ប្រអប់សំបុត្រលេខ ១១១០ភ្នំពេញ
ឬតាមទូរសារលេខ: (៨៥៥)(២៣)២១០៣៥៨

# មន្ទីរ ម-១៣ របស់ឌុច




កាំង ហ្គិចអៀវ ហៅ សមមិត្ត ឌុច បាននិយាយគំរាមដាក់អ្នកទោសរបស់ខ្លួនឈ្មោះ ហម អ៊ីន ដែលបានជាប់គុកនៅឆ្នាំ ១៩៧៣ ។ ពូអ៊ីន នៅចាំសម្តីរបស់ ឌុច នៅក្នុងចិត្តជានិច្ច ហើយបានស្រង់សម្តីរបស់ ឌុច ប្រាប់ខ្ញុំថា “តាអ៊ីន អ្ហា! គិតទៅមនុស្សឲ្យតែឆ្នាំមមី អត់ចៀសរួចពីគុកតែម្តង មើលគ្នាមុនជាប់គុកហ្នឹង មុនទំរាំបានម៉ោហ្នឹងជាប់គុកប៉ុន្មានឆ្នាំឯណោះ ដល់ឥឡូវហ្នឹងឃើញទេ តែគ្រាន់តែជាប់គុកមនុស្សឆ្នាំមមីកម្ររស់ អូ!អត់ចេះផាប់...” ។ ឌុច ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចេញបញ្ជានិងចាប់ខ្លួនកាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ ហើយបច្ចុប្បន្ននេះកំពុងស្ថិតនៅក្នុងមន្ទីរឃុំឃាំងរបស់តុលាការយោធា ដើម្បីរង់ចាំការកាត់ទោសពីតុលាការពិសេសមួយ ។

តើ ឌុច ដែលជាមនុស្សម្នាក់ធ្លាប់មានប្រវត្តិជាប់គុកជាច្រើនឆ្នាំ ហើយក្រោយមកនៅក្នុងឆ្នាំ១៩៧១ បានក្លាយជាប្រធានគុកមន្ទីរម-១៣ ក្នុងតំបន់រំដោះខ្មែរក្រហម និងបន្តតួនាទីជាប្រធានមន្ទីរស-២១ ក្នុងអំឡុងពេលដែលខ្មែរក្រហមកាន់កាប់អំណាច ហើយនាពេលបច្ចុប្បន្ននេះដែល ឌុច បានក្លាយខ្លួនជាជនជាប់ចោទ ហើយដែលកំពុងស្ថិតនៅក្នុងមន្ទីរឃុំឃាំងអាចនឹងមិនចេះស្លាប់ ឬអាចនឹងមិនត្រូវបានជាប់ទោស ដូចសម្តីគំរាមឲ្យអតីតអ្នកទោសរបស់ខ្លួនមែនដែរឬយ៉ាងណា? ពូ អ៊ីន កំពុងតែរង់ចាំមើលដោយអន្ទះសាណាស់ ។ កាំង ហ្កេចអៀវ ហៅ ឌុច និងឈ្មោះដែលមិត្តភក្តិហៅក្រៅថា “អាគៀវ” ធ្លាប់ជាប់គុកតាំងពីឆ្នាំ១៩៦៧ដល់ឆ្នាំ១៩៧០ ។ បន្ទាប់ពីនោះមក ឌុច បានរត់ចូលព្រៃដើម្បីបម្រើចលនាខ្មែរក្រហម ។ មូលហេតុដែលនាំឲ្យ ឌុច ជាប់គុក គឺដោយសារតែគាត់មានជាប់ពាក់ព័ន្ធទៅនឹងការបោះឆ្នោតបណ្តោយឃោសនាបម្រើខ្មែរក្រហម ។

ឌុច កើតនៅឆ្នាំ១៩៤២ ត្រូវនឹងឆ្នាំមមី ។ មនុស្សកើតឆ្នាំមមីរូបនេះ បានជួបប្រទះនូវបទពិសោធន៍នៅក្នុងគុក ហើយក៏បានដឹងច្បាស់អំពីការលំបាកនិងការឈឺចាប់ដែលជីវិតរស់នៅក្នុងគុករាប់ឆ្នាំ ។ នៅពេលដែលខ្លួនមានឱកាសបានធ្វើជាប្រធានគុកវិញនោះ បទពិសោធន៍ទាំងអម្បាលម៉ានត្រូវបានប្រមែប្រមូលនិងចម្រាញ់យកមកអនុវត្តចំពោះអ្នកទោសដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនម្តងវិញ ។ បទពិសោធន៍ទាំងនេះជំរុញឲ្យ ឌុច គិតថា ការដែលយកអំពើទារុណកម្មទៅអនុវត្តលើអ្នកទោសដើម្បីជម្រិតយកចម្លើយជួនកាលក៏មិនបានលទ្ធផលដែរ ។ ឌុច បានផ្លាស់ប្តូរវិធីសាស្ត្រមួយផ្សេងទៀតដែលខ្លួន




គិតថាមានប្រសិទ្ធភាព ។ ឌុច បានប្រើប្រាស់អ្នកទោសនៅក្នុងគុកដើម្បីឲ្យធ្វើជាអ្នកយកការណ៍ឲ្យខ្លួន ព្រោះគិតថាប្រហែលជាអ្នកទោសដូចគ្នាទើបហ៊ាននិយាយត្រង់ៗទៅវិញទៅមក ។ ពូអ៊ីន ដកស្រង់សម្តី ឌុច និយាយថា “អ៊ីន ឯងខ្ញុំថាលែងហើយ លែងឲ្យរួចហើយ តែតា អ៊ីន ឯងធ្វើភ្នាក់ងារក្នុងគុកឲ្យខ្ញុំ...” ។ នៅក្នុងអំឡុងឆ្នាំ១៩៧១ ឌុច បានធ្វើជាប្រធានគុកមន្ទីរម-១៣

នៅក្នុងភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ ពូ អ៊ីន បានមកជាប់គុកមន្ទីរម-១៣ របស់ ឌុច នៅខែមិថុនា ឆ្នាំ១៩៧៣ ។ ពូអ៊ីន រៀបរាប់អំពីទារុណកម្មជាច្រើនដែល ឌុច បញ្ជាឲ្យអ្នកនៅក្រោមបញ្ជារបស់ខ្លួនអនុវត្តទៅលើអ្នកទោសដែលជាប់ឃុំឃាំងនៅទីនោះ ។ ពូ អ៊ីន ក៏ធ្លាប់បានភ្លក្សរសជាតិនូវអំពីនេះ ហើយជួនកាលបានឃើញផ្ទាល់ភ្នែករបស់គាត់ទៀតផង ។ ទារុណកម្មទាំងនោះមានដូចជា÷ ១)ចងដៃទាំងពីររបស់អ្នកទោសទៅក្រោយដោយភ្ជាប់ខ្សែមួយព្យួរទៅលើ រួចហើយទាញខ្សែនោះឲ្យតឹងដើម្បីយោងខ្លួនអ្នកទោសទៅលើទុកឲ្យជើងទាំងពីរនៅទន្ទឹមគ្នាផុតពីដីពីម ៗ ២)បញ្ចូកទឹកសាប៊ូទៅក្នុងពោះអ្នកទោសរហូតដល់សន្លប់បាត់ស្មារតី ដោយប្រើទុយោស៊ីកចូលទៅក្នុងពោះតាមបំពង់ក ៣) យកចន្ទុះដែលកំពុងឆេះមកញល់ ក្បាលពោះអ្នកទោស ហើយពេលដែលដកចន្ទុះវិញធ្វើឲ្យកន្លែងដែលញល់នោះឡើងសស្កុសដោយសារតែស្បែករលាត់ចេញមកតាមចន្ទុះ ៤)យកក្រណាត់រុំជ័រចន្ទុះយកទៅដុតសម្រក់ជ័រក្តៅដាក់ពីលើរាងកាយអ្នកទោសចាប់ពីក្បាលរហូតដល់សព្វទាំងខ្លួនដែលមើលទៅសស្កុសគួរឲ្យព្រឺឆ្អឹងខ្នង ៥)យកអ្នកទោសទៅចងជាប់នឹងបង្គោល ហើយបាញ់ក្បាលអ្នកទោសបំបែកឲ្យខ្ទាតខួរនិងឈាមដាក់លើអ្នកទោសដទៃទៀតដែលអង្គុយជុំវិញ ៦)យកដែកស្រួចៗចាក់ចូលទៅក្នុងក្រចកដៃទាំងដប់របស់អ្នកទោស រួចហើយពេលដកដែកចេញភ្លាមក៏យកម្រាមដែលកំពុងចេញឈាមទៅជ្រលក់ក្នុងធុងទឹកនោម ។ ទាំងនេះពូ អ៊ីន មិនបានបញ្ចូលនូវអំពើផ្សេងទៀត ដូចជាអ្នកនៅក្រោមបង្គាប់របស់ ឌុច ដែលមានវ័យក្មេងៗបានយកចំពាមកៅស៊ូបាញ់ទៅលើអ្នកទោស ឬទាត់ធាក់អ្នកទោសដើម្បីជាការសើចលេងសប្បាយ ។ អំពើរំលោភបំពានទាំងនេះ ជួនកាលក្មេងទាំងនោះធ្វើនៅចំពោះមុខ ឌុច ផ្ទាល់ក៏មានដែរ ហើយ ឌុច ពុំដែលអើពើឬចាត់វិធានការអ្វីបន្តិចសោះចំពោះទង្វើរបស់ក្មេងៗទាំងនោះ ។ គុកមន្ទីរ ម-១៣ របស់ ឌុច ស្ថិតនៅក្បែរមាត់ស្ទឹងដែលអ្នកស្រុកតែងហៅកន្លែងនោះថា "ត្រពាំងប្រាប" ជាព្រៃស្ថិតនៅភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ អាចលិចលង់ដោយសារទឹកជំនន់ ។ មានម្តងនោះ គឺនៅចំពេលខែទឹកឡើងអ្នកទោសដែលនៅជាប់ក្នុងគុកក្រោមដីត្រូវបានស្លាប់យ៉ាងច្រើន ដោយមូលហេតុទឹកលិចលង់ចូលកន្លែងបរិវេណគុកនាពាក់កណ្តាលអាគ្រាត្រក្នុងឆ្នាំ១៩៧២ ។ ពូ អ៊ីន និយាយថា "កាលទឹកលិចហ្នឹង កាលណោះមានរឿងហេតុអីចេះដែរ ទឹកលិចងាប់មនុស្សអស់ច្រើនមែន...ចុះទឹកម៉ោ ម៉ាឆុរងាប់ហ្នឹងស្មានងាប់តិចណាស់..." ។ មីង ប៊ុត សៃ ដែលធ្លាប់ដើររកដីកទំពាំងនៅកន្លែងនោះ បាននិយាយរឿងរ៉ាវប្រាប់ខ្ញុំដូច តាអ៊ីន ដែរ ។ តាស៊ុម កាន់កាប់នៅសាខាក្រោម ឌុច បានឈ្លបសួរ ពូ អ៊ីន


ប៊ុត សៃ

ដើម្បីចង់ដឹងពត៌មានថា តើថាពេលទឹកលិចមកមានអ្នកទោសស្លាប់ប៉ុន្មាននាក់ ។ ពូ អ៊ីន និយាយថា "សាខា តាស៊ុម នេះរាយការណ៍ទៅគាត់ប្រធានដែរ តែក្រោមតា ឌុច ទេណាទៅដល់នោះ លែងសួរខ្ញុំដែរ បម្រុងឲ្យប៊ិក ឲ្យសៀវភៅឲ្យខ្ញុំរាយការណ៍ពីតាឌុច ខ្ញុំថា តាកុំធ្វើអីចឹងដឹរដល់គ្នាងាប់ដឹរមិនមែនងាប់ស្រមោចសង្ការទេតា កាលហ្នឹងលេងពួយអីចឹង មើលកាលទឹកសាយងាប់អស់ ប៉ុន្មានងាប់អស់មនុស្សច្រើនណាស់ណាឯងថា..." ។ មនុស្សត្រូវបានយកទៅសម្លាប់មានចំនួនច្រើនណាស់ ដែលតាមការប៉ាន់ស្មានរបស់ពូ អ៊ីន ថា មានមនុស្សចូលមកគុកមន្ទីរម-១៣ នេះ យ៉ាងហោចណាស់១០នាក់ដែរ ក្នុងអំឡុងពេលបីថ្ងៃ ។ ប្រសិនបើគិតតាមក្បួនទព្វន្ត ចំនួនមនុស្សស្លាប់នៅទីនោះអាចឈានដល់រាប់ម៉ឺននាក់ ចាប់រាប់ពីឆ្នាំ១៩៧១ ដល់ពាក់កណ្តាលខែមេសា ឆ្នាំ១៩៧៥ ។ មានអំពើឃោរឃៅពីរករណីដែល

ប្រព្រឹត្តដោយផ្ទាល់ដៃរបស់ ឌុច ដែលជាប្រធានគុកមន្ទីរម–១៣ ។ ករណីទី១គឺ ឌុច បានយកឈើរុំក្រណាត់ដោយជ័រចន្ទះកំពុងតែឆេះទៅញាល់លើក្បាលពោះអ្នកទោស និងករណីទី២ គឺ ឌុច ដុតចន្ទុះសម្រក់ជ័រដាក់អ្នកទោសបណ្ដាលឲ្យរលាកពេញខ្លួន ។ អ្នកទោសដែលទទួលរងនូវអំពើក្រោយនេះមានឈ្មោះថា សុន ។ អំពើឃោរឃៅទាំងនេះ មានបន្តទៅទៀតនៅមន្ទីរស–២១ (គុកទួលស្លែង) ចំពោះអ្នកទោសក្រោមការគ្រប់គ្រងរបស់ប្រធានគុក ឌុច ។ ដែនការប្រជុំផ្សេងៗ ជួនកាលត្រូវបានធ្វើឡើងនៅពេលយប់ ។ ពូអ៊ីន ធ្លាប់ពើបប្រទះជាញឹកញាប់ចំពោះការប្រជុំរបៀបនេះ ។ ពូអ៊ីន និយាយថា“ជួនកាលរត់ទៅចំប៉ះគ្នាគាត់ (ឌុច) ប្រជុំគាត់ថា អ្ហែង ម៉េចក៏ក្លាហានណាស់ តាអ៊ីន អ៊ីចឹងម៉េចក៏មិនយកកាស្សែតមកចតតែម្ដងទៅ” ។ ពូអ៊ីន តបនឹងសម្ដីរបស់ ឌុច ថា “អ៊ួតា! ខ្ញុំអត់ដឹងតាប្រជុំសុំទោស” ។ បញ្ជាទាំងអស់ត្រូវចេញពី ឌុច ។ ពូអ៊ីន និយាយថា“ជួនកាល តាឌុច បញ្ជាដាក់កំណត់អ៊ីចឹងតែម្ដងថា ឥឡូវត្រូវយកអ្នកនេះៗឲ្យក្មេងវ៉ៃម៉ាថ្ងៃពីរនាក់ តែអាម៉ាថ្ងៃពីរនាក់ហ្នឹង ខ្ញុំនៅហ្នឹងបានម៉ាខែ...” ។ ទាក់ទងទៅនឹងបញ្ជានេះដែរ យ៉ាងហោចណាស់មានឯកសារចំនួនពីរអាចបញ្ជាក់បន្ថែមឲ្យបានឃើញកាន់តែច្បាស់ ។ ឯកសារទាំងពីរនេះគឺសរសេរដោយផ្ទាល់ដៃរបស់ ឌុច ។ ឯកសារទី១ៈ បញ្ជីជនរងគ្រោះចំនួន១៨នាក់ ធ្វើឡើងដោយឈ្មោះ ហ៊ុយ នៅថ្ងៃទី៧ ខែមេសា ឆ្នាំ១៩៧៧ ។ មានខ្លឹមសារថា “ឈ្មោះដែលត្រូវដកៈគ្រួសាររបស់ អាសុខ និងអាម៉ៃ លន់” ឌុច បានចារជាលក្ខណៈបញ្ជាថា “**ស្មើសួរ៤នាក់ ក្រៅពីនេះវាយចោល**” ។ ចំណែកឯកសារមួយផ្សេងទៀតបង្ហាញឲ្យឃើញថា បញ្ជារបស់ ឌុច កាន់តែលេចចេញកាន់តែច្បាស់និងមានលក្ខណៈឃោរឃៅ ។ បញ្ជានេះគឺ យើងរាល់គ្នានឹកស្មានមិនដល់ទេ ហើយមានការខុសប្លែកគ្នាទាំងស្រុងទៅនឹងអ្វីដែល ឌុច បានផ្ដល់បទសម្ភាសន៍ពីមុនៗមក ។ ឯកសារជាបញ្ជីក្រោយនេះមានខ្លឹមសារថា “សង្ខេបរបស់អ្នកជាប់និន្នាការ” ហើយ ឌុច បានចារនៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៨ នៅផ្នែកកណ្ដាលនៃផ្ទៃក្រដាសបញ្ជីផ្នែកខាងក្រោមថា “**ពូប៉េង វាយចោលឲ្យម៉ត់**” ។ ជីវិតអ្នកទោសនៅក្នុងគុកមន្ទីរម–១៣ ហាក់ដូចជាស្ងាប់ផុយណាស់ សូម្បីតែកូនក្មេងអាយុប្រហែលបួនដប់ឆ្នាំក៏អាចសម្លាប់មនុស្សបានយ៉ាងជោគជ័យតាមសំណូមពររបស់បក្សដែរ ហើយប្រសិនបើធ្វើមិនបានទេ គឺត្រូវទិតៀនកសាងភ្លាម ។ ពូអ៊ីន និយាយថា “បើក្មេងៗឲ្យយកវ៉ៃឲ្យវ៉ៃចោលនៅក្នុងមន្ទីរហ្នឹងណា អត់ឲ្យវ៉ៃចោលឆ្ងាយទេ ឲ្យម៉ាថ្ងៃងាប់ពីរ បើមិនងាប់ពីរគេទិតៀនកសាងថាគេនៅសហករណ៍គេដាំដំឡូងមី មួយថ្ងៃបានហាសិបគុម្ពទៅមួយរយគុម្ពឯងគ្រាន់តែសម្លាប់ខ្មាំងគេឲ្យស្រេចៗឲ្យវ៉ៃប៉ុណ្ណឹង ឲ្យងាប់អត់នេះ អាណាដែលសួរអស់ចម្លើយអស់អី គេយកម៉ោដាក់ខ្មោះអ៊ីចឹងទៅឲ្យក្មេងៗវ៉ៃ ។ ក្មេងតូចៗអាយុប្រហែលដប់ឆ្នាំ ប្រាំពីរ, ប្រាំបី, ប្រាំបួន” ។ តាសុខ ជាប់នៅក្នុងគុកមន្ទីរម–១៣ របស់ ឌុច ជាមួយ


រណ្ដៅសាកសពនៅមន្ទីរម–១៣របស់ ឌុច

ពូអ៊ីន ដែរ ហើយត្រូវបាន ខន ដែលត្រូវជាចៅវាយធ្វើបាបនឹងញញួរឈើចំកណ្តាលដើមទ្រូងយ៉ាងឃោរឃៅ ដោយចោទថាខ្មាំង ។ ខន វាយរហូតទាល់តែ តាសុខ ហៅចៅរបស់គាត់ថា "បង" ។ ពូអ៊ីន និយាយគ្រាប់តាមសម្តីរបស់ ខន ថា "អើ! គេក្មេងមែនតែគេបងខាងបដិវត្តន៍" ។ នៅឆ្នាំ១៩៧៩ នៅពេលដែលត្រឡប់មកភូមិកំណើតវិញ ខន បានមកជួបតាសុខ ហើយលើកដៃសំពះតា សុខ ព្រមទាំងនិយាយ "ធ្វើម៉េចតា កាលណោះខ្ញុំអត់ដឹង ខ្ញុំនៅក្មេង" ។ កាលពីជំនាន់នោះ ក្មេងជំទង់ៗដែលមានអាយុប្រហែលពី១០ទៅ១៨ឆ្នាំ ត្រូវបានយកឲ្យទៅបម្រើការងារនៅកន្លែងរបស់ ឌុច ទាំងអស់ ។ ខ្ញុំបានធ្វើសម្ភាសន៍អ្នកស្រុកនៅទីនោះបានឲ្យដឹងថា ឈ្មោះ ខែល គុន (កូន អ៊ីស្រី ញ៉ាំង យី) បេ (កូនរបស់អ៊ីស្រី ហែម) គីម អុន (កូនអ៊ីស្រី ដួង នួច) ជ៉ោ កាក់ (ក្មួយលោកតា សី ជា) ហែម បឿន (កូនលោកយាយ សឹម) និង ឈ្មោះ អឿន (កូនយាយ យក់) ត្រូវបានបំបែកចេញពីគ្រួសារទាំងវ័យក្មេងនៅឡើយ ។ អ្នកធ្វើការនៅកន្លែងមន្ទីរម-១៣របស់ ឌុច ជាអ្នកមកចាប់ក្មេងទាំងនោះយកទៅ ។ មួយថ្ងៃៗ អ៊ីៗទាំងអស់ទន្ទឹងរង់ចាំតែដំណឹងកូនចៅរបស់គាត់ត្រឡប់មករកគាត់វិញ ដូចប្រធានគុក ឌុច ដែលកំពុងតែរង់ចាំតុលាការកាត់ទោសខ្លួនអីចឹងដែរ ។

តើអាចរួចខ្លួនពីការជាប់គុកបន្តទៅទៀតដែរឬទេចំពោះមនុស្សកើតឆ្នាំមមីដូចរូប ឌុច? ឌុច ធ្លាប់ជាប់គុកច្រើនពេករហូតដល់ខ្លួនឯងអាចចំណាំបានថា ឲ្យតែអ្នកណាកើតឆ្នាំមមីដូចខ្លួនគាត់ច្រើនតែជាប់គុក ។ ឌុច ហ៊ានធ្វើការអះអាងយ៉ាងដូច្នេះដោយគាត់មើលឃើញតែករណីរបស់គាត់និងករណីរបស់ពូ អ៊ីន តែពីរនាក់ប៉ុណ្ណោះ ។ គុករបស់ ឌុច ដែលអ្នកស្រុកអ្នកភូមិអមលាំងដឹងឮស្ទើរគ្រប់ៗគ្នាថា មន្ទីរ ម-១៣ ត្រពាំងច្រាបត្រូវបានរុះរើ ហើយផ្លាស់មកនៅភ្នំពេញវិញកាលពីឆ្នាំ១៩៧៥ គឺនៅចំពេលដែលទីក្រុងភ្នំពេញត្រូវវាយយកបានទាំងស្រុងដោយខ្មែរក្រហម ។ ពូ អ៊ីន រៀបរាប់ពីការរុះរើមន្ទីរនេះថា "តែខ្ញុំទៅហ្នឹងគេអត់ទាន់រើទេ តែខ្ញុំដឹងថាសភាពការណ៍ត្រូវរើហើយ ព្រោះសភាពការណ៍គេត្រូវទៅកាន់ភ្នំពេញនោះ ព្រោះខ្ញុំឮគាត់និយាយគ្នា គាត់ថា ត្រៀមហ្នឹងទៅកាន់នៅភ្នំពេញនៅគេ-៣ ។ "ខ្ញុំពេលនោះឮគេ គេគ្រាន់តែនិយាយម៉ោឲ្យកងការពារគេឮ ហើយកងការពារហ្នឹងដើរជាមួយខ្ញុំ ។ ចំណែកឯកអ្នកទោសត្រូវបានសម្លាប់យ៉ាងរន្ធាលក្នុងអំឡុងពេលនៃការរើផ្លាស់ប្តូរគុកមន្ទីរ ម-១៣ របស់ ឌុច មកកាន់ភ្នំពេញ បន្ទាប់ពីទីក្រុងនេះត្រូវបានកាន់កាប់ដោយពួកខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ កងការពារវ័យក្មេងនៅទីនោះមានសេចក្តីរីករាយណាស់ដោយបានទទួលដំណឹងថានឹងត្រូវផ្លាស់មន្ទីរទៅក្រុងភ្នំពេញវិញ ។ អ្នកខ្លះដឹងថា គុកមន្ទីរម-១៣នេះ ត្រូវរើទៅតាំងនៅគេ-៣ទីក្រុងភ្នំពេញ រីឯមួយចំនួនទៀតគ្រាន់តែដឹងថាត្រូវរើមកភ្នំពេញប៉ុណ្ណោះ ។ ពូ អ៊ីន និយាយថា "...ឮថាគេទៅឮក្មេងកងការពារ ខ្លះគេថាទៅគេ-៣ ខ្លះថាទៅភ្នំពេញអីចឹងទៅគេអរលាន់ពុទ្ធោអីចឹងទៅឃើញគេអរ" ។ ចំពោះអ្នកទោសដែលនៅសេសសល់ទាំងអម្បាលម៉ាន ត្រូវបានបញ្ឆោតឲ្យជីករណ្តៅសម្រាប់កប់ខ្លួនដោយមិនដឹងខ្លួន ។ ពូ អ៊ីន ប្រាប់ថា "ខ្ញុំពេលនោះឮគេ គេគ្រាន់តែនិយាយម៉ោឲ្យកងការពារគេឮ ហើយកងការពារហ្នឹងដើរជាមួយខ្ញុំ ។ គេនិយាយថាពេលនេះ កន្លែងនេះគេរំសាយហើយ ឯអ្នកទោសហ្នឹងគេផ្លាស់ឲ្យកាប់រណ្តៅកប់ខ្លួនឯង គេឲ្យកាប់រណ្តៅកប់ខ្លួនឯង" ។ អ្នកទោសដែលនៅជិតកន្លែងសួរចម្លើយ គេឲ្យកាប់រណ្តៅតែអត់ដឹងគេឲ្យកប់ខ្លួនឯង...អ្នកទោសកាប់រណ្តៅខ្លួនឯងដូចខ្ញុំថាអីចឹងទៅ ហើយនិងគេសម្លាប់ចោលខ្ទេចទៅអ្នកទៅក្នុងគុកហ្នឹង" ។ បន្ទាប់ពីនោះមក ពូ អ៊ីន ត្រូវបានបញ្ជូនមកមន្ទីរម-៩៩ ។ មន្ទីរនេះក៏ជាគុកដែលត្រូវបង្កើតឡើងនៅឆ្នាំ១៩៧៣ ហើយមានទីតាំងស្ថិតនៅក្នុងព្រៃដ៏ស្ងាត់ជ្រងំក្នុងទឹកដីឃុំគាសាល ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។ គុកក្រោយនេះមានអ្នកគ្រប់គ្រងឈ្មោះ ឆៃ ។ នៅខែមេសា ឆ្នាំ១៩៧៥ មនុស្សជាច្រើនបានបញ្ជូនឲ្យមកជាប់គុកនៅទីនេះក្រោមការគ្រប់គ្រងរបស់ តាគុល និងតាណម ។ មន្ទីរម-៩៩ ជាសាខាគុកមួយរបស់ ឌុច ដែលជីវភាពរស់នៅរបស់មន្ទីរនេះត្រូវពឹងផ្អែកទាំងស្រុងលើកម្លាំងពលកម្មរបស់អ្នកទោស ។

ការសម្លាប់មនុស្សនៅមន្ទីរ ម-៩៩ នេះ បានកើតឡើងខ្លាំងក្លាមិនចាញ់នៅគុកមន្ទីរម-១៣ប៉ុន្មានទេ ។

**(តទៅទំព័រ៣៣)**

**(តពីលេខមុន)** មានចម្លើយសារភាពមួយចំនួនបានធ្វើការប្រៀបធៀបរវាងវាសនារបស់ទាហានកម្ពុជាក្រោយជ័យជម្នះខែមេសា ឆ្នាំ១៩៧៥ជាមួយនឹងទាហានវៀតណាមនៅក្នុងរយៈពេលក្រោយនោះបន្តិច ។ នៅវៀតណាមអតីតយុទ្ធជនត្រូវបានអនុញ្ញាតឲ្យសម្រាកនិងទៅលេងក្រុមគ្រួសារសាច់ញាតិ ។ ប៉ុន្តែនៅប្រទេសកម្ពុជាវិញ ទាហានត្រូវបានបង្ខំឲ្យទៅធ្វើស្រែភ្លាម ។ វ៉ាន់ យឿន និយាយថា «នៅប្រទេសដទៃទៀតគេវៃខ្លាំងមួយខែគេសម្រាកហើយ ។ ចំណែកយើងវិញវៃរហូតគ្មានពេលសម្រាកទេ» ។ ព្រំ ភន បានធ្វើការកត់សម្គាល់ថា«នៅពេលឈ្នះសង្គ្រាមកងទ័ពវៀតណាមមានសម្លៀកបំពាក់និងហូបចុកគ្រប់គ្រាន់» ។ គំនិតនេះត្រូវបានលើកយកមកនិយាយដោយ នន ណាល់ ដែលបានសរសេរថា«អ្នកជិតខាង[វៀតណាម] ក៏វៃពួកចក្រពត្តិដូចតែយើងអីចឹងដែរ ប៉ុន្តែគេមានហូបគ្រប់គ្រាន់» ។ ការនិយាយប្រៀបធៀបផ្សេងទៀតជាមួយនឹងវៀតណាមទោះបីជាមិនបានស្តែងចេញឲ្យឃើញ ក៏វាច្បាស់ក្រឡែតដែរ ។




**សម្លេងពីមន្ទីរ ស-២១**
**វគ្គទី៤: បង្កើតសំណួរធម្លាក់កំហុស**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

ជួ នី ទាហានវរសេនាធំលេខ៨១១ ប្រើប្រាស់ពត៌មានប្រមូលយកពីវគ្គសិក្សារបស់បក្សកុម្មុយនិស្តកម្ពុជាក្នុងការឆ្លុះបញ្ចាំងអំពីបដិវត្តន៍កម្ពុជាក្នុងផ្លូវអាក្រក់ ។ នៅក្នុងចម្លើយរបស់ខ្លួន នី បានបាត់តាំងមតិវិទ្ធង្សនារបស់ខ្លួនចំពោះកម្មាភិបាលថ្នាក់លើមួយរូប ដែល នី បានស្រង់សម្តីកម្មាភិបាលនោះដែលនិយាយថា÷ «ទាហាននៅវៀតណាមមិនធ្វើស្រែដូចយើងទេ ។ ទាហានគេសប្បាយរីករាយនិងដើរហើរដោយសេរីតាមតែខ្លួនចង់ ។ មានហូបចុកគ្រប់គ្រាន់ខុសពីយើងដែលគ្មានអ្វីហូបទាល់តែសោះ ។ តាមពិតទាហានវៀតណាមក៏ធ្វើបដិវត្តន៍ដូចជាយើងដែរ ប៉ុន្តែគ្រាន់តែសំបកខាងក្រៅប៉ុណ្ណោះ ។ ប៉ុន្តែខាងក្នុងគេមិនសប្បាយចិត្តនឹងផ្លូវសង្គមនិយមនេះទេ ពីព្រោះ[សង្គមនិយម] គ្មានផ្លូវណាឲ្យប្រជាជនបានរស់ទេ ។ គេមានការភ្ញាក់រឭកតស៊ូប្រឆាំងនឹងបដិវត្តន៍ដោយឥតឈប់ឈរ ពីព្រោះគេយល់ថាគេមិនអាចធ្វើទៅមុខបាន ។ នេះមិនទាន់អស់ទេ ។ និយាយពីសូវៀតម្តង ។ នៅប្រទេសសូវៀតដែលមានបដិវត្តន៍សង្គមនិយមយូរហើយមកដល់ពេលនេះគេមិនទាន់ចាប់ផ្តើមធ្វើអ្វីដែលធ្វើសព្វថ្ងៃនេះទេ គេមិនដែលចាប់រឹបធ្វើដូចយើងភ្លាមទេ ។ សព្វថ្ងៃសូវៀតកំពុងតែពិនិត្យបញ្ហាផ្សេងៗសាឡើងវិញ ពីព្រោះគេមិនអាចរក្សានូវការតស៊ូវណ្ណៈក្តៅគគុកបានដែលមានការពាក់ព័ន្ធនឹងបដិវត្តន៍ ។ ធ្វើបដិវត្តន៍គឺពិបាកណាស់...ពេលយើងធ្វើបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យប្រឆាំងនឹងខ្មាំង គេនិយាយថាពិបាក ។ នៅពេលសង្គ្រាមចប់យើងចូលទៅក្នុងបដិវត្តសង្គមនិយមហើយគេនិយាយថាយើងនឹងបានសប្បាយ ។ តែតាមការពិតវានៅតែពិបាកដដែលតាំងពីការស្លៀកពាក់ការហូបចុក និងសេរីភាពដើរហើរ ។ គ្មានចំណុចណាមួយដូចនៅប្រទេសវៀតណាមទេ» ។

ជ័យជម្នះបាននាំមកនូវរង្វាន់សម្រាប់កងទ័ពកម្ពុជាតិចណាស់ ។ ភាគច្រើន ជ័យជម្នះតែងតែមានភាពលើសលប់ជាងអ្វីដែលបានទទួលរងនូវការឈឺចាប់ និងឋានៈរបស់ខ្លួនកាលពីមុន ។ យុវជន យុវនារី បានបោះបង់ការងារស្រែចម្ការរបស់ឪពុកម្តាយដើម្បីមក«រំដោះ»ប្រទេសកម្ពុជានិងខ្លួនឯងផ្ទាល់ ហើយនៅពេលបានទទួលជ័យជម្នះយុវជនយុវនារីទាំងនោះមិនចង់ត្រឡប់ទៅធ្វើស្រែវិញទេ ។ វោហារសាស្ត្រគាំទ្រប្រជាកសិកររបស់របបកម្ពុជាប្រជាធិបតេយ្យត្រូវផ្ចាញ់ដោយយុទ្ធជនកម្ពុជាដែលអ្នកទាំងនោះមានមានអារម្មណ៍ថា ក្នុងនាមជាយុទ្ធជនបដិវត្តខ្លួនត្រូវតែមានសិទ្ធិដកខ្លួនចេញពីភក់ ឈឺឆ្អឹង ឈឺឆ្អែង និងឋានៈតូចទាប ជាកសិករធ្វើស្រែ ហើយប្រគល់ឋានៈនេះទៅឲ្យអ្នកផ្សេងៗ ជាការគួរឲ្យអស់សំណើច អ្នកដែលចាត់តាំង

ទោសកំហុសកម្របានធ្វើស្រែដោយផ្ទាល់ដៃណាស់ ។

កែ សាន ហៅ (សុខ) ដែលជាសមាជិកមានឋានៈខ្ពស់របស់បក្ស ខឹងចំពោះការវិវត្តទាំងនេះ និងក្លែមសម្តីដើម្បីបញ្ជាក់គំនិតដែលគាត់ចង់និយាយថា÷ [នៅខែឧសភា] ឆ្នាំ១៩៧៥ មានម្នាក់ឈ្មោះ ចាស់ បាននិយាយថា“មិត្តឃើញទេ យើងបានរំដោះមួយខែកន្លងទៅហើយ ដោយគ្មានសម្រាកបន្តិចសោះ ។ រាល់អ្វីៗដែលយើងធ្វើគឺគិតតែពីវាយសម្រុក ។ យើងដាំស្រូវទាំងយប់ទាំងថ្ងៃ អ្នកឯងសាកគិតមើល៍ តើមានបញ្ហានិងភាពច្របូកច្របល់យ៉ាងដូម្តេចខ្លះ ។

ពីរ-បីខែក្រោយមក ឃឿង រុន ដែលជាទាហានដូចគ្នាបានរាយការណ៍អំពីភាពទុក្ខព្រួយរបស់មិត្តខ្លួននៅពេលឃើញប្រជាជនជាច្រើនមានសម្លៀកបំពាក់រហែករយ៉ៃ ។ សំ និយាយថា“ធ្វើបដិវត្តន៍ពិបាកនិងស្មុគស្មាញណាស់...រស់នៅក៏ពិបាកស្លៀកពាក់នោះក៏ពិបាក ។ ឥឡូវនេះមើលខោអាវយើងទៅមើល៍ ។ យើងមិនដែលមានសម្លៀកបំពាក់ថ្មីទាល់តែសោះ ។ កម្មាភិបាលនិងទាហានធម្មតាគឺដូចតែគ្នា ។ ពេលអ្នកឯងទៅសមរភូមិ អ្វីដែលអ្នកឃើញគឺខោអាវ រហែករយ៉ៃ គោកយ៉ាក គ្មានអ្វីស្អាតបន្តិចសោះ ហើយនៅមានចំណុចជាច្រើនទៀត ។ មិនថាថ្ងៃណា ខែណា ឆ្នាំណាទេ អ្នកនឹងឃើញ [ទាហាន] ដេកផ្ទាល់ដី ហើយខ្លួនប្រាណរបស់អ្នកទាំងនោះមិនដែលប៉ះទឹកម្តងណាឡើយ ។ ពួកទាហានផ្ទូតទឹក ផ្ទូតភក់តែម្តងប៉ុណ្ណោះក្នុងមួយខែ ។







យុទ្ធជនចាស់ៗបានត្អូញត្អែរថា ខ្លួនត្រូវបែកពីប្រពន្ធកូន ។ ការបំបែកគ្រួសារមិនសមហេតុផលទាល់តែសោះ ។ ដូចដែល កេង បាក់ លើកឡើងអំពីបញ្ហាតាមរយៈសំឡេងរបស់អ្នកដទៃថា÷ គាត់និយាយថាខ្លួនគាត់និងប្រពន្ធគាត់ ព្រមទាំងខ្ញុំបានឆ្លើយតបទៅវិញថា “មិត្ត ប្រសិនបើមិត្តពិនិត្យជនបដិវត្តជាពិសេសមិត្តរបស់មិត្តឯងផ្ទាល់មិត្ត នឹងដឹងថា នៅពេលដែលអង្គការនិយាយថាយើងត្រូវបានរំដោះឲ្យមានសេរីភាព ពាក្យសេរីភាពគឺគ្មានផ្លូវបានឃើញទេ ។ បើមានសេរីភាពមែននោះ ម៉្លេះមិត្តត្រូវបានឲ្យទៅជួបជុំប្រពន្ធបាត់ទៅហើយ ។ តើមូលហេតុអ្វីបានជាមិនបានទៅជួបប្រពន្ធយ៉ាងដូច្នេះ? ហាន ក៏ឆ្លើយថា“វាស្រេចតែលើអង្គការទេ ។ បើអង្គការមិនយកចិត្តទុកដាក់[ចំពោះយើង] ថ្ងៃណាមួយយើងនឹងរត់ចោលជួរមិនខានឡើយ ចាំតែមើលទៅថ្ងៃណាមួយខ្ញុំនឹងរកកន្លែងថ្មីដោយខ្លួនឯង” ។

ទោះបីជាការត្អូញត្អែរអំពីកម្ពុជាប្រជាធិបតេយ្យខ្លី ប៉ុន្តែច្បាស់ មានប្រសិទ្ធភាពនិងមានឥទ្ធិពល ប៉ុន្តែមានឧទាហរណ៍មួយចំនួននៅក្នុងបណ្ណសារមួយដែល ដេម សុត ហៅថា “ប្រតិចារឹកមិនចេញមុខ”ដែលមានតាំងពីការតស៊ូដល់ការគាបសង្កត់ ។ គំរូបង្ហាញអំពីការប្រឈមមុខគ្នា អំពើឃោរឃៅ និងភាពព្រហើន ដែលមិននឹកស្មានដល់រវាងអ្នកជិះជាន់និងអ្នកដែលត្រូវជិះជាន់ ដែលលេចឡើងជាញឹកញាប់នៅក្នុងកំណត់ប្រវត្តិនៃសារមន្ទីរហាយនភាពឬជំរំប្រមូលផ្តុំរបស់រុស្ស៊ីនិងចិន ពិតជាកម្រមានណាស់ ។

ដោយសារតែកម្រមានក្នុងបណ្ណសារយ៉ាងនេះហើយ បានជាឱកាសដែលអ្នកទោសវាយប្រហារបដិវត្តន៍ដោយផ្ទាល់មានភាពស្រួចស្រាល់និងគួរឲ្យរន្ធត់ណាស់ ។ ប្រាក់ ឈាន ជាទាហានតូចតាចនៅកងពលលេខ៣១០ និយាយដោយត្រង់ថា “អង្គការអាក្រក់មែនទែន” ។ ហូ គុងហូ អតីតជាគ្រូបង្រៀនដែលធ្លាប់ទៅលេងសហរដ្ឋអាមេរិកកាលពីទសវត្សរ៍ឆ្នាំ១៩៥០ បានប្រើចម្លើយសារភាពរបស់ខ្លួនវាយប្រហារលើមនោគមវិជ្ជានិងការអនុវត្តជាក់ស្តែងរបស់បក្សកុម្មុយនិស្តកម្ពុជា ដោយកត់សម្គាល់ថា “ខ្ញុំមិនអាចមើលឃើញផ្លូវដែលកុម្មុយនិស្តនឹងបានទទួលជ័យជម្នះទេ នៅថ្ងៃអនាគត ប្រសិនបើអ្នកធ្វើការខាង

បច្ចេកទេសត្រូវបណ្តេញចោលពីការងារផលិតកម្ម ឧស្សាហកម្មត្រូវគាំង ហើយរោងចក្រនានាត្រូវបិទទ្វារយ៉ាងនេះ» ។ អ្នកអង្គការ ធ្វើការនៅវិទ្យុផ្សាយសំឡេងបានសារភាពថាការងាររបស់គាត់ត្រូវបាត់បង់ដោយសារតែគាត់មាន «កំហឹងក្តៅពេកចំពោះបដិវត្តន៍» ។ តាន ឌឿន បានកត់សម្គាល់យ៉ាងច្បាស់ថាចំពោះខ្លួនគាត់វិញ «កុម្មុយនិស្តគឺហូបបាយមួយកំប៉ុងក្នុងមួយថ្ងៃ និងដើរតាមគំនិតមនុស្សចាស់គំរិល» ។

«ប្រតិចារឹកមិនចេញមុខ»ជាច្រើនផ្សេងទៀតអាចត្រូវបានបញ្ចេញដោយផ្ទាល់មាត់ ហើយដូច្នេះមិនទាន់ត្រូវបានចងក្រងឲ្យបានត្រឹមត្រូវដាក់ក្នុងបណ្ណសារទេ ។ ញ៉ែម អេន ដែលរស់នៅជាមួយអ្នកធ្វើការជាមួយខ្លួននៅក្នុងផ្ទះមានចម្ងាយរាប់រយម៉ែត្រពីគុក បានរំឭកការចងចាំរបស់ខ្លួនដែលឮអ្នកគុកម្នាក់ស្រែកជំទាលខ្លាំងៗទាំងកណ្តាលអធ្រាត្រនៅក្នុងទីក្រុងដែលស្ងាត់ជ្រងំថា «បើចង់សម្លាប់ខ្ញុំសម្លាប់មក ។ អាមនុស្សក្បត់!» ។

អ្នកទោសភាគតិចណាស់មានចម្ងល់អំពីវិន័យឃោរឃៅចាប់ពីលើមកដល់ក្រោមរបស់កម្ពុជាប្រជាធិបតេយ្យ ជាចរិតដែលកម្ពុជាប្រជាធិបតេយ្យបានរួមចំណែកជាមួយរបបកម្ពុជាមុនសម័យបដិវត្ត ។ ហៅឈ្មោះអ្នកធំថា អាមីង មិនបានជាដាច់ខាត ។ ខ្ញុំបានមើលចម្លើយសារភាពរបស់អ្នកទោសម្នាក់ឈ្មោះ អ៊ិន វ៉ាន់ ដែលធ្វើការនៅកងពិសេស «ការពារអង្គការ» រហូតដល់ថ្ងៃចាប់ខ្លួននាខែមីនា ឆ្នាំ១៩៧៧ ។ នៅក្នុងចម្លើយសារភាព វ៉ាន់ បានជេរប្រទេច ខៀវ សំផន ដែលប្រហែលជាបងលេខ៦ឬ៧ ។ «ខៀវ សំផន កំពុងតែធ្វើបដិវត្តន៍សង្គមនិយមគាបសង្កត់ វាយប្រហារសតិអារម្មណ៍សេរីរបស់ប្រជាជន និងជិះជាន់កេងប្រវ័ញ្ចប្រជាជនគ្មានមេត្តា ។ ដូច្នេះយើងត្រូវតែវាយប្រយុទ្ធដើម្បីរំដោះបងប្អូនដែលស្ថិតនៅក្រោមការជិះជាន់សង្កត់សង្កិនរបស់ពួកនេះដែលមិនមានបដិវត្តន៍ស្អាតស្អំ ។»

កាន់តែធំជាងនេះទៅទៀត ឈ្មោះ ភួង កម្មាភិបាលជាន់ខ្ពស់មកពីភូមិភាគបូព៌ាដែលជាមុខសញ្ញារបស់សន្តិបាលតាំងពីឆ្នាំ១៩៧៦ ហើយត្រូវចាប់ខ្លួននៅឆ្នាំ១៩៧៨ បានវាយប្រហាររបបនេះដោយចំៗថា «ប្រជាជនកំពុងតែបាត់បង់នូវសិទ្ធិប្រជាធិបតេយ្យនិងសេរីភាព គ្រប់កម្មាភិបាលទាំងអស់និងអំណាចទាំងមូលគឺស្ថិតនៅក្រោមការកាន់កាប់របស់បក្សកុម្មុយ-និស្តគ្រប់ពេល...ពីមួយថ្ងៃៗប្រជាជននិងកម្មាភិបាលត្រូវបានចាប់ដាក់គុក ដាក់ច្រវ៉ាក់ យកទោសម្លាប់ទាំងរយៗ ហើយអង្គការគ្មានច្បាប់ប៉ុនក្រចកមកការពារសិទ្ធិរបស់ប្រជាជនឡើយ ។ ប្រជាជននៅស្ងាត់ស្ងៀមហាក់ដូចជាឈឺចាប់ជាពន់ពេក ចង់និយាយក៏ មិនហ៊ាននិយាយព្រោះចេះតែខ្លាច» ។

លេខាភូមិភាគបស្ចិមឈ្មោះ ជូ ជេត ដែលត្រូវបានចាប់ខ្លួននៅខែមីនា ឆ្នាំ១៩៧៨ បាននិយាយតទល់ជាមួយអ្នកដែលចាប់ខ្លួននូវចំណុចមួយចំនួនដែលជាការវាយប្រហារចំៗ ដោយឥតលាក់លៀមទៅលើបក្សកុម្មុយនិស្តកម្ពុជានិងនយោបាយ


អ្នកទោសមន្ទីរស-២១

របស់បក្សនេះ ប៉ុន្តែមិននិយាយចំឈ្មោះនរណាម្នាក់នៅក្នុងបក្សឡើយៈ «[ខ្ញុំនិយាយថា] របបសព្វថ្ងៃនេះគឺជារបបផ្តាច់ការតឹងរ៉ឹង និងដាច់ខាតបំផុតនិស្ស័យនិងសតិអារម្មណ៍ប្រជាជន ។ ហេតុនេះហើយបានជាប្រជាជនជាច្រើនរអ៊ូរទាំ... ថាខ្លួនធ្វើការច្រើនដែរតែទទួលបានផលតិចណាស់ គេរស់ជាមួយគ្រួសារជុំគ្នាម្តេចបាន មានពេលឯណានឹងបានសម្រាក នឹងបាននិយាយលេងសើចសប្បាយ...» ។

យើងដឹងតាមរយៈដំណើររឿងរបស់ វ៉ាន់ ណាត ថា អ្នកទោសបាននិយាយខ្សឹបខ្សៀវដាក់គ្នាទៅវិញទៅមកជាមួយអ្នកទោសដូចគ្នា ហើយជួនកាលជាមួយអ្នកធ្វើការនៅក្នុងគុក និយាយជាមួយអ្នកទោសទៀតផង ទោះជាដឹងថាខុសនឹងវិន័យក៏ដោយ ។ ឈ្មោះ ផា ថាចាន់ បាននិយាយថាខ្លួនបានគោះជញ្ជាំងថ្មបន្ទប់គាត់ឲ្យអ្នកទោសនៅសងខាងដឹង ។ ថាចាន់ មិនដែលបានឃើញ ឬដឹងថាអ្នកទោសទាំងនោះជាអ្នកណាខ្លះទេ ។ អ្វីដែលនិយាយចេញឬគោះនៅក្នុងកាលៈទេសៈបែបនេះ គឺជាប្រតិ“ចារឹកមិនចេញមុខ” ប្រសិនជាមានគឺនៅមានលក្ខណៈអាថ៌កំបាំងនៅឡើយ ។ ដូចគ្នានេះដែរ ឯកសារនិយាយអំពីការសន្ទនាគ្នារវាងអ្នកសួរចម្លើយស្តីអំពីការងាររបស់ខ្លួនទៅលើអ្នកទោសកម្រមានណាស់ ហើយមិនអាចធ្វើឡើងវិញបានទេ ។ ជនរងគ្រោះនិងជនដៃដល់ភាគច្រើនអាចពុតាមរយៈក្រដាសស្នាមដែលនៅសល់តែប៉ុណ្ណោះ ។



រុយ នាគង់



“សកម្មភាពក្បត់” របស់អ្នកទោសដែលផ្ទុយពីការតវ៉ារិះគន់ទៅលើរបបនេះ មិនអាចមានអ្វីបញ្ជាក់ថាពិតបានទេ ។ ប៉ុន្តែភាគច្រើនសកម្មភាពទាំងនេះធ្វើឲ្យយើងនឹកឃើញនូវបញ្ហាពិតៗដែលកម្មាភិបាលស្ថិតក្រោមការគាបសង្កត់ខ្លាំងដែលខ្លួនបានជួបប្រទះនៅតាមជនបទក្នុងពេលតស៊ូស៊ុតស្វាញក្នុងការដាក់ចុះឲ្យអនុវត្តនូវគោលនយោបាយរបស់មជ្ឈិមបក្ស ។ អនុស្សរណៈចុះខែវិច្ឆិកា ឆ្នាំ ១៩៧៦ ផ្ញើមកពីឈ្មោះ រឿន ដែលជាលេខាកងពលលេខ ៨០១ឈរជើងនៅខ្សែក្រវ៉ាត់ក្រុង ជូនចំពោះ សុន សេន បានរៀបរាប់អំពី“សកម្មភាពរបស់អ្នកដែលបម្រើឲ្យខ្មាំង” នៅក្នុងអង្គភាពយោធា ។

១) ពួកវាបានឃោសនាឲ្យកម្មាភិបាលនិងជួរផ្សេងៗទៀតកុំឲ្យជឿលើបដិវត្តន៍របស់យើង ដោយលើកឡើងថាហូបមិនគ្រប់គ្រាន់ ។

២) ពួកវាបញ្ចុះបញ្ចូលឲ្យយុទ្ធជនរត់ចោលជួរទ័ពឬរត់ចេញពីសហករណ៍ដោយនិយាយថា នៅសហករណ៍ពិបាកណាស់ ។

៣) នៅការដ្ឋានពួកវាបានបំផុសឲ្យប្រជាជនលួចអ្វីក៏ដោយ ឲ្យតែលួចបាន បើស៊ីមិនកើតគ្រវាត់ចោល ។

៤) ពួកវាបានបំផុសប្រជាជន“សេរី” ដើរស្រេចតែចិត្ត និយាយតាមដែលខ្លួនយល់ឃើញថា នៅប្រទេសវៀតណាមនិងនៅឡាវគេមានសេរីភាពជាង ។

៥) ពួកវាបំផុសប្រជាជនអំពីបញ្ហាបុណ្យស័ក្តិ សិទ្ធិ និងប្រាក់ខែ នៅប្រទេសវៀតណាមនិងប្រទេសឡាវ ដែលនៅទីនោះ [ប្រជាជន] មានការសប្បាយរីករាយចំពោះប្រាក់ខែ ចំណែកឯបដិវត្តន៍កម្ពុជាវិញ មិនសប្បាយទេ ហើយនឹងមិនសប្បាយចិត្តជាយូរតទៅទៀត ។

៦) ពួកវាបំផុសឲ្យប្រជាជនខ្ជិលធ្វើការដោយនិយាយថា “បើហូបមិនឆ្អែត គ្មានកម្លាំងឯណាទៅធ្វើការទេ” ។

“សកម្មភាពរបស់អ្នកបម្រើខ្មាំងទាំងនេះ” បង្ហាញអំពីអ្វីដែលកម្មាភិបាលបក្សនិងកូនទាហានធម្មតាបានឆ្លើយសារភាពដដែលៗ ។ ពាក្យដែលអ្នកទោសយកមកប្រើសម្រាប់រៀបរាប់“សកម្មភាពក្បត់”របស់ខ្លួន ភាគច្រើនគឺជាពាក្យឡេនីននិយម ដែលបានមកពីវគ្គសិក្សានានា របស់បក្សកុម្មុយនិស្តកម្ពុជា ។ ឧទាហរណ៍ជាក់ស្តែងមួយអ្នកទោសបាននិយាយថា ខ្លួនបាន“អប់រំ” និង“ចាត់តាំង” កម្លាំងក្បត់ ។ ពាក្យទាំងពីរនេះគឺជាពាក្យម៉ាក្ស-ឡេនីន ដែលជាមូលដ្ឋានគំនិតសំខាន់របស់បក្សកុម្មុយនិស្តកម្ពុជា ។ ឧទាហរណ៍មួយទៀត

ដែលបង្ហាញពីភាសានិយាយរបស់បក្សដូចជាការអះអាងរបស់អ្នកទោសដែលថាខ្លួនបាន "ចិញ្ចឹមការសម្ងាត់" "កសាងកម្លាំង" "ពង្រីកម្លាំង" "វាយសម្រុក" និង "ឃោសនា" ។

អ្នកទោសតែងតែឆ្លើយថាធ្វើតាមកលល្បិចវិទ្ធង្សនាដែលបក្សកុម្មុយនិស្តកម្ពុជាប្រើនៅតាមផ្លូវ ដើម្បីកាន់កាប់អំណាច ។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេថា បក្សភាគច្រើនដែលអ្នកទោសបង្កើតឬចូលរួម គឺសុទ្ធតែត្រូវបានរៀបចំដូចគ្នាបេះបិទទៅនឹងសណ្ឋានរបស់បក្សកុម្មុយនិស្តកម្ពុជា ។ មិនតែប៉ុណ្ណោះ "ខ្មាំង"មួយចំនួនបានសារភាពថាខ្លួនធ្លាប់"បង្កប់ស៊ីរូងផ្ទៃក្នុង" សង្គមកម្ពុជា ។ ប៉ុន្តែមិនដូចបក្សកុម្មុយនិស្តកម្ពុជាទេ បក្សក្បត់មានអ្នកដឹកនាំច្បាស់លាស់ (ជាទូទៅគឺកម្មាភិបាលដែលត្រូវបានចាប់ខ្លួនរួច ហើយឬស្លាប់បាត់ទៅហើយ) ។ សមាជិករបស់បក្សក្បត់មានភក្តីភាពចំពោះមេរបស់ខ្លួនដែលត្រូវបានបក្សកុម្មុយនិស្តកម្ពុជាចាប់ខ្លួនឬសម្លាប់ ចំណែកឯមជ្ឈិមរបស់បក្សមានភក្តីភាពចំពោះមេរបស់ខ្លួនត្រូវបានបក្សកុម្មុយនិស្តកម្ពុជាចាប់ខ្លួនឬសម្លាប់ ចំណែកឯមជ្ឈិមបក្សវិញ មើលងាយមើលថោកចំពោះអ្នកទាំងនេះទៅវិញ ។

ឆ្លើយតបទៅនឹងសំណួរថាតើមានលាក់អ្វីខ្លះមិនឲ្យអ្នកសួរចម្លើយដឹងអ្នកទោសជាច្រើនបានឆ្លើយប្រាប់ដោយនិយាយរឿងដែលមិនគួរជឿបានដូចជាថាលាក់អាវុធ គ្រាប់រំសេវ ថ្នាំពេទ្យ កញ្ចប់ថ្នាំពុល និងវៀតណាម ដែលមានរហូតដល់២០ករណីឯណោះ ។

ប៉ុក ផា បានឆ្លើយថាបាន"ប្រមូលកម្លាំង" មិនឲ្យនរណាដឹងដែលខ្លួនបាន"លាក់ទុកយ៉ាងជ្រៅ" ។ ចម្លើយសារភាព៦១ច្បាប់ដែលទាក់ទងនឹងរបស់ ឬមនុស្សដែលលាក់គឺសុទ្ធតែមានអមដោយផែនទីគូរដោយដៃយ៉ាងស្អាតមានរបៀបរៀបចំដោយបុគ្គលិកធ្វើការនៅស-២១ ដែលបញ្ជាក់ច្បាស់ចាប់តាំងពីកន្លែងលាក់រហូតដល់មន្ទីររបស់អ្នកគូររូបនេះ ។ ចម្លើយសារភាពដែលនិយាយអំពីជនជាតិវៀតណាមដែលត្រូវបានលាក់ខ្លួនគឺសុទ្ធតែសរសេរឡើងនៅក្នុងឆ្នាំ១៩៧៨ ក្រោយពីមានផ្ទុះឡើងនូវភាពប្រទូសរ៉ាយជាមួយវៀតណាម ។ ភាពប្រទូសរ៉ាយទាំងនេះបានធ្វើឲ្យនឹកឃើញដល់ការរំដើបរំជួលយ៉ាងខ្លាំងនៅទូទាំងមជ្ឈិមបក្សនៅពេលនេះ ។ ជនជាតិវៀតណាមត្រូវបានគិតថាមានគ្រប់ទីកន្លែង"ដែលបង្កប់ស៊ីរូងផ្ទៃក្នុង" ត្រៀមខ្លួនវាយសង្គ្រប់ក្នុងពេលដែលកម្លាំងវៀតណាមនៅតាមជនបទវាយតទល់ដោយចំហជាមួយនឹងកងទ័ពកម្ពុជាប្រជាធិបតេយ្យ ។ ខ្មាំងបង្កប់តែងតែគ្រោះថ្នាក់បំផុត ។ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨ ក្រោយពីវគ្គសិក្សាដែលដាក់ឈ្មោះថា "អំពីបញ្ហាវៀតណាមបង្កប់" អ្នកសួរចម្លើយជាន់ខ្ពស់ឈ្មោះ ប៉ុន សរសេរថា "ជាការពិតណាស់វៀតណាមគឺនៅមានបង្កប់នៅក្នុងទីក្រុងភ្នំពេញពីព្រោះភ្នំពេញមិនទាន់បានបោសសម្អាតពួកក្បត់នៅឡើយទេ ។ ឯកសារនៅសន្តិបាលបង្ហាញថា ជនក្បត់បានបង្កប់ពួកវៀតណាមនៅភ្នំពេញនៅពាយ័ព្យនិងនៅភូមិភាគដទៃៗទៀត" ។

ចម្លើយសារភាពមួយចំនួនបង្ហាញថា វៀតណាមត្រូវបានលាក់ខ្លួននៅតាមផ្ទះ ឬនៅតាមដីឡូត៍ដែលទុកចោលនៅម្តុំក្រសួងមន្ទីរសំខាន់ៗមួយចំនួននៅទីក្រុងភ្នំពេញ ។ ក្នុងចំណោមចម្លើយសារភាពទាំងនេះ គ្មានចម្លើយសារភាពណាមួយត្រូវបានឌុច និង កូនចៅទាត់ចោលថាជារឿងស្រមើស្រមៃនោះទេ ហើយក៏គ្មានឈ្លើយសង្គ្រាម និងគិញវៀតណាមណាម្នាក់ដែលត្រូវបានសួរចម្លើយនៅក្នុងគុកនេះ ឆ្លើយថាខ្លួនត្រូវលាក់ទុកដោយជនជាតិខ្មែរដែរ ។ ករណីទាំងនេះប្រហែលជាឧទាហរណ៍ដ៏ច្បាស់ក្រឡែតនៅក្នុងបណ្ណសារនៃគំនិតរវើរវាយដែលអ្នកទោស អ្នកសួរចម្លើយ និងមជ្ឈិមបក្សដឹងថាមិនមានមូលដ្ឋានពិតប្រាកដ ។ ទន្ទឹមពេលជាមួយគ្នានេះដែរ ការក្បត់របបគឺមានន័យថា លាក់បំពួនវៀតណាមនៅក្នុងខ្លួន ដូចជាអំពើក្បត់ដែលស្មើនឹងនិន្នាការ "គហបតី"យ៉ាងដូច្នោះដែរ ។

ដូចជាផែនទីបង្ហាញពីទីតាំងលាក់អាវុធ ថ្នាំពេទ្យ ថ្នាំពុល និងវៀតណាមដូច្នេះដែរ ដែលជាការនិយាយរៀបរាប់ការពិតតាមរយៈចម្លើយសារភាព ។ ចម្លើយសារភាពភាគច្រើនគឺសុទ្ធតែនិយាយពីរឿងថ្មីៗដោយសារថាអ្នកទោសត្រូវបានបង្ខំឲ្យសារភាពថាបានធ្វើការឲ្យខ្មាំងដែលមជ្ឈិមបក្សកំពុងតែរកមុខ ។ គ្មានអ្នកណាម្នាក់"លាក់វៀតណាម"ទេនៅក្នុងឆ្នាំ១៩៧៦ ម្យ៉ាងវិញទៀតនៅឆ្នាំ១៩៧៨ ក៏គ្មាននរណាម្នាក់ឆ្លើយថាធ្វើការឲ្យរបប លន់ ណុល ដែរ ។ តាមធម្មតា "កំហុស"របស់អ្នកទោសក៏មានការទាក់ទងជាមួយនឹងការងាររបស់ខ្លួនដែរ ។ **(នៅមានត)**

### វៀតណាមបរិយាយៈ

# ឈ្លើយសឹកកម្ពុជាដែលត្រូវវៀតណាមចាប់ខ្លួន

«ថ្ងៃនេះខ្ញុំដឹងថាវៀតណាមមិនដែលជាខ្មាំងរបស់ប្រជាជនកម្ពុជាណាម្តងឡើយ ប៉ុន្តែឥឡូវនេះវាយឺតពេលទៅហើយ» ។ នេះជាសម្តីសារភាពរបស់ សៀម សារិញ មានដើមកំណើតនៅខេត្តស្វាយរៀងដែលជាទាហានក្នុងកងអនុសេនាតូចលេខ១០ វរលេខ៤ អនុសេនាធំលេខ២ ឈរជើងនៅស្រុកពាមជរ ។ «អនុសេនាតូចរបស់ខ្ញុំជាមួយនឹងអង្គភាពកងតំបន់២០ និងកម្លាំងមកពីយោធាតំបន់ បានសម្រុកចូលសាម៉ាតនៅរាត្រីថ្ងៃទី២៤-២៥ខែកញ្ញា ឆ្នាំ១៩៧៧ ។ នៅទីនោះយើងបានដេញអ្នកស្រុកអ្នកភូមិ ដុតផ្ទះសម្បែង ចាប់ស្ត្រីរំលោភ និងសម្លាប់រង្គាលប្រជាជនដោយគ្មានមេត្តា» ។ សៀម សារិញ ស្ថិតក្នុងកងកម្លាំងដ៏ធំមួយដែលត្រូវបានទីក្រុងភ្នំពេញ បញ្ជូនមកឲ្យវាយលុកខេត្តតាយនិញ ។ កម្លាំងទាំងអស់រួមមានកងពលលេខ៣និងលេខ៤ ដែលជួយជាកម្លាំងដោយអង្គភាពមកពីតំបន់២០, ២១និងតំបន់២៣នៃតំបន់យោធា២០៣ (ភាគបូព៌ានៃប្រទេសកម្ពុជា) ។ កងកម្លាំងកម្ពុជាប្រជាធិបតេយ្យបានជ្រៀតចូលក្នុងទឹកដីវៀតណាមចម្ងាយ៧គីឡូម៉ែត្រ និងបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ឃោរឃៅមិនដែលមានពីមុនមកប្រឆាំងនឹងជនស៊ីវិល ដូចអ្នកដែលធ្លាប់បានអនុវត្តកាលពី៥ខែមុននៅក្នុងខេត្តអានហ្សាង កាលពីយប់ថ្ងៃទី៣០ ខែមេសា និងក្នុងថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧៧ ដែលធ្វើឲ្យមតិអន្តរជាតិមួយភាគធំខឹងសម្បារយ៉ាងខ្លាំង ។

សៀម សារិញ បន្តទៀតថា «ខ្លួនខ្ញុំផ្ទាល់បានបើកការវាយប្រយុទ្ធទៅលើកងរក្សាព្រំដែនដែលឈរជើងនៅប៉ុស្តិ៍លេខ២៧ នៅភូមិលេខ៨ ។ នៅពេលកម្លាំងម្ខាងទៀតវាយបកមកវិញ ខ្ញុំបាត់ម្ចាស់ការនិងត្រូវរបួស ហើយចុងបញ្ចប់ក៏ត្រូវបានចាប់ខ្លួនជាមួយនឹងអាវុធអាកាមួយដើមនិងគ្រាប់បែកដៃ៤គ្រាប់» ។

សុន សុជាត ទាហានកងវរសេនាធំលេខ១៨២ កងពលធំលេខ៣នៃកងទ័ពកម្ពុជាប្រជាធិបតេយ្យ បានធ្លាក់ចូលក្នុងដៃឆ្មាំការពារព្រំដែនវៀតណាមប៉ុន្មានម៉ោងក្រោយពី សៀម សារិញ ត្រូវបានចាប់ខ្លួនហើយ បានប្រាប់យើងលម្អិតអំពីគម្រោងការរបស់ថ្នាក់លើ៖ «ឈ្មោះ សុល មេបញ្ជាការកងអនុសេនាធំឈរជើងនៅស្រុកចន្ទ្រា បានបញ្ជាឲ្យយើងកម្ទេចអ្វីក៏ដោយឲ្យតែប្រទះ ដើម្បីពង្រីកទឹកដីកម្ពុជា...យើងត្រូវដុតផ្ទះសម្បែងទាំងអស់និងសម្លាប់ប្រជាជនរួមទាំងមនុស្សចាស់ ក្មេង ប្រុសស្រី រឹបអូសយកគោក្របីនិងផលស្រូវចូលមកកម្ពុជា» ។

គម្រោងការយូរអង្វែងរបស់ក្រុងភ្នំពេញត្រូវបែកការណ៍អស់ ។ ម៉េង ញៀប ជាអ្នកស្រុកតាកែវនិងជាទាហានកងអនុសេនាតូចលេខ២ អនុសេនាធំលេខ១ វរសេនាតូចលេខ២៧ វរសេនាធំលេខ២ យោធភូមិភាគនិរតី ដែលត្រូវបានចាប់ខ្លួននៅខែឧសភា ឆ្នាំ១៩៧៧ នៅខេត្តអានហ្សាង បានសារភាពថា៖«ចាប់តាំងពីខែមីនា ឆ្នាំ១៩៧៧ តាម៉ុក ជាសមាជិកមន្ទីរភូមិភាគ អមដោយចិនពីរនាក់សស្កុសហើយមាឌធំ បានចុះមកធ្វើសតិអារម្មណ៍កងទ័ពឲ្យរៀបចំវាយលុកចូលវៀតណាមដល់កន្លែងមានដើមត្នោតទីមួយនៅសៃហួន...យើងបានចាប់ផ្តើមដោយវាយប្រហារនៅតាមព្រំដែនដេញចុះទៅព្រែកជីក វិញគេនិងបាក់ដាយ ។ យើងសម្រាកនៅក្បាលស្ពានមួយភ្លែតដើម្បីដកយកខ្យល់អាកាសហើយក៏ចូលបន្តទៅក្នុងទឹកដីវៀតណាមជ្រៅថែមទៀត» ។

គូកនរបស់ ម៉េង ញៀប ដែលកងកម្លាំងយើងចាប់បាននៅនឹងកន្លែងក្នុងពេលជាមួយគ្នានេះ បានសារភាពប្រហាក់ប្រហែលគ្នានេះដែរ ។

ដើម្បីអនុវត្តមហិច្ឆតាដ៏ឃោរឃៅរបស់ខ្លួន អាជ្ញាធរកម្ពុជាប្រជាធិបតេយ្យបានព្យាយាមរកគ្រប់មធ្យោបាយក្នុងការញុះញង់បំផុសកំហឹងកងទ័ពរបស់ខ្លួនចំពោះជនជាតិវៀតណាម ។

អុីញ ចាន់ថុន អាយុ២៧ឆ្នាំ ជាអ្នកស្រុកមានដើមកំណើតនៅខេត្តស្វាយរៀង ដែលជាមេបញ្ជាការរងកងវរសេនាធំលេខ៥០១ កងពលលេខ៣នៃកងទ័ពកម្ពុជាបានផ្តើមផ្តល់

ចម្លើយសារភាពរបស់ខ្លួន ដោយនិយាយថា "បក្សបានអប់រំពួកយើងខ្ញុំផ្ទាល់និងយុទ្ធជនដទៃទៀតថា វៀតណាមគឺជាអ្នកឈ្លានពានជាខ្មាំងស៊ីសាច់ហុតឈាមទីមួយរបស់យើង យើងត្រូវតែវាយដោយគ្មានរួញរា" ។

ចាន់ ថុន ចូលបក្សនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៣ ហើយត្រូវបានចាប់ខ្លួនក្រោយពីបានចូលបក្សបាន៤ឆ្នាំកត់នៅភាគខាងត្បូងផ្លូវជាតិលេខ១ ភាគនិរតីនៃខេត្តតាយនិញ ។ ចាន់ ថុន ត្រូវរងរបួសជាទំងន់ ហើយត្រូវបានពេទ្យវៀតណាមមើលថែទាំនៅមន្ទីរពេទ្យទីរួមខេត្ត ។ ចាន់ ថុន មានពេលគ្រប់គ្រាន់សម្រាប់ទទួលការអប់រំរបស់អង្គការអំពី"សត្រូវស៊ីសាច់ហុតឈាម"ដែលទើបតែបានសង្គ្រោះខ្លួនឲ្យផុតពីសេចក្តីស្លាប់ថ្មីៗនេះ ។ ចាន់ថុន បញ្ជាក់នៅចុងបញ្ចប់នៃចម្លើយសារភាពរបស់ខ្លួនចុះថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៨ថា "វៀតណាមបានរំដោះខ្ញុំឲ្យផុតពីក្រញាំពួកខ្មែរក្រហម" ។ "សម្លាប់ពួកវាចោលទៅ" សម្រែកនេះគឺចេញពីមាត់របស់ អ៊ីញ ចាន់ថុន និងកូនចៅរបស់ខ្លួន ។ មានទាហានម្នាក់ដែលត្រូវបានចាប់ខ្លួននៅពេលកំពុងធ្វើសកម្មភាពបានសារភាពថា "មេៗរបស់យើងបានប្រាប់ថា វៀតណាមគឺជាសត្រូវប្រពៃណីរបស់យើង ជាសត្រូវទី១របស់ប្រជាជនកម្ពុជា" ។ "យើងត្រូវសម្លាប់ពួកវាចោល បើមិនសម្លាប់វា វានឹងសម្លាប់យើង ។ ដូច្នេះយើងត្រូវបង្ខំចិត្តសម្លាប់វៀតណាម" ។ ឃាតករដែលត្រូវបានចាប់ខ្លួនមានការព្រួយបារម្ភខ្លាចសត្រូវសម្លាប់ចោលក្នុងខណៈដែលជនរួមជាតិរបស់ខ្លួនកំពុងតែស្ថិតក្នុងដៃរបស់អង្គការនៅខេត្តស្វាយរៀង ខេត្តព្រៃវែង កំពង់ចាម តាកែវ ឬតាមបណ្តោយផ្លូវរថភ្លើងបាត់ដំបងនៅតាមត្រើយសងខាងទន្លេមេគង្គ...ប៉ុន្តែគ្មានអ្វីក្រៅពីទំប៉ុង ឬបាយទេ ដែលអ្នកទាំងនេះទទួលបានពីដៃវៀតណាម ។

ខ្លឹមសារនៃចម្លើយសារភាពទាំងនេះមាននៅក្នុងសេចក្តីសម្រេចរបស់ភូមិភាគបូព៌ាចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧៧÷ "...ការវាយប្រហាររបស់យើងមិនត្រូវសំដៅទៅលើទីតាំងជាក់លាក់ឬតំបន់ណាមួយទេ ប៉ុន្តែត្រូវវាយប្រហារគ្រប់កន្លែងព្រមៗគ្នា...។ យើងត្រូវបញ្ឈប់ពួកវា បោសសម្អាតពួកវា ទោះបីជានៅលើទឹកដីវាក៏ដោយ...។ ដូច្នេះយើងត្រូវប្រុងប្រយ័ត្នរៀបចំកម្លាំងជើងគោក កាំភ្លើងធំគាំទ្រ និងកម្លាំងចាំបាញ់យន្តហោះនៅតាមព្រំដែន...។ មិនតែប៉ុណ្ណោះ យើងត្រូវស៊ើប-ការណ៍ ដើម្បីដឹងពីសភាពការណ៍ ងាយស្រួលក្នុងការវាយប្រហារឲ្យបានល្អ ។ បញ្ជាទីពីរនេះត្រូវលាក់ឲ្យជិតកុំឲ្យបែកការណ៍ ។ ក្រៅពីការបញ្ជាគឺថាទាំងទាហាននិងប្រជាជនទាំងអស់ត្រូវដឹងអំពីរឿងនេះ..."

អ្នកសរសេរបញ្ជានេះបានអួតអាងអំពីការកេងប្រវ័ញ្ចញើសឈាមដែលកងទ័ពខ្លួនបានធ្វើ÷ "នៅថ្ងៃទី៣០ ខែមេសា យើងបានដកយកពន្ធនៅប្រទេសវា (សូមអានៈ វៀតណាម ឈ្លានពាន) ដោយធ្វើឲ្យពួកវាខាតបង់យ៉ាងច្រើន ។ មានជនស៊ីវិល ៨ពាន់នាក់ត្រូវរងរបួសហើយផ្ទះ៩០ភាគរយ នៅតំបន់នោះត្រូវដុតឆេះអស់" ។ តារាងរបាយការណ៍នេះមានសរសេរនៅក្នុងសៀវភៅកំណត់ហេតុរបស់ ឈឹម ភិន មេបញ្ជាការកងអនុសេនាតូចក្នុងកងពលលេខ២៧នៃកងកម្លាំងប្រដាប់អាវុធកម្ពុជា ។ ឈ្មោះនេះបានចូលរួមប្រជុំធ្វើឡើងនៅអង្គរបុរីនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧ ។ ឈឹម ភិន បានឲ្យដឹងទៀតថា នៅថ្ងៃនោះ កងទ័ពកម្ពុជាត្រូវបានផ្តល់ជារង្វាន់លើកទឹកចិត្តដោយឲ្យស៊ីបាយតាមចិត្ត ។ រង្វាន់បែបនេះគឺជារង្វាន់លើកទី១ ហើយចាប់តាំងពីសង្គ្រាមតាមព្រំដែនប្រឆាំងនឹងវៀតណាមបានលេចចេញជារូបរាងឡើង ។

ទាហានដែលត្រូវចាប់ខ្លួនម្នាក់ទៀតបានសារភាពថា ការដេញចាប់ត្រូវបានធ្វើឡើងដោយមានប្រើពាក្យថា"ម្នាក់ចាប់៣០" ។ ពាក្យនេះគឺជាបញ្ជា ។ "ចំនួននេះមិនទាន់គ្រប់នៅឡើយទេ ។ បក្សនៅតម្រូវឲ្យយើងចាប់លើសពីនេះទៀតជួនពេលគឺ ១ចាប់៤០ឬ៥០ឯណោះ ។ នេះជាមូលហេតុដែលយើងត្រូវតែសម្លាប់ទាំងអស់មិនថាក្មេង មិនថាចាស់ មិនថាប្រុសមិនថាស្រីទេ ។ បើមិនធ្វើដូច្នេះទេ ធ្វើម៉េចទើបសម្រេចគោលដៅ?" ។ ការស្រេកឃ្លានឈាមនេះ បង្ខំឲ្យទីក្រុងភ្នំពេញបង្កើនប្រសិទ្ធភាពកងទ័ពរបស់ខ្លួនជាលំដាប់ ។ ការចាប់បង្ខំនេះត្រូវបានធ្វើឡើងនៅតំបន់ដាច់ស្រយាលបំផុតនៃប្រទេសកម្ពុជា សូម្បីតែអ្នកឈឺ ឬស្ថិតក្នុងវ័យជំទង់ក៏គ្មានលើកលែងដែរ ។

"បើគេហៅអ្នកឯងហើយ អ្នកឯងត្រូវឆ្លើយតបភ្លាម" ។

នេះជាសម្ដីរបស់យុទ្ធជនវ័យក្មេងម្នាក់ដែលយើងបានចាប់ខ្លួន ។ «ប្រសិនបើអ្នកឯងនៅអែអង់ នឹងត្រូវសម្លាប់ចោលមួយរំពេច ។ យើងបានទទួលឯកសណ្ឋាន កាំភ្លើង និងគ្រាប់រំសេវ សុទ្ធតែធ្វើនៅប្រទេសចិន ។ ក្រោយមកមិនយូរប៉ុន្មាន ប្រធានរបស់យើងបានផ្ដល់ជម្រើសឲ្យយើងពីរយ៉ាងៈ ទៅសម្លាប់វៀតណាម ឬមួយចង់ស្លាប់ ។ សម្លាប់វៀតណាមកាន់តែច្រើននឹងបានហូបចុកកាន់តែប្រសើរឡើង ។ បើអ្នកឯងមិនសម្លាប់នឹងត្រូវស្លាប់ដោយខ្លួនឯង ហើយសូម្បីតែក្រុមគ្រួសារសាច់ញាតិក៏ត្រូវស្លាប់ដែរ ។ យើងច្បាស់ជាជ្រើសរើសយក«សម្លាប់»ហើយវាគ្រាន់បើជាងស្លាប់ខ្លួនឯង ។

សួន សួយ អាយុ១៣ឆ្នាំ ជាទាហានកងអនុសេនាធំលេខ២ និង អ៊ុន សារឿន អាយុ១៦ឆ្នាំ មានដើមកំណើតនៅខេត្តព្រៃវែងជាទាហានកងអនុសេនាធំលេខ៣ កងវរសេនាតូចលេខ៨២ វរសេនាធំលេខ២ ត្រូវរងរបួសនិងចាប់ខ្លួននៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៧៨ ។ អ៊ុន សារឿន សរសេរនៅក្នុងចម្លើយសារភាពរបស់ខ្លួនថា«នៅអនុសេនាធំខ្ញុំមានកុមារអាយុ១២-១៣ឆ្នាំប្រហែលជា៣០នាក់ ។ កុមារទាំងនោះមានការលំបាកណាស់ក្នុងការស្ពាយកាំភ្លើងអាកានិងសាក់កាដូ ហើយបាយក៏មិនសូវមានហូបគ្រប់គ្រាន់ ។ សាក់កាដូនេះតែងតែទុកដាក់អំបិល ព្រោះមិនសូវមានបាយទេ ។ នៅថ្ងៃទី៥ ខែមិថុនា យើងធ្វើការតស៊ូយ៉ាងស្រួចស្រាល់ ។ យើងមានការភិតភ័យខ្លាំងពេករហូតដល់ចង់រត់ចោលការប្រយុទ្ធនៅក្នុងសមរភូមិទៀតផង ។ ប៉ុន្តែមេបញ្ជាការយើងឈ្មោះ ចៀន បានបញ្ឈប់យើងដោយបាញ់បេ៤០ដូចមនុស្សឆ្កួតអ៊ីចឹង ។ អណ្ដាតភ្លើងបេ៤០មួយគ្រាប់នេះអាចធ្វើឲ្យខ្ញុំស្ពុតស្មារតីហើយក៏លោតចូលត្រង់សេភ្លាមមួយរំពេច ។ ពេលនោះហើយខ្ញុំក៏ត្រូវរបួសជើង» ។

មា៉ ដួង អាយុ២១ឆ្នាំ ត្រូវបានចាប់ខ្លួនកាលពីថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៨ ។ ជើងរបស់ ដួង ហើមដោយសារកង្វះអាហារ ។ ពេលនោះដួងពិបាកដើរណាស់ ។ «ជើងខ្ញុំហើមស្ពុលពីព្រោះខ្ញុំហូបមិនគ្រប់គ្រាន់ ។ ខ្ញុំមានជំងឺ ប៉ុន្តែគេបង្ខំឲ្យខ្ញុំរ៉ៃដូចគេដូចឯងដែរ បើមិនអ៊ីចឹងទេ គេច្បាស់ជាសម្លាប់ខ្ញុំចោលបាត់ទៅហើយ...» ។

ទីក្រុងភ្នំពេញពូកែណាស់ខាងបំពាក់បំប៉នកម្លាំង«យុទ្ធជនវ័យក្មេង»គំបន់ឲ្យក្លាយជាពេជ្ឈឃាតស្រេកឈាមដូចវៀមច្បងរបស់ខ្លួនដែលបម្រើក្នុងជួរទ័ពទូទៅដែរ ។ យុទ្ធជនវ័យក្មេងទាំងនេះ ត្រូវបានដាក់ទណ្ឌកម្មនៅ បា ជុក ចំណែកឯអ្នកផ្សេងទៀតដូចជា អ៊ុន សារឿន ឬ សួន សួយ ត្រូវបានចាប់ខ្លួន ។ អ្នកដែលត្រូវបានចាប់ខ្លួនទាំងនេះសារភាពថាខ្លួនបានចូលរួមវាយប្រហារមកលើ បាជុក សម្លាប់ស្ត្រីនិងកូនក្មេងតូចៗ ថែមទាំងកាត់ដោះនិងវះពោះស្ត្រីទៀតផង ។ ពួកនេះបានប្រមូលប្រជាជនដាក់ក្នុងវត្ត ហើយបោកគ្រាប់បែកនិងបាញ់កាំភ្លើងអាកាបេ៤០មកលើប្រជាជនទាំងនេះធ្វើជាការលេងសើច...» ។

កម្ពុជាបង្កឲ្យជនជាតិយើងស្លាប់កាន់តែច្រើននោះ តារាងឈ្មោះជនជាតិកម្ពុជាដែលស្លាប់និងត្រូវចាប់ខ្លួនក៏ចេះតែកើនឡើងទៅតាមហ្នឹងដែរ ។ កម្ពុជាបានរត់ចោលអាវុធនៅលើសមរភូមិជាច្រើនដើមដែលផលិតនៅប្រទេសចិន មានតាំងពីកាំភ្លើងអាកា រហូតដល់កាំភ្លើង ៧៥ម.មនិង៨២ម.ម ឥតធាក់ថយ កាំភ្លើង យន្តធុនធ្ងន់១២,៧ម.ម កាំភ្លើងត្បាល់៦០ និង៨២ម.មព្រមទាំងបេ៤០និងបេ៤១ប្រឆាំងរថក្រោះជាច្រើនដើមទៀតផង ។ តើអ្នកណាជាអ្នកបង្រៀនប្រើអាវុធទាំងនេះ?

ទាហានភាគច្រើនដែលចាប់បានឆ្លើយថា «ទីប្រឹក្សាចិនជាអ្នកបង្រៀនប្រើកាំភ្លើងទាំងនេះ ដែលទើបតែផ្ដល់មកថ្មីៗ ។ ជួនកាលទីប្រឹក្សាទាំងនោះក៏ធ្លាប់បាញ់ចូលដីវៀតណាមដែរ» ។ មានទាហានកម្ពុជាភាគច្រើនគោរពបញ្ជាមេរបស់ខ្លួនទាំងការភ័យខ្លាច ចំណែកឯអ្នកផ្សេងទៀតមិនព្រមធ្វើតាមឬធ្វើជាទីទើររួញរាមិនចង់ធ្វើតាមបញ្ជា ។ អ្នកទាំងនេះនឹងត្រូវសម្លាប់ដោយគ្មានមេត្តាឡើយ ។ ទាហានម្នាក់ដែលមានវាសនារួចខ្លួនពីមេដែលរៀបសម្លាប់ខ្លួនចោលទៅហើយ បាននិយាយដំណើររឿងនេះ ។ ទាហានរូបនេះនៅពេលទៅដល់ប្រទេសវៀតណាមទាំងដៃនៅចងស្លាបសេកនៅឡើយ ។

ទាហានរូបនេះនិយាយទាំងញ័រមាត់ថា «ខ្ញុំឈ្មោះ សុទ្ធ អាយុ២៥ឆ្នាំ មានដើមកំណើតនៅខេត្តស្វាយរៀង ។ ខ្ញុំជាមេបញ្ជាការនៅកងអនុសេនាធំលេខ៨៥ វរសេនាតូចលេខ១២ វរសេនាធំលេខ១៥៧ ។ មេខ្ញុំឈ្មោះ សុល ដែលជាបញ្ជាការអនុ

សេនាធំ បានបញ្ជាខ្ញុំឲ្យដោះឯកសណ្ឋានចិនចេញ ។ ឯកសណ្ឋាននេះខ្ញុំទើបតែទទួលបានកាលពីរសប្តាហ៍មុនប៉ុណ្ណោះ ។ ខ្ញុំដឹងខ្លួនឯងថា ពេលនេះខ្ញុំត្រូវស្លាប់ហើយ...។ កាលនោះមាននាយទាហាននិងកូនទាហានចំនួន៣០នាក់នៅជាមួយខ្ញុំ ។ អ្នកទាំងអស់នោះក៏ដោះឯកសណ្ឋានចេញនិងចងស្លាបសេកដូចជាខ្ញុំដែរ ។ យើងទាំងអស់គ្នាត្រូវបានបង្ខំឲ្យឡើងឡានចិនម៉ាកថ្មីមួយគ្រឿង ។ ពេលនោះស្រាប់តែឡានឈប់ ហើយនាយទាហានម្នាក់ស្រែកថា "ពួកឯងចុះចេញពីឡានភ្លាម" ។ នេះជារបៀបថ្មីដែលគេហៅថា "វិសុទ្ធកម្ម" ជានយោបាយមួយដែលអង្គការគាំទ្រ ។ ខ្ញុំបានឃើញការសម្លាប់រង្គាលរបៀបនេះបីដងរួចមកហើយ...។ ក្នុងចំណោមសមាជិកនៅក្នុងអង្គភាពរបស់ខ្ញុំទាំង៣០នាក់ មាន១០នាក់ត្រូវបានសម្លាប់តាមរបៀបនេះ ។ នៅកងពលលេខ២៩០វិសុទ្ធកម្មត្រូវបាននិងកំពុងប្រព្រឹត្តទៅជាច្រើនខែ ។ នាយទាហាននិងពលទាហានរាប់រយនាក់នៅក្នុងកងពលនេះត្រូវបានកម្ទេចចោល...។ មិនមែនមានតែខ្ញុំម្នាក់ទេដែលស្អប់ ប៉ុល ពត និងអៀង សារី នោះ ។ ប្រជាជនទាំងអស់ស្អប់ពួកអាយ៉ងប៉េកាំងទាំងនេះណាស់ ។ ចិនកំពុងតែផ្គត់ផ្គង់អាវុធ និងសម្ភារសឹកដើម្បីវាយវៀតណាម...។ អ្នកណាហ៊ានប្រឆាំងឬគ្រាន់តែមិនសម្តែងក្តីអំណរ ព្រមទាំងអ្នកដែលហ៊ាននិយាយអាក្រក់អំពីចិន នឹងត្រូវកាត់ទោសប្រហារជីវិតភ្លាម..." ។ **គិញ ខា**

---

(**តមកពីទំព័រ២៤**) ពូ អ៊ីន និយាយថា "បញ្ចេញខ្ញុំពីណឹងទៅគេយកទៅដាក់៩៩ ហើយ៩៩ហ្នឹងក៏ខ្ទាំងអត់ទាស់ដែរ" ។ បន្ទាប់ពីការផ្លាស់ប្តូរ គុកមន្ទីរម-១៣ ពីត្រពាំងប្រាប អមលាំងទៅតាំងនៅភ្នំពេញវិញ បាន២ឆ្នាំគឺឆ្នាំ១៩៧៧ មន្ទីរ ម-៩៩ ដែលគ្រប់គ្រងដោយ តាគុល និង តាណម ក៏ត្រូវរំសាយចោលអស់ដែរ ។

ដោយមិនទាន់អស់ចិត្ត នៅដើមខែមករា ឆ្នាំ១៩៧៩ ឌុច បានមកជាន់ដីអមលាំងម្តងទៀត ។ ភាគច្រើននៃកិច្ចសម្ភាសន៍របស់ខ្ញុំជាមួយអ៊ំៗដែលមានកូនចៅត្រូវបានចាប់យកទៅបម្រើនៅមន្ទីរម-១៣របស់ ឌុច បាននិយាយប្រាប់ថា ចាប់តាំងពីកូនរបស់គាត់ត្រូវបានបំបែកពីគ្រួសារឲ្យទៅធ្វើការនៅមន្ទីរ ឌុច មិនដែលបានមកលេងផ្ទះឬក៏ផ្តល់ជាដំណឹងអ្វីនោះទេ ទើបតែនៅឆ្នាំ១៩៧៩ ប៉ុណ្ណោះដែលកូនចៅគាត់បានមកលេងផ្ទះមួយឬពីរថ្ងៃ ហើយបន្ទាប់ពីនោះក៏បាត់ដំណឹងរហូតមកដល់សព្វថ្ងៃ ។ កាលណោះដោយសារតែមានការវាយប្រហារគ្នាយ៉ាងចាស់ដៃនៅទីក្រុងភ្នំពេញ ទើបកូនចៅរបស់អ៊ំរត់គេចខ្លួន ហើយមានឱកាសមកលេងផ្ទះសម្បែង ។ ពូអ៊ីន និយាយថា "ដល់៧៩អាណឹងសួរពួកម៉ាក ខ្ញុំបានដឹងវានៅផ្ទាល់ដល់៧៩ណឹង វាថា៧៩ហ្នឹងម៉ោលេងទៀត គាត់ តាឌុច ទោឈរអាកន្លែងគុកចាស់មួយសាទៀត" ។

មិត្តសម្លាញ់របស់ពូ អ៊ីន ឈ្មោះ វឿន ដែលធ្លាប់ធ្វើជាកងការពារនៅគុកមន្ទីរម-១៣ បាននិយាយរឿងរ៉ាវអំពីការដែល ឌុច វិលមកជាន់ដីគុកមន្ទីររបស់ខ្លួនម្តងទៀតនៅដើមឆ្នាំ១៩៧៩ ហើយការសម្លាប់លើកក្រោយនេះក៏សាហាវមិនខុសពីលើកមុនប៉ុន្មានដែរ ។ ពូ អ៊ីន និយាយអំពីរឿងរ៉ាវដែល វឿន ធ្លាប់ប្រាប់គាត់ថា"...៧៩អាជិតផ្តាច់គ្នា ឌុច ទោឈរទោកាន់ហ្នឹងថា មនុស្សម្តង ហ្នឹងអាពួកម៉ាកខ្ញុំនិយាយថា ច្រើនសឹង ច្រើនជាងមុនដង ម៉ោរាប់ម៉ឺននាក់តែម្តង ទាំងខ្សែតែម្តង គិតពីពឹតឲ្យឈ្នះដៃតែម្តង... ម៉ោម៉ាសាទៀតថាសម្លាប់ខ្លាំងជាមុនទៀត ហើយរយៈពេលខ្លីផង វា(វឿន)ថា រយៈពេលខ្លីតែដល់ហើយ" ។ លោកពូ អន ហន បានឲ្យដឹងថា នៅអមលាំងនេះ វៀតណាមវាយចូលនិងកាន់កាប់បាននៅខែកុម្ភៈ ឆ្នាំ១៩៧៩ ក៏ប៉ុន្តែការសម្លាប់បានកើតឡើងរួចរាល់ហើយ គឺក្នុងអំឡុងពេលកន្លះខែមុនការចូលកាន់កាប់នេះ ។ អ្នកភូមិទំនាបអមលាំងមួយណាក៏ស្គាល់មន្ទីរ ឌុច ។ មីង ប៊ុត សែ និយាយថា "...ដើរសួរពេញគេតែហ្នឹង សួរថាត្រង់ណាមន្ទីរតា ឌុច បើមិនគេប្រាប់ឥឡូវសួរពេញតែហ្នឹងទៅដឹងពេញតែហ្នឹង" ។ ទោះបីជាអ្នកស្រុកស្គាល់ស្ទើរតែគ្រប់គ្នាហើយក៏ដោយ ប៉ុន្តែបើប្រៀបធៀបជាមួយ ឌុច គឺអ្នកស្រុកទាំងអស់នោះនៅមិនទាន់ស្គាល់ច្បាស់នៅឡើយទេ ។ មានតែអតីតប្រធានគុកមន្ទីរម-១៣ ឈ្មោះ ឌុច ម្នាក់ប៉ុណ្ណោះ ទើបស្គាល់ច្បាស់ជាងអ្នកស្រុកដែលរស់នៅទីនោះ ។

**ខ៉ាន់ថាន់ ពៅដារ៉ា**

# ជូនចំពោះ ខៀវ សំផន

លិខិតនេះជាការឆ្លើយតបទៅនឹងសំបុត្រចំហរបស់ ខៀវ សំផន ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០១ ចំពោះអ្វីដែល ខៀវ សំផន បាននិយាយថា ខ្លួន “មិនឃើញមានផលប្រយោជន៍អ្វីផង ក្នុងការកកាយរឿងចាស់មកនិយាយ” ។ ខ្ញុំសូមលើកឡើងនូវផលប្រយោជន៍មួយចំនួនដែលទាញចេញពីការយល់ឃើញរបស់ ខៀវ សំផន និងរបស់“បងៗថ្នាក់លើ”ដែល ខៀវ សំផន ប្រហែលជាមើលរំលង ដោយសារតែភាពខ្វល់ខ្វាយក្នុងការអះអាងថាខ្លួនជាជនស្លូតត្រង់ហើយគ្មានកំហុស ។

ការរំលោភបំពានដោយឃោរឃៅធ្ងន់ធ្ងរទាំងនេះ គួរតែជំរុញឲ្យសហគមន៍អន្តរជាតិដាក់ទណ្ឌកម្មប្រឆាំងទើបសមរម្យ ។ ដើម្បីកុំឲ្យអំពើអាក្រក់នេះកើតឡើងវិញនិងអស់សកម្មភាព គឺត្រូវវាយប្រហារទៅលើអ្នកដែលមានចិត្តជាមនុស្សដូចយើងរាល់គ្នាដែរ ។




ការ បំពារបំពានទាំងនេះ គឺជាការរំលោភទៅនឹងភាពថ្លៃថ្នូររបស់មនុស្សជាតិ ។ ដូច្នេះការចាប់និងការនាំខ្លួនជនដៃដល់រួមទាំង ខៀវ សំផន ផង មកកាត់ទោសចំពោះមុខតុលាការ ដើម្បីសម្តែងឲ្យឃើញនូវកំហឹងនិងការស្អប់ខ្ពើមរបស់មនុស្សជាតិទូទៅ ។ មានតែការបញ្ចេញ “ការស្អប់ខ្ពើម”របស់យើងឲ្យបានសមរម្យ និងលែងទទួលស្គាល់នូវអំពើនេះទេ ទើបយើងអាចស្តារបាននូវសណ្តាប់ធ្នាប់នៅក្នុងសង្គមនិងខ្លួនយើងផ្ទាល់ ។

ការដាក់ទណ្ឌកម្មមានលក្ខណៈស្ញប់ស្ញាត់តាមបែបទស្សនវិជ្ជា គឺជាហេតុផលមួយនៃការដាក់ទណ្ឌកម្មដើម្បីរកយុត្តិធម៌មួយ ។ យុត្តិធម៌ទាមទារឲ្យមានសំណង ។ ជនដៃដល់ដែលស្ម័គ្រចិត្តចូលខ្លួនឲ្យតុលាការជម្រះទោស និងអ្នកដែលនៅរស់គេចពីការទទួលខុសត្រូវចៀសមិនរួចត្រូវតែមានទម្ងន់ទទួលខុសត្រូវខុសគ្នាទៅតាមអំពើរបស់ខ្លួន ។ ទី១ការផ្តន្ទាទោសទាមទារឲ្យមានការនិយាយរឿងពិតនិងការទទួលខុសត្រូវរបស់ជនដៃដល់ ។ ទោះបីជាជនដៃដល់រត់គេចពីការចាប់ខ្លួនក៏ដោយក៏ដីកាចាប់ខ្លួនធ្វើឲ្យជនដៃដល់មានស្លាកស្នាមទុយ៌ស ហើយចាត់ទុកអ្នកទាំងនោះជាជនរស់នៅក្រៅសង្គម ។ តម្លៃនៃការធ្វើឲ្យមានស្លាកស្នាមទុយ៌សនិងការអាម៉ាស់មុខ ទោះបីជាវាមិនមានជារូបរាងថាអាចប៉ះពាល់បានក៏ដោយ ប៉ុន្តែមិនត្រូវមើលស្រាលឡើយ ។ ទី២ សហគមន៍នឹងត្រូវស្ថាបនាឡើងវិញជាមិនខាន នៅពេលណាដែលយុត្តិធម៌ត្រូវបានកំណត់ច្បាស់ ។ ទី៣ នៅពេលដែលយុត្តិធម៌ចេញជារូបរាងសិទ្ធិរបស់ជនរងគ្រោះនឹងត្រូវបានសងវិញដោយសមស្របក្នុងនាមជាពលរដ្ឋស្របច្បាប់ ។ បុគ្គលម្នាក់មានស្វ័យភាពមានន័យថាបុគ្គលនោះជា“មនុស្សស្របច្បាប់”ពោលគឺជាអ្នកមានសិទ្ធិនិងកាតព្វកិច្ចជាផ្លូវការ ។ ពិសេសដំណើរការព្រហ្មទណ្ឌនាំឲ្យមានការទទួលស្គាល់តាមផ្លូវច្បាប់ថាយុត្តិធម៌មិនមែនជាឯកសិទ្ធិទេ តែជាសិទ្ធិដែលប្រជាពលរដ្ឋគ្រប់រូបត្រូវតែទទួលបាន ។ ចំណុចចុងក្រោយគឺការគោរពត្រូវបានផ្តល់ដល់ជនរង

គ្រោះ ល្កុកណាសហគមន៍អន្តរជាតិចាត់វិធានការដាក់ស្តែងជួសមុខឲ្យជនរងគ្រោះ និងតំណាងឲ្យការចងចាំរបស់ជនរងគ្រោះ ។ ហេតុដូចនេះ អង្គជំនុំជម្រះស្របច្បាប់មួយនឹងបញ្ចប់រាល់ការទទួលខុសត្រូវជាបុគ្គលនិងជាសមូហភាពនៅក្នុងគោលគំនិតមួយថាអ្វីដែលគួរតែធ្វើពិតជាត្រូវធ្វើបានមែន ។ ការបញ្ចប់ការទទួលខុសត្រូវនេះទៀតសោត ក៏នឹងផ្តល់នូវលក្ខខណ្ឌដែលត្រូវតែបំពេញជាមុនសម្រាប់ឲ្យមានការលូតលាស់និងរីកចម្រើនពិតៗ ។

ជ្រុងយុត្តិធម៌មួយទៀតផ្តល់ហេតុផលថា ការដាក់ទណ្ឌកម្មនឹងចូលរួមកម្លាមិនឲ្យមានអំពើរារាំងនិងមិនឲ្យឧក្រិដ្ឋកម្មកើតឡើងនាពេលអនាគត ។ ទឡ្ហីករណ៍នេះបញ្ជាក់ច្បាស់ថា អ្នកបំពានច្បាប់សំខាន់ៗត្រូវតែបានកំណត់ឲ្យបានច្បាស់លាស់ ។ ការមិនបានដឹងនូវសេចក្តីប្រកាស និងការមិនបានដាក់ទណ្ឌកម្មដល់ជនដៃដល់គឺជាគ្រោះថ្នាក់ផ្នែកសីលធម៌ ហើយជាផលវិបាក វានឹងនាំដល់ការមិនគោរពប្រតិបត្តិច្បាប់ដោយផ្អែកតាមហេតុការណ៍ពិតនៃការសម្លាប់មនុស្សតាមអំពើចិត្ត និងរួចទោសរហូត ។

រួមសេចក្តីមក ការរំលោភបំពានទៅលើភាពថ្លៃថ្នូររបស់មនុស្សជាតិ ធ្វើឲ្យយើងមានកាតព្វកិច្ច និងមានគំនិតចង់បានយុត្តិធម៌ ព្រមទាំងជំរុញយើងឲ្យចាត់ការក្នុងរឿងនេះទៀតផង ។

ភាពចាំបាច់ខាងសីលធម៌ក្នុងការបង្កើតតុលាការគឺដូចគ្នាទៅនឹងកាតព្វកិច្ចច្បាប់ដែលបានចាក់ឫសនៅក្នុងប្រវត្តិសាស្ត្រ ។ ហេតុផលទីពីរដែលជាការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិ គឺបង្ហាញបានឥតខ្ចោះនូវយុត្តាធិការផ្លូវច្បាប់និងផ្លូវប្រវត្តិសាស្ត្រ ។ ប្រព័ន្ធច្បាប់ណាមួយក៏ដោយ ទោះជាប្រព័ន្ធច្បាប់ក្នុងស្រុកឬអន្តរជាតិ គឺត្រូវផ្អែកលើគោលគំនិតវិធាននៃច្បាប់ ។ នៅពេលដែលគោលគំនិតនេះដំណើរការចេញជារូបរាងជាក់ស្តែងហើយនោះវាពិតជាមានន័យ ។ ថ្មីៗនេះយើងមានគោលគំនិតច្រើនណាស់ ។ ប៉ុន្តែយើងនៅតែចង់បានគំនិតទាំងនេះចេញជាការអនុវត្តជាក់ស្តែង ។

ការអភិវឌ្ឍនិងការលើកកម្ពស់វប្បធម៌សិទ្ធិមនុស្ស ព្រមទាំងការគ្រប់គ្រងបែបប្រជាធិបតេយ្យ គឺជាហេតុផលទីបីឲ្យមានការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិអចិន្ត្រៃយ៍មួយ ។ ដោយផ្អែកទៅលើគោលការណ៍ការវិនិច្ឆ័យទៅលើរឿងក្តី នឹងបង្កើតបានជាកម្រងសិក្សាស្រាវជ្រាវដ៏សំបូរបែបសម្រាប់ឲ្យមានអាហារូបករណ៍លើប្រធានបទសិទ្ធិមនុស្ស បង្កើតវេទិកាពិភាក្សានិងជំរុញឲ្យមានការយល់ដឹងកាន់តែច្បាស់អំពីបញ្ហាយុត្តិធម៌ ។ បើតាមគំនិតទស្សនវិជ្ជាវិញ ការបង្កើតតុលាការដែលមានចរិតបែបនេះនឹងបង្កើនថែមទៀតទៅលើសមិទ្ធិផលនៃវប្បធម៌សិទ្ធិមនុស្សដើម្បីពង្រឹងវិធាននៃច្បាប់ ជាពិសេសគឺការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ ។ ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យនឹងធានាបាននូវភាពស្មើគ្នាក្នុងការពេញចិត្តនិងការអនុវត្តជាក់ស្តែងរបស់ប្រជាពលរដ្ឋ ។ ក៏ប៉ុន្តែ នៅពេលណាដែលច្បាប់ផ្តន្ទាទោស បទល្មើសតូចតាចឬទោសទូទៅតែបែរជាឲ្យឃាតករធំៗដើរហើរដោយសេរី និងយ៉ាងរំភើយនៅមុខប្រជាពលរដ្ឋនោះ សន្តិភាពនិងស្ថិរភាពប្រជាធិបតេយ្យច្បាស់ជាត្រូវបានបំផ្លាញ ហើយច្បាប់នឹងពិតជាក្លាយទៅជាអសារបង់មិនខានឡើយ ។ “សម្រាប់មិត្តរបស់ខ្ញុំគ្មានបញ្ហាគេចង់បានអ្វីក៏បាន ។ តែចំពោះសត្រូវរបស់ខ្ញុំវិញ ច្បាប់គឺច្បាប់” ។ គួរឲ្យសោកស្តាយណាស់ដែលមានករណីនេះកើតឡើងជាញឹកញយ ។ ប៉ុន្តែការទាក់ទាញឲ្យមានការគាំទ្រចំពោះការកែទម្រង់តាមផ្លូវនេះពិតជាមិនអាចទៅរួចទេ ។

ដូច្នេះជាការច្បាស់ណាស់ថា ការខកខានមិនបានផ្តន្ទាទោសគឺជាការបោះបង់ចោលនូវអំណាចតាមបែបប្រជាធិបតេយ្យ ។ ដូច្នេះភាពឆ្លើយតបអសកម្មជាការក្រើនរំពុកថាបាបកម្មនៃការប្រព្រឹត្តគឺជាបាបកម្មចេញពីការធ្វេសប្រហែស និងចាំបាច់តម្រូវឲ្យមានការឆ្លើយតបដែលសកម្មជាងនេះ ។ សរុបមក សហគមន៍អន្តរជាតិមានភាពចាំបាច់ផ្នែកសីលធម៌កាតព្វកិច្ចច្បាប់និងឱកាសក្នុងការបន្ថែមទៅលើវប្បធម៌សិទ្ធិមនុស្សនិងពង្រឹងវិធាននៃច្បាប់ ។

ខៀវ សំផន! ខ្ញុំសង្ឃឹមថាមតិទាំងអម្បាលម៉ានដែលខ្ញុំលើកឡើងនេះ បានស្រាយបំភ្លឺនូវផលប្រយោជន៍ដែលលោកមើលមិនឃើញ ។ ការលើកឡើងនូវភាពគ្មានទោសរបស់លោកវាយឺតពេលទៅហើយ ។ ជីវិតប្រជាជនស្លូតត្រង់ខ្មែរប្រមាណពីរលាននាក់ត្រូវបានឆក់យកបាត់ ។ ក្នុងនាមជាគ្រិស្តសាសនិកមួយរូប ខ្ញុំអាចអត់ឱនទោសឲ្យលោកដែលបានឆក់យកម្តាយឪពុកខ្ញុំទៅ ក៏ប៉ុន្តែការទាមទារយុត្តិធម៌និងហេតុការណ៍ដ៏រន្ធត់នេះនៅជក់ជាប់ក្នុងចិត្តខ្ញុំជានិច្ចគ្មានថ្ងៃបំភ្លេចបានឡើយ ។ **សេង ធារី**

# តម្លៃនៃភ័ស្តុតាង

**(តពីលេខមុន) ឃ) ខ្សែសង្វាក់នៃការបញ្ជា**

សាក្សីគួរតែផ្តល់កសិណទាក់ទងនឹងខ្សែសង្វាក់នៃការបញ្ជារបស់បក្សកុម្មុយនិស្តកម្ពុជា ប្រសិនបើអាចធ្វើទៅបាន ។ ប្រសិនបើសាក្សីនេះដឹងអំពីរបៀបរៀបចំការបញ្ជារបស់បក្សកុម្មុយ-និស្តកម្ពុជានៅតាមមូលដ្ឋានស្រុកនិងតំបន់ សាក្សីរូបនេះគួរតែនិយាយទាក់ទងនឹង÷ ១) អត្តសញ្ញាណជាក់លាក់របស់បុគ្គលដែលមានការពាក់ព័ន្ធ ២) តួនាទីរបស់បុគ្គលទាំងនោះ ៣) សារជាតិនៃរចនាសម្ព័ន្ធទូទៅនៃខ្សែសង្វាក់បញ្ជា ៤) តើការបញ្ជាទាំងនេះត្រូវបានផ្តល់ពីថ្នាក់លើមកកូនចៅថ្នាក់ក្រោមតាមរបៀបណា និង ៥) ថាតើសាក្សីសំខាន់រូបនេះបានពត៌មាននេះតាមរបៀបណា ។ ប្រសិនបើសាក្សីដឹងអំពីរឿងរ៉ាវផ្សេងៗអំពីភូមិភាគ ឬអង្គការជាតិរបស់បក្សកុម្មុយនិស្តកម្ពុជា ពត៌មាននោះក៏មានប្រយោជន៍ខ្លាំងដែរ ដែលជាការបង្ហាញថាពត៌មាននេះពិតជាចេញមកពីប្រភពដែលអាចយកជាការបាននិងអាចរកឃើញ ។

**ង) បទល្មើសជាប្រព័ន្ធ**

ចំណុចចុងក្រោយគឺថា សាក្សីសំខាន់ៗអាចមានពត៌មានសំខាន់ទាក់ទងនឹងសារជាតិជាប្រព័ន្ធនៃបទល្មើសជាក់លាក់នានារបស់បក្សកុម្មុយនិស្តកម្ពុជា ។ សាក្សីរូបនេះនឹងមានសមត្ថភាពពិសេសស្រាយបំភ្លឺអំពី÷ ១) ថាតើខ្លួនបានឃើញសមាជិកនៃបក្សកុម្មុយនិស្តកម្ពុជាប្រព្រឹត្តបទល្មើស ដូចដែលបានលើកឡើងក្នុងចំណុច(គ)តាមរបៀបណា ២) តើបទល្មើសទាំងនេះកើតឡើងនៅពេលណា ញឹកញាប់ដល់កម្រិតណា ហើយស្ថិតក្នុងវិសាលភាពភូមិសាស្ត្រប៉ុនណា និង ៣) តើមានអ្នកណាម្នាក់ប្រាប់សាក្សីអំពីបទល្មើសប្រហាក់ប្រហែលគ្នានេះនៅកន្លែងណាផ្សេងទៀតទេ ។ ប្រសិនបើសាក្សីសំខាន់ត្រូវបាននិយាយប្រាប់អំពីបទល្មើសជាប្រព័ន្ធ សាក្សីនេះគួរតែ÷ ១) រៀបរាប់របាយការណ៍ទាំងនោះ ២) បញ្ជាក់ឲ្យច្បាស់អំពីប្រភព ហើយនិង ៣) បញ្ជាក់អំពីភ័ស្តុតាងជាក់ស្តែងនៃបទល្មើសទាំងនេះ ។ តាមពិតពត៌មានក្នុងចំណុចចុងក្រោយនេះបង្កើតបានជាពាក្យចចាមអារ៉ាម ប៉ុន្តែគួរតែមានទម្ងន់នៃភ័ស្តុតាងមួយចំនួនទៀត ដូចជាភ័ស្តុតាងច្បាស់លាស់បង្ហាញពីបទល្មើសជាប្រព័ន្ធ និងមធ្យោបាយក្នុងការស៊ើបរកសាក្សីសំខាន់ៗផ្សេងទៀត ។

ប្រសិនបើសាក្សីរូបនេះធ្លាប់ឃើញ ឬឮការពន្យល់របស់មេដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជា ឬរបស់មន្ត្រីបក្សកុម្មុយនិស្តកម្ពុជានៅតាមមូលដ្ឋាន អំពីមូលហេតុដែលសមាជិកនៃបក្សកុម្មុយនិស្តកម្ពុជាប្រព្រឹត្តបទល្មើសដូចដែលបានរៀបរាប់ខាងលើ កសិណដែលមានប្រយោជន៍បំផុតគឺរួមមាន÷ ១) អត្តសញ្ញាណរបស់បុគ្គលដែលធ្វើសេចក្តីថ្លែងការណ៍នេះ ២) ពត៌មានលម្អិតអំពីសេចក្តីថ្លែងការណ៍នេះ និង ៣) ពេលវេលានិងទីកន្លែងធ្វើសេចក្តីថ្លែងការណ៍នេះ ។

មើលទៅសាក្សីសំខាន់ៗទំនងជាមិនអាចផ្តល់ពត៌មានលម្អិតគ្រប់ជ្រុងជ្រោយចំពោះអ្វីដែលខ្លួនបានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក៏ប៉ុន្តែ ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជារួមមានការត្រួសត្រាយផ្លូវឈានទៅរកមនុស្សមួយចំនួនដែលអាចមានលទ្ធភាពនិងមានឆន្ទៈចង់ផ្តល់ពត៌មានមួយចំនួនទាក់ទងនឹងលទ្ធភាពទាំងនេះ ។ ដោយប្រើសាក្សីខ្លាំងៗជាច្រើនរូប ការកាត់សេចក្តីគួរតែអាចបង្ហាញបាននូវភ័ស្តុតាងចេញពីឯកសារ និងបានពីភ័ស្តុតាងទាំងឡាយដែលមិនមានក្នុងឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

**V-ឧទាហរណ៍ការយកភ័ស្តុតាងតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា អនុវត្តប្រឆាំងនឹងជនសង្ស័យពិសេសៗមួយចំនួន**

ដោយមានចុងចោទសំខាន់ៗច្រើនសន្ធឹកសន្ធាប់នៅក្នុងការជម្រះក្តីខ្មែរក្រហម ជាការចាំបាច់ណាស់ក្នុងការបង្រួមទំហំឲ្យតូចបន្តិចក្នុងការស្រាវជ្រាវផ្នែកច្បាប់ ។ នៅក្នុងពេលខ្ញុំធ្វើការវាយតម្លៃ ខ្ញុំបានផ្តោតសំខាន់ទៅលើការទទួលខុសត្រូវលើការបញ្ជានៃមនុស្សប្រាំពីររូបដែលនៅរស់ដល់សព្វថ្ងៃ ដែលតាមពត៌មាន

ឯកសារនិងពត៌មានប្រវត្តិសាស្ត្រ អ្នកទាំងនេះមានតួនាទីទៅតាមឋានានុក្រមនៅក្នុងជួរបក្សកុម្មុយនិស្តកម្ពុជា ។ អត្តសញ្ញាណរបស់ជនប្រាំពីររូបនេះមានដូចខាងក្រោម÷

១) នួន ជា (អនុប្រធានបក្សកុម្មុយនិស្តកម្ពុជា)

២) អៀង សារី ហៅ វ៉ាន់ (ឧបនាយករដ្ឋមន្ត្រី)

៣) ឈិត ជឿន ហៅ ម៉ុក (លេខាភូមិភាគនិរតី)

៤) ខៀវ សំផន ហៅ ហែម (គណៈប្រធានរដ្ឋ)

៥) កែ ពក (ប្រធានភូមិភាគកណ្តាល)

៦) កាំង ហ្កិចអៀវ ហៅ ឌុច (ប្រធានមន្ទីរសន្តិសុខ ស-២១)

ទី៧) ម៉ម ណៃ ហៅ ចាន់ (ប្រធានអង្គភាពសួរចម្លើយនៃ មន្ទីរ ស-២១) ។

ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ជាភស្តុតាងផ្នែកច្បាប់ប្រឆាំងនឹងអតីតមេដឹកនាំនៃបក្សកុម្មុយនិស្តកម្ពុជាដែលរាយនាមនៅខាងលើនេះ ទោះបីជាកម្រាំងភស្តុតាងឯកសារមានភាពផ្សេងគ្នាពីជនសង្ស័យម្នាក់ទៅជនសង្ស័យម្នាក់ទៀតយ៉ាងណាក៏ដោយ ។ ចំណុចតូចៗដូចខាងក្រោមនេះបង្ហាញជាឧទាហរណ៍មួយចំនួននៃឯកសារនិងការទាក់ទងនឹងភស្តុតាងដែលមានស្រាប់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រឆាំងនឹងបុគ្គលដែលបានរៀបរាប់ឈ្មោះមកខាងលើ ។

***សំខាន់:*** ចំណុចតូចៗ នៅខាងក្រោមនេះមិនបង្ហាញអំពីរូបភាពទូលំទូលាយនៃភស្តុតាងដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជាប្រឆាំងនឹងបុគ្គលម្នាក់ៗដែលបានរៀបរាប់ឈ្មោះទាំងនេះទេ ។ ឯកសារខាងក្រោមនេះត្រូវបានស្រង់យកមកពីផ្នែកតូចមួយនៃឯកសារទាំងអស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមិនគួរត្រូវយកមកធ្វើជាតំណាងឲ្យឯកសារទាំងអស់ឡើយ ។ ប៉ុន្តែវាជាឧទាហរណ៍មួយចំនួនលើកឡើង ដើម្បីផ្តល់ឲ្យអ្នកអាននូវគំនិតទាក់ទងនឹងរបៀបប្រើប្រាស់ឯកសារមួយចំនួនដែលជាផ្នែកមួយនៃការកាត់សេចក្តីជាក់ស្តែង និងពីរបៀបបន្ថែមភស្តុតាងផ្សេងៗទៀតទៅលើឯកសារទាំងនេះ ។

### ក) នួន ជា

ភស្តុតាងឯកសារប្រឆាំងនឹង នួន ជា ដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា មានសារសំខាន់ណាស់ ។ ឯកសារផ្លូវការរបស់បក្សកុម្មុយនិស្តកម្ពុជា បង្កើតយ៉ាងច្បាស់លាស់នូវតួនាទីជាមន្ត្រីជាន់ខ្ពស់ដែលមានសិទ្ធិអំណាចបញ្ជាស៊ីវិល ។ ក្នុងនាមជាអនុប្រធានបក្សកុម្មុយនិស្តកម្ពុជា នួន ជា គឺជាអ្នកដែលបានទទួលឯកសារឆ្លើយឆ្លងយ៉ាងច្រើនអនេកពីកូនចៅដែលជាមន្ត្រីនៃបក្សកុម្មុយនិស្តកម្ពុជានៅថ្នាក់ក្រោម ដែលរាយការណ៍អំពី "ការបោសសម្អាត" "ការកម្ទេច" ឬ "ទារុណកម្ម" ។ ឯកសារទាំងនេះបញ្ជាក់ច្បាស់ថា នួន ជា ជាមន្ត្រីថ្នាក់លើ ហើយស្នើសុំយោបល់ពី នួន ជា ទៀតផង ។ កំណត់ហេតុប្រជុំគណៈកម្មាធិការក៏រួមមានសេចក្តីថ្លែងការណ៍របស់ នួន ជា ដែលពិភាក្សាទៅលើនយោបាយបោសសម្អាតរបស់បក្សកុម្មុយនិស្តកម្ពុជា និងស្នើឲ្យបន្តសកម្មភាពនេះឲ្យសកម្មតទៅទៀត ។ ដូចនេះឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជារួមមានភស្តុតាងដែលគួរឲ្យជឿបានថា នួន ជា ពិតជាឆ្លើយតបទៅនឹងធាតុទាំងបីនៃការទទួលខុសត្រូវលើខ្សែសង្វាក់បញ្ជា ហើយថាមានករណីមានទម្ងន់មួយចំនួនប្រឆាំងនឹង នួន ជា ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនិងទារុណកម្ម ។ ភស្តុតាងប្រយោលជាច្រើនសន្ធឹកសន្ធាប់ក៏បង្ហាញថា នួន ជា ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មសង្គ្រាម អំពើប្រល័យពូជសាសន៍ និងការបង្ខំឲ្យធ្វើពលកម្មដែរ ។

ឧទាហរណ៍មួយចំនួននៃឯកសារដែលទាក់ទង នួន ជា ដែលមានភ្ជាប់ជាមួយនឹងការពិភាក្សាសង្ខេបៗ ស្តីអំពីរបៀបប្រើប្រាស់ឯកសារនេះជាភស្តុតាងនៅក្នុងអង្គជម្រះក្តីព្រហ្មទណ្ឌ និងភស្តុតាងដែលនឹងត្រូវការបន្ថែម (ប្រសិនបើមាន) ដែលមានប្រយោជន៍ជាទីបំផុតសម្រាប់ការកាត់សេចក្តី មានដូចខាងក្រោមនេះ÷

១) "សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមទៅលើបញ្ហាជាច្រើន" ថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ (ប្រែសម្រួលនិងបោះពុម្ពផ្សាយសាជាថ្មីនៅក្នុងសៀវភៅ "ប៉ុល ពត ធ្វើផែនការសម្រាប់អនាគត" ដែលនិពន្ធដោយលោក ដេវីដ ឆេនដល័រ) ។

ក) ចំណុចទី១ចែងថា "អំណាចក្នុងការកម្ទេច(មនុស្ស) នៅក្នុងជួរនិងក្រៅជួរ" ។ ដូចនេះ គណៈកម្មាធិការមជ្ឈិមថ្លែងថា អង្គការខាងក្រោមនេះមានអំណាចកម្ទេចមនុស្សនៅក្នុងជួរនិង

ក្រៅជួរ ក្រោមដែនកំណត់របស់ខ្លួន÷ ១)គណៈកម្មាធិការអចិន្ត្រៃយ៍ភូមិភាគ ២)គណៈកម្មាធិការមន្ទីរមជ្ឈិម ៣)គណៈកម្មាធិការតំបន់ឯករាជ្យ និង ៤)មន្ទីរសេនាធិការនៃកងកម្លាំងប្រដាប់អាវុធមជ្ឈិម ។ ឯកសារនេះគឺជាភស្តុតាងមានទម្ងន់បញ្ជាក់ថា នួន ជា ដែលជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបានដឹងពុអំពីអំណាចរបស់បក្សកុម្មុយនិស្តកម្ពុជាក្នុងការកម្ទេចមនុស្ស និងបានចូលរួមចំណែកក្នុងអំណាចនោះដែរ ។ ឯកសារនេះបង្ហាញអំពីបំណងឧក្រិដ្ឋប្រឆាំងនឹងរាល់ការកម្ទេចរបស់បក្សកុម្មុយនិស្តកម្ពុជាដែលអនុវត្តទៅតាមប្រការទាំងឡាយនៃចំណុចទីមួយ ។

ឯកសារនេះក៏បង្ហាញថា នួន ជា បំពេញតាមតម្រូវការ "អំពើពិរុទ្ធ"ចំពោះការទទួលខុសត្រូវលើការបញ្ជា ដោយសារខ្លួនបានបញ្ជាកូនចៅឲ្យកម្ទេចប្រជាជន ។

ខ) ចំណុចទី៦ប្រកាសថា កងកម្លាំងប្រដាប់អាវុធ "វាយកម្ទេច"មហាវិហារគ្រិស្ត ។ ដូច្នេះ ក្នុងនាមជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស នួន ជា បានចូលរួមនៅក្នុងផែនការបំផ្លិចបំផ្លាញមហាវិហារគ្រិស្តនេះ ដែលជាការផ្តល់ភស្តុតាងគ្រួសៗបង្ហាញថា នួន ជា និងអ្នកដទៃទៀត រិះរកមធ្យោបាយលុបបំបាត់គ្រិស្តសាសនានៅក្នុងប្រទេសកម្ពុជា ។

គ) នួន ជា ត្រូវបានឲ្យឈ្មោះថា "ប្រធានរដ្ឋសភា" ដែលជាអង្គការតំណាងឲ្យរដ្ឋាភិបាលថ្នាក់មជ្ឈិម ។ តួនាទីរបស់ នួន ជា ជាប្រធានរដ្ឋសភា គឺជាភស្តុតាងបង្ហាញថា នួន ជា បានកាន់កាប់មុខតំណែងដឹកនាំខ្ពស់ ហើយមានលក្ខណៈបង្ហាញដូវបញ្ជាក់អំពីអាជ្ញាបញ្ញាស៊ីវិល"តាមច្បាប់"និង"ព្រឹត្តិន័យ" ។

### ២) កំណត់ហេតុអំពីទស្សនកិច្ច[របស់គណៈកម្មាធិការ] អចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ ១៩៧៥:

ក) សំណេរខាងក្រោមនេះមាននៅក្នុងរបាយការណ៍អំពីសភាពការណ៍រួមនៅមូលដ្ឋានៈ"...ពួកថៃបានចូលមកធ្វើស្រែក្នុងដីយើងចម្ងាយ៣គ.ម ។ យើងកំពុងដេញកម្ចាត់" ។ ពាក្យថា "កំពុងដេញកម្ចាត់"ជនជាតិថៃមិនគ្រប់គ្រាន់សម្រាប់បង្កើតជាបទឧក្រិដ្ឋទេ ។ ប៉ុន្តែចេតនារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ក្នុងការសម្លាប់ជនស៊ីវិលថៃ ដោយសារតែជនស៊ីវិលទាំងនោះចូលមកធ្វើស្រែ បង្ហាញឲ្យឃើញភស្តុតាងប្រយោលមួយចំណែកដែលបញ្ជាក់ថាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍រួមទាំង នួន ជា ផង បានយល់ព្រមនិងបញ្ជាឲ្យមានការសម្លាប់មនុស្សដែលជាការរំលោភទៅលើច្បាប់អន្តរជាតិនៅក្នុងជម្លោះរបស់ខ្លួនជាមួយនឹងប្រទេសថៃ ។

ខ) វគ្គដាក់ថាៈ "សភាពការណ៍ខ្មាំង"បង្ហាញពីការប៉ះទង្គិចតាមព្រំដែនជាមួយប្រទេសថៃនៅក្នុងខែសីហា ឆ្នាំ១៩៧៥ ។ ខាងខ្មែរក្រហមដែលកំពុងរង់ចាំមើលសកម្មភាពរបស់ខ្មាំង បានរាយការណ៍អំពីការក្រវែលរបស់យន្តហោះថៃនៅតាមព្រំប្រទល់ និងការជ្រៀតចូលរបស់ក្រុមជនជាតិថៃតូចៗ និងបានស្ទាក់បាញ់អ្នកដែលជ្រៀតចូលទាំងនោះ ។ គណៈកម្មាធិការក៏បានរាយការណ៍អំពីសកម្មភាពវិទ្ធង្សនា តាមរយៈការបាចខិត្តប័ណ្ណនៅភ្នំម៉ាល័យ ។ ទោះបីជាខ្លឹមសារនេះមិននិយាយរៀបរាប់លម្អិតអំពីឧក្រិដ្ឋកម្មអន្តរជាតិក៏ដោយ ក៏ប៉ុន្តែវាបានបង្ហាញថា ជម្លោះប្រដាប់អាវុធពិតជាកើតមានឡើងរវាងប្រទេសថៃនិងកម្ពុជានៅដើមខែសីហា ឆ្នាំ១៩៧៥ (យ៉ាងហោចណាស់ក៏នៅក្នុងក្រសែភ្នែករបស់សមាជិកនានានៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនិស្តកម្ពុជាដែលរួមទាំង នួន ជា ផង) ។ ទោះបីជារបាយការណ៍នេះមិនបានបង្ហាញថាជម្លោះប្រដាប់អាវុធបានរាលដាលហួសពីតំបន់ព្រំប្រទល់យ៉ាងណាក៏ដោយ ក៏ការកើតឡើងនូវជម្លោះប្រដាប់អាវុធអាចទាក់ទងក្នុងការចោទប្រកាន់មន្ត្រីបក្សកុម្មុយនិស្តកម្ពុជាមួយចំនួនអំពីបទឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងប្រហែលអាចជាការបំផ្លាញទ្រព្យសម្បត្តិវប្បធម៌ផង ។

គ) វគ្គនិយាយពីសកម្មភាពនៅខាងក្នុងបន្ទរាយការណ៍អំពីសកម្មភាពទាក់ទងរបស់ថៃក្នុងការបំផុសឲ្យប្រជាជន[កម្ពុជា] រត់ចេញពីប្រទេស ។ វគ្គនេះនិយាយថាវា(ខ្មែរបង្កប់) ធ្វើសង្គ្រាមចិត្តសាស្ត្រធ្វើវិទ្ធង្សនា" ។ របាយការណ៍បានបន្តទៀតថា"ខាងជួរយើងដែលសម្រិតសម្រាំងមិនទាន់អស់ក៏នៅមាន ។ ....យើងចាប់វាបានជាបន្តបន្ទាប់ ហើយកំពុងបន្តរាវរកទៀត" ។ នេះបញ្ជាក់ថា ចាប់ពីខែសីហា ឆ្នាំ១៩៧៥ សមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជាជឿថា យុទ្ធនាការ

សង្គ្រាមចិត្តសាស្ត្រផ្ទៃក្នុងពិតជាមានមែន ។ ភាសាដែលប្រើនៅក្នុងរបាយការណ៍នេះបង្ហាញថាបក្សកុម្មុយនិស្តកម្ពុជាមិនបានបែងចែកឲ្យបានច្បាស់ទេថាតើអ្នកណាជាខ្មាំងប្រដាប់អាវុធថៃ ហើយអ្នកណាជាខ្មាំង«ចិត្តសាស្ត្រ»នោះ ។ អង្គហេតុនេះអាចជួយឲ្យការកាត់សេចក្តីបង្កើតនូវទស្សនាទានទូលំទូលាយមួយចំពោះសង្គ្រាមដែលធ្វើឡើងដោយបក្សកុម្មុយនិស្តកម្ពុជាប្រឆាំងនឹងប្រទេសថៃ ។

ឃ) នៅក្នុងវគ្គ«ដំណើរការការពារប្រទេស»របាយការណ៍នេះបានលើកឡើងថា«បញ្ហាគន្លឹះគឺដោះស្រាយសភាពការណ៍នយោបាយរបស់ប្រជាជន ។ របាយការណ៍នេះបញ្ជាឲ្យរដ្ឋអំណាចបដិវត្តគ្រប់គ្រងប្រជាជនឲ្យបានល្អលើគ្រប់ផ្នែកនយោបាយ សតិអារម្មណ៍និងចាត់តាំង» ។ បើធ្វើដូច្នេះ«គ្មានខ្មាំងណាមកវាយយើងបានទេ» ។ បន្ទាប់មករបាយការណ៍នេះ និយាយអំពីរបៀបពង្រីក«សហករណ៍យើង» ។ សេចក្តីថ្លែងនៅក្នុងវគ្គនេះផ្តល់ជាភ័ស្តុតាងច្រើនប្រភេទ ។ ទី១ ផ្តល់នូវភ័ស្តុតាងថាៈគណៈកម្មាធិការអចិន្ត្រៃយ៍មានវិធានការបញ្ជាមួយចំនួនទៅលើសហករណ៍មូលដ្ឋាន ហើយជួយបង្ហាញនយោបាយទ្រង់ទ្រាយធំនៅក្នុងសហករណ៍ ។ ទី២ សេចក្តីថ្លែងនេះបញ្ជាក់ថានយោបាយសតិអារម្មណ៍ និងការចាត់តាំងរបស់ប្រជាជន នឹងត្រូវបានគ្រប់គ្រងដោយបង្ហាញពីៈ ១) ការបង្ខំឲ្យធ្វើការជាទម្ងន់ដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងអំពើទាសភាព និង ២) ចេតនាក្នុងការចូលរួមអនុវត្តការបង្ក្រាបផ្នែកនយោបាយ ។ នៅចំណុចចុងក្រោយក្នុងគោលបំណងការពារជាតិ សេចក្តីថ្លែងទាំងនេះបន្ថែមទម្ងន់ទៅលើសញ្ញាណដែលថា«ខ្មាំង»រួមមានភ្នាក់ងារបង្កប់ផ្ទៃក្នុងដែលសកម្មភាពរបស់ខ្លួនត្រូវបក្សកុម្មុយនិស្តកម្ពុជាចាត់ទុកថាជាការពង្រីកកម្លាំង និង/ឬនាំដល់ជម្លោះប្រដាប់អាវុធ ។

ង) វគ្គនេះដែលនិយាយអំពីវិស័យការពារជាតិ ក៏បាននិយាយដែរអំពីតួនាទីរបស់សហករណ៍«ក្នុងសង្គ្រាម»ក្នុងការផ្តល់កម្លាំងគ្រប់យ៉ាងដើម្បីវាយឈ្នះចក្រពត្តិអាមេរិក» ។ សំណេរនៅក្នុងអត្ថន្ទរនេះបង្ហាញជាភ័ស្តុតាងថា សហករណ៍ត្រូវបានថ្នាក់ដឹកនាំបក្សកុម្មុយនិស្តកម្ពុជាចាត់ទុកថាជាម៉ាស៊ីនចលករយ៉ាងសំខាន់នៅក្នុងការធ្វើសង្គ្រាមប្រឆាំងនឹងចក្រពត្តិអាមេរិក ។ អង្គហេតុនេះពង្រឹងទឡ្ហីករណ៍ដែលថាខ្មាំងផ្ទៃក្នុងនិងខាងក្រៅ»ត្រូវបានបក្សកុម្មុយនិស្តកម្ពុជា ប្រព្រឹត្តមកលើខុសគ្នាតិចតួចប៉ុណ្ណោះ ។ បក្សកុម្មុយនិស្តកម្ពុជាគិតថាខ្លួនស្ថិតនៅក្នុងសង្គ្រាមជាមួយ«ខ្មាំង»របស់ខ្លួនទាំងក្នុងនិងក្រៅស្រុក ។

ច) នៅក្នុងរបាយការណ៍ គណៈកម្មាធិការអចិន្ត្រៃយ៍បានណែនាំឲ្យសហករណ៍«ស្រូបប្រជាជនថ្មីចេញពីទីក្រុងទាំងអស់»ឲ្យធ្វើការតាមសហករណ៍នានា ។ សេចក្តីដកស្រង់នេះបង្ហាញថាគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនិស្តកម្ពុជាមានចេតនាចង់បង្ខំប្រជាជនឲ្យធ្វើការឆ្ងាយពីភូមិដ្ឋានរបស់ខ្លួនទោះបីជាប្រជាជនមិនពេញចិត្តក៏ដោយ ។ ទង្វើនេះបង្កើតបានជាការអនុវត្តមួយមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងអំពើទាសភាព ហើយដោយរួមជាមួយនឹងភ័ស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ ដែលបង្ហាញអំពីការជម្លៀសមនុស្សទាំងហ្វូងៗ និងបង្ខំឲ្យធ្វើការជាទម្ងន់ ទង្វើនេះបង្កើតបានជា«បំណងឧក្រិដ្ឋ»របស់ នួន ជា និងអ្នកដទៃទៀត ។

## ៣) ឯកសារអ្នកទោស ជួត ញ៉ៅ

អ្នកសួរចម្លើយពីរនាក់ ម្នាក់ឈ្មោះ ហម និងម្នាក់ទៀតឈ្មោះ ដេន បានសរសេរថា របាយការណ៍មួយចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៧៧ ហើយផ្ញើជូន សុន សេន ដោយភ្ជាប់ជាមួយនូវឯកសារចម្លើយសារភាពមួយចំនួន រួចហើយផ្ញើជូន នួន ជា ដែលជាថ្នាក់ដឹកនាំថ្នាក់លើ ។ របាយការណ៍នេះនិយាយថា«...ក៏បានធ្វើទារុណកម្មខ្លះ ទើបវាសុខចិត្តទទួលខ្លួនរ៉ាក្សត់» ។ ក្រោយមកទៀតនៅពេលដែល ជួត ញ៉ៅ និយាយមិនច្បាស់ ហម និង ដេន «ក៏ធ្វើទារុណកម្មខ្លះទៀត» ។ ភាសាដែលស្តែងចេញមកនេះគឺមានលក្ខណៈច្បាស់ណាស់ ហើយត្រូវទៅនឹងនិយមន័យច្បាប់នៃពាក្យ«ទារុណកម្ម»ពីព្រោះភាសានេះត្រូវបាននិយាយចេញដោយមន្ត្រីរដ្ឋាភិបាលសម្រាប់ជម្រិតយកចម្លើយ ។ ឧបមាថា នួន ជា មិនបានដាក់ទណ្ឌកម្មដល់ ហម និង ដេន ចំពោះទង្វើរបស់ខ្លួន ។ បើយ៉ាងដូច្នេះមែនឯកសារនេះបង្កើតបានជាធាតុផ្សំយ៉ាងសំខាន់ក្នុងការទាញឲ្យ នួន ជា ទទួលខុសត្រូវចំពោះអំពើទារុណកម្ម ។

## ៤) ឯកសារចុះថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៨

នៅក្នុងរបាយការណ៍ស្តីអំពី«សភាពការណ៍ខ្មាំងខាងក្នុង» សែ បាននិយាយថា «យើងកំពុងបន្តបោសសម្អាតពួកអានៅសេសសល់ជាបន្តទៀត ។...ឯនៅតំបន់១០៣ យើងបានដំណើរការបោសសម្អាតខ្មាំងបង្កប់ស៊ីរូង» ។ របាយការណ៍នេះត្រូវបានចម្លងជូន នួន ជា និង អៀង សារី សេចក្តីថ្លែងខាងលើនេះបង្ហាញថា សមាជិកក្នុងជួរខ្មែរក្រហមដែលប្រឆាំងជាលក្ខណៈនយោបាយ ទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យកំពុងត្រូវបានវែកមុខនិងសម្លាប់ចោល ។ ឧបមាថា នួន ជា និង អៀង សារី មិនបានប្រឹងប្រែងរកវិធីដាក់ទណ្ឌកម្មឬក៏បញ្ឈប់«ការបោសសម្អាត» ។ បើយ៉ាងដូច្នេះមែន ឯកសារនេះបង្កើតបានជាធាតុផ្សំទាញថា ទាំង នួន ជា និង អៀង សារី ពិតជាមានការទទួលខុសត្រូវក្នុងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

**៥) កំណត់ហេតុសរសេរដោយដៃចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៨**

អ្នករាយការណ៍សរសេរថា ពួកចារកម្មចូលតាមព្រំដែនកម្ពុជាហើយ«យើងកម្ទេចមួយចំនួនរួច មួយចំនួន» ។ របាយការណ៍នេះត្រូវបានចម្លងជូន នួន ជា និង អៀង សារី ដាក់ថាពួកចារកម្មត្រូវបានកម្ទេច ។ ត្រង់ចំណុចនេះនៅមិនទាន់ច្បាស់នៅឡើយថា តើពួកចារកម្មត្រូវបានសម្លាប់នៅក្នុងន័យជម្លោះប្រដាប់អាវុធឬក៏យ៉ាងណានោះទេ ប៉ុន្តែជាការច្បាស់នោះ គឺថាពួកចារកម្មត្រូវបានសម្លាប់ដោយមូលដ្ឋានជនជាតិ ឬការពាក់ព័ន្ធផ្នែកនយោបាយ ។ បើមានភស្តុតាងផ្សេងទៀត អាចបញ្ជាក់ថាពួកចារកម្មគ្មានកាន់អាវុធ ឬត្រូវបានចាប់ជាឈ្លើយនោះ ទង្វើទាំងអស់នេះនឹងចូលក្នុងធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (និងប្រហែលជាឧក្រិដ្ឋកម្មសង្គ្រាម) ដោយសន្មតថា នួន ជា និង អៀង សារី មិនបានដាក់ទណ្ឌកម្មដល់អ្នកសរសេររបាយការណ៍នេះ ឬមន្ត្រីកម្ពុជាប្រជាធិបតេយ្យផ្សេងទៀតដែលទទួលខុសត្រូវចំពោះការសម្លាប់ចារកម្មទាំងនេះ ។

**(នៅមានត)**

**ចន ឆរធីអារី**



ប៉ុល ពត    នួន ជា    អៀង សារី    វន វេត    សុន សេន

# តុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍

**(តពីលេខមុន)** កត្តាទី៤ អ្នកគាំទ្រទង្វើអសកម្មនេះសួរថាអ្នកណាខ្លះនឹងត្រូវយកមកកាត់ទោស ។ ទ្រឹស្តី "ហ្វូងមនុស្សឥតសណ្តាប់ធ្នាប់" ធ្វើឲ្យមានជនដៃដល់ច្រើន ។ មានមន្ត្រីរបស់រដ្ឋដែលបានចេញបញ្ជា ហើយបន្ទាប់មកមានមនុស្សជាច្រើនជាអ្នកអនុវត្តបញ្ជាទាំងនោះ ។ មានទាំង"មនុស្សដែលគ្មានសីលធម៌" និង "មនុស្សមិនល្អ" ។ មនុស្សដែលគ្មានសីលធម៌ធ្វើឱ្យបង្កឲ្យមានលក្ខខណ្ឌនានាដែលនាំឲ្យមនុស្សមិនល្អប្រព្រឹត្តអំពើអសីលធម៌ ។ ហេតុដូចនេះ តើត្រូវបែងចែកការដាក់ឲ្យទទួលខុសត្រូវចំពោះអំពើទាំងនេះយ៉ាងដូចម្តេច? ប៉ុន្តែបញ្ហាទាំងនេះកើតឡើងនៅគ្រប់កន្លែងទាំងអស់នៅក្នុងច្បាប់ ។ បញ្ហាគឺតម្រូវឲ្យមានតុល្យភាពខាងផលប្រយោជន៍ និងភាពត្រឹមត្រូវតាមផ្លូវតុលាការ ។

សរុបមក អ្នកមិនអើពើ(ការឆ្លើយតបអសកម្ម) ត្រូវរំឭកឡើងវិញថាបាបកម្មនៃការប្រព្រឹត្តមិនខុសគ្នានឹងបាបកម្មនៃការបំភ្លេចទោសឧក្រិដ្ឋ និងចាំបាច់តម្រូវឲ្យឆ្លើយតបដែលសកម្មជាងនេះ ។

ការឆ្លើយតបមួយទៀតរបស់សហគមន៍អន្តរជាតិគឺការយល់ព្រមតាមរដ្ឋាភិបាលរបស់ជាតិក្នុងការកាត់ទោសជនដៃដល់តាមដែនសមត្ថកិច្ចរបស់ខ្លួន ។ មែកធាងមួយនៃការឆ្លើយតបប្រភេទនេះនិយាយថា "តុលាការចម្រុះ"ត្រូវបង្កើតឡើងដោយមានការជួយជ្រោមជ្រែងពីសំណាក់សហគមន៍អន្តរជាតិ ។ ភាពឆ្លើយតបនេះពិតជាមានការគោរពយ៉ាងខ្លាំងទៅដល់អធិបតេយ្យភាពរបស់រដ្ឋ ។ ក្នុងករណីដែលរដ្ឋមិនបានចូលរួមគំនិតប្រព្រឹត្តអំពើឃោរឃៅ ហើយតុលាការមានឯករាជ្យភាពពិតប្រាកដ និងមានសមត្ថភាពដើម្បីទប់ទល់នឹងការសមគំនិតនេះ គួរតែរៀបចំឲ្យមានដំណើរការតុលាការបែបនេះ ។ ប៉ុន្តែនៅតែជាការងឿងឆ្ងល់និងភាពមិនអាចទៅរួចថាតើប្រព័ន្ធដែលនាំឲ្យមានអំពើឃោរឃៅកើតឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនមានសមត្ថភាពគ្រប់គ្រាន់ និងមានឯករាជ្យភាពក្នុងការកាត់សេចក្តីឧក្រិដ្ឋសង្គ្រាមតាមច្បាប់អន្តរជាតិដែរឬទេ? ការបង្ហាញពីអំពើឃោរឃៅដែលប្រព្រឹត្តជាផ្លូវការ ពិតជាមានបញ្ហាលើសពីនេះថែមទៀត ។ ឧទាហរណ៍ឧក្រិដ្ឋជនមួយចំនួនដែលបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដាគឺជាជនដៃដល់ដែលមានតួនាទីនៅក្នុងរដ្ឋាភិបាល ។ ប្រសិនបើសហគមន៍អន្តរជាតិអនុញ្ញាតឲ្យដំណើរការរឿងក្តីព្រហ្មទណ្ឌស្ថិតនៅក្នុងដៃរបស់រដ្ឋាភិបាល យុត្តិធម៌នឹងមិនអាចកើតឡើងក្នុងប្រទេសមួយនេះបានឡើយ ។ ដូច្នេះ បញ្ហាស្របច្បាប់និងធម្មនុញ្ញភាពទាំងអស់នេះនឹងបង្កឲ្យមានការលំបាកចំពោះអ្នកគាំទ្រឲ្យមានតុលាការក្នុងស្រុក ។

នៅក្នុងប្រទេសកម្ពុជា អង្គការសហប្រជាជាតិបានស្ទង់ប្រមើលមើលប្រព័ន្ធច្បាប់ក្នុងស្រុក ហើយយល់ថារដ្ឋនេះខ្វះសមត្ថភាពមិនអាច បង្កើតតុលាការមួយស្របច្បាប់សម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហមបានទេ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ អង្គការសហប្រជាជាតិអាចសម្របតាមការអះអាងអំពីអធិបតេយ្យភាពរបស់រដ្ឋាភិបាលកម្ពុជាដែលជាការគួរឲ្យសោកស្តាយ ។ មានការទាញសេចក្តីសន្និដ្ឋានយ៉ាងមាំទាំថា តុលាការជាតិនឹងនាំឲ្យមានការសោកស្តាយ ហើយនឹងមិននាំឲ្យមានយុត្តិធម៌ពិតប្រាកដឡើយ ។ ទី១គឺថា "នីតិរដ្ឋ" ដែលដឹងជ្រួតជ្រាបនិងជាអ្នករៀបចំសណ្តាប់ធ្នាប់សង្គមនិងទំនាក់ទំនងសង្គមនោះជាក់ស្តែងមិនមានឡើយ ។ ប៉ុន្តែរដ្ឋនេះបែរជាបង្កើតឲ្យមានវប្បធម៌រួចទោសទៅវិញ ។ ដូចនេះ នៅក្នុងប្រទេសកម្ពុជាដើម្បីឲ្យមានអំណាចពិតប្រាកដគឺត្រូវមានការរួចទោសស្របតាមផ្លូវច្បាប់ ។ ទី២ ជនដៃដល់ដែលត្រូវបានចោទប្រកាន់ គឺជាផ្នែកមួយនៃក្បាលម៉ាស៊ីនដឹកនាំរដ្ឋាភិបាល ហើយដែលសព្វថ្ងៃកំពុងតែទទួលភាពរួចទោស ។ ទី៣ តុលាការខ្វះឯករាជ្យភាពនិងសមត្ថភាព ។ ប្រសិទ្ធភាពនៃតុលាការគឺពឹងផ្អែកលើភាពគួរឲ្យទុកចិត្តបាន និងមានកិត្យានុភាពនៅក្នុងចំណោមមហាជន ។ ជាទូទៅការបាត់បង់នូវសេចក្តីគោរពគឺស្តែងចេញពីចេតនា ។ នៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន បើគ្មានតុលាការដែលមានចរិតជាអន្តរជាតិទេនោះ យុត្តិធម៌ពិតជាគ្មានរូបរាងទេ ។

គណៈកម្មាធិការស្វែងរកការពិតនិងការផ្សះផ្សាជាតិនៅប្រទេសអាហ្វ្រិកខាងត្បូង គឺជាឧទាហរណ៍បញ្ជាក់ពីមធ្យោបាយទី៣ ដែលប្រទេសមួយចំនួនបានឆ្លើយតបទៅនឹងព្រហ្មទណ្ឌក្រោមច្បាប់អន្តរជាតិ ។ គណៈកម្មាធិការទាំងពីរនេះផ្តោតការយកចិត្តទុកដាក់សំខាន់ទៅលើការនិយាយអំពីការពិតដើម្បីឲ្យមានការលើកលែងទោស ជាប្រយោជន៍ក្នុងការជួយជំរុញឲ្យមានការផ្សះផ្សាសង្គមមួយដែលកំពុងតែមានភាពបែកបាក់ ។ ប៉ុន្តែប្រសិទ្ធភាពនៃការឆ្លើយតបនេះប្រហែលជាចេញមកពីកាលៈទេសៈតម្រូវឲ្យនិងវប្បធម៌ ។ គំនិតរបស់ជនជាតិអាហ្វ្រិកខាងត្បូងស្បែកខ្មៅ"អ៊ូប៊ុនទូ"ដែលសុខចិត្តឲ្យមានការផ្សះផ្សា សុខចិត្តលះបង់យុត្តិធម៌បានទទួលនូវជោគជ័យ ។ គណៈកម្មាធិការស្វែងរកការពិតត្រូវបានបង្កើតឡើងនៅអាមេរិកឡាទីន ប៉ុន្តែទទួលបានជោគជ័យបន្តិចបន្តួចតែប៉ុណ្ណោះ ។ ឧទាហរណ៍ជាក់ស្តែង គណៈកម្មាធិការស្វែងរកការពិតនៅប្រទេសហៃទីមិនដែលចេញផ្សាយនូវរបាយការណ៍របស់ខ្លួនទេ ហើយថែមទាំងបង្វែរការយកចិត្តទុកដាក់នឹងឯកសារដែលប្រមូលបានចេញពីការកាត់ទោសទៀតផង ។ ជាងនេះទៅទៀតគណៈកម្មាធិការស្វែងរកការពិតមិនអាចដោះស្រាយប្រកបដោយការពេញចិត្តនូវការរំលោភដ៏ធ្ងន់ធ្ងរនៃព្រហ្មទណ្ឌប្រល័យពូជសាសន៍និងព្រហ្មទណ្ឌសង្គ្រាមបានទេ ដោយសារគណៈកម្មាធិការទាំងនេះឲ្យសិទ្ធិទៅ


តុលាការប្រជាជនបដិវត្តន៍កម្ពុជា ឆ្នាំ១៩៧៩ សវនាការកាត់ទោសបទប្រល័យពូជសាសន៍ ប៉ុល ពត អៀង

លើតែការលើកឡើងនូវផលវិបាកដែលកើតឡើងក្រោយពីការប្រព្រឹត្តនិងការស្ម័គ្រចិត្តឡើងមករៀបរាប់រឿងរ៉ាវតែប៉ុណ្ណោះ ។ ដូច្នេះឃើញថា ការផ្តល់ការលើកលែងទោសចំពោះជនដែលដឹ



ឃោរឃៅ អាចបង្កឲ្យមានកំហឹងសាធារណៈក្នុងការប្រានចោលទុកជាមុននូវការផ្សះផ្សាជាតិ ។

ការឆ្លើយតបទី៣ដំបូងចំពោះសហគមន៍អន្តរជាតិបានយល់ព្រមចំពោះបូរណភាពរបស់រដ្ឋ ។ ការឆ្លើយតប២ទៀតឲ្យតម្លៃទៅលើមនុស្សជាតិដោយសុខចិត្តលះបង់ស្វ័យភាពរបស់រដ្ឋ ។

ការឆ្លើយតបទី៤ដែលបានឆ្លើយតបទៅនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សនៅក្នុងប្រទេសដទៃទៀតនោះ បានទទួលយកនូវការចាត់វិធានការជាឯកតោភាគី ។ ការចាប់ខ្លួនយ៉ាងក្លាហានរបស់ប្រទេសអេស្ប៉ាញទៅលើរូបឧត្តមសេនីយ៍ ពីណូចេ នៃប្រទេសឈីលី បង្ហាញឲ្យឃើញពីការពង្រីកនិងស៊ីជម្រៅទៅលើវប្បធម៌សិទ្ធិមនុស្សចាប់តាំងពីវប្បធម៌នេះចាប់កំណើតក្រោយពីសង្គ្រាមលោកលើកទី២មក ។ ករណីនេះបង្ហាញឲ្យឃើញពីភាពខុសគ្នារវាងការអនុវត្តច្បាប់និងការប្រព្រឹត្តបទឧក្រិដ្ឋ ហើយលើកឡើងនូវបញ្ហាមួយចំនួនទាក់ទងទៅនឹងអភ័យឯកសិទ្ធិផ្នែកការទូត ។ ទី១ ក្រោយពីការចាប់ខ្លួន ឧត្តមសេនីយ៍ ពីណូចេ មិនបានបដិសេធការទទួលខុសត្រូវរបស់ខ្លួនចំពោះការប្រព្រឹត្តអំពើមនុស្សឃាតនិងអំពើទារុណកម្មឡើយ ។ ពីណូចេ គ្រាន់តែអះអាងថាការប្រព្រឹត្តរបស់លោកមានហេតុផលសមរម្យនិងមានលក្ខណៈស្របច្បាប់ ។ ទី២ តើអភ័យឯកសិទ្ធិរបស់លោក ពីណូចេ ដែលត្រូវបានលើកឡើងកើតឡើងដោយសារឋានៈរបស់លោកជាអតីតប្រមុខរដ្ឋ ឬក៏កើតឡើងដោយសារឋានៈសព្វថ្ងៃជា“សមាជិកព្រឹទ្ធសភាអស់មួយជីវិត”នៅក្នុងប្រទេសឈីលី? អនុសញ្ញាទីក្រុងវីយែនស្តីពីទំនាក់ទំនងការទូត(១៩៦១) ធ្វើឲ្យភាពផ្សេងគ្នានេះក្លាយជាគ្មានន័យ ។ អនុសញ្ញានេះចែងថា “គោលបំណងនៃសិទ្ធិនិងអភ័យឯកសិទ្ធិនេះគឺមិនមែនចែងឡើងដើម្បីផ្តល់ផលប្រយោជន៍ចំពោះបុគ្គលឡើយ ប៉ុន្តែគឺដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនៃបេសកកម្មការទូតតែប៉ុណ្ណោះ ។ សិទ្ធិនិងអភ័យឯកសិទ្ធិនេះមិនមែនបង្កើតឡើងដើម្បីរារាំងមិនឲ្យមានការកាត់សេចក្តីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬអំពើឃោរឃៅផ្សេងៗទៀតនោះទេ ។ ទី៣ ប្រទេសឈីលីបានផ្តល់ការលើកលែងទោសដល់ឧត្តមសេនីយ៍ ពីណូចេ រួចហើយ ។ តើប្រទេសផ្សេងៗទៀតតម្រូវឲ្យគោរពការលើកលែងទោសនេះដែរឬទេ? នៅក្នុងស្ថានការណ៍បែបនេះ ប្រទេសដទៃទៀតត្រូវតែបង្ហាញនូវការយល់ព្រមរបស់ខ្លួនចំពោះបំណងប្រាថ្នារបស់ប្រជាជនឈីលី ។ ចំណុចចុងក្រោយគឺសំណួរដែលថាតើប្រទេសអេស្ប៉ាញអាចកាត់សេចក្តីទៅលើអំពើដែលឧត្តមសេនីយ៍ ពីណូចេ បានប្រព្រឹត្តនៅក្នុងប្រទេសឈីលីបានដែរឬយ៉ាងណានោះ គួរតែឆ្លើយថា“ទេ” ។ បណ្តឹងជាឯកតោភាគីប្រឆាំងនឹងរដ្ឋមានអធិបតេយ្យភាពធ្វើឲ្យមានអំណាចច្រើនហួសពេកនៅក្នុងដៃរបស់រដ្ឋ ហើយបង្កឲ្យ

មានការរំលោភស្រេចតែអំពើចិត្តរបស់រដ្ឋ ។ កន្លះខាតការឆ្លើយតបរឹតតែបង្ហាញទិសដល់សហគមន៍អន្តរជាតិឲ្យបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ចុងបញ្ចប់គឺថាតាមរយៈការយល់ព្រមរបស់ក្រុមប្រឹក្សាអង្គការសហប្រជាជាតិ សហគមន៍អន្តរជាតិបានឆ្លើយតបចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិមនុស្សក្នុងបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយបង្កើតឡើងនូវតុលាការអន្តរជាតិពិសេសមួយ ។ ការបង្កើតតុលាការពិសេសគឺជាការសមស្របទៅនឹងភាពអសកម្មរបស់សហគមន៍អន្តរជាតិ ។ ប៉ុន្តែប្រព័ន្ធនេះមិនទាន់មានលក្ខណៈឥតខ្ចោះនៅឡើយទេ ។

ផ្អែកលើហេតុការណ៍ជាក់ស្តែង សារជាតិពិសេសនៃការឆ្លើយតបនេះបង្កើតឲ្យមានអសមត្ថភាពខាងផ្លូវច្បាប់និងរដ្ឋបាល ។ នៅរាល់ពេលដែលអំពើឃោរឃៅកើតឡើង អ្នកគាំទ្រតុលាការត្រូវតែស្វែងរកអំណាចពីសមាជិកក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដូច្នេះបានធ្វើឲ្យមានការពន្យារពេលយ៉ាងច្រើនក្នុងការគ្រប់គ្រងយុត្តិធម៌ ។ អ្នកគាំទ្រនឹងជួបប្រទះឧបសគ្គពីរយ៉ាងនៅក្នុងដំណើរការនេះ ។ ទី១ សមាជិកអចិន្ត្រៃយ៍មានការស្ទាក់ស្ទើរក្នុងចិត្តក្នុងការប្រើប្រាស់ក្រុមប្រឹក្សាសន្តិសុខឲ្យបង្កើតច្បាប់ថ្មី ។ ទី២ ក្រុមប្រឹក្សាសន្តិសុខគឺជាអង្គការនយោបាយ ។ ការយល់ស្របគ្នាជាប្រពៃណីរវាងសមាជិក នឹងនាំដល់ការបំភ្លេចចោលនូវយុត្តិធម៌ឬអន្តរាគមន៍នៅក្នុងប្រទេសនានា ។ ឧទាហរណ៍តុលាការនៅប្រទេសរ៉្វាន់ដានិងអតីតយូហ្គោស្លាវី ត្រូវបានបង្កើតឡើងនៅក្នុងសម័យនយោបាយរួម ។ ផ្ទុយមកវិញ ប្រទេសកម្ពុជាមិនទាន់បានទទួលនូវការយល់ព្រមពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ក្នុងការបង្កើតតុលាការដើម្បីកាត់សេចក្តីមេដឹកនាំខ្មែរក្រហមដែលមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងប្រទេសរ៉្វាន់ដានិងអតីតប្រទេសយូហ្គោស្លាវីនៅឡើយទេ ។ ក្នុងនាមជាអ្នកគាំទ្រខ្មែរក្រហមដ៏សំខាន់ ប្រទេសចិននឹងមានការរួញរាមិនយល់ព្រមឲ្យបង្កើតតុលាការអន្តរជាតិដើម្បីកាត់សេចក្តីអតីតផ្ទៃរណបរបស់ខ្លួនទេ ។

ជាងនេះទៅទៀត តម្លៃនិងការខាតបង់ពេលវេលាក្នុងការចាប់ផ្តើមរដ្ឋបាលគ្រប់គ្រងរាល់ពេលមានការអនុញ្ញាតឲ្យបង្កើតតុលាការគឺពិតជាមិនគួរឲ្យចូលចិត្តទេ ហើយបញ្ហានេះអាចដោះស្រាយបានដោយងាយតាមរយៈការបង្កើតតុលាការអចិន្ត្រៃយ៍មួយ ។

ការមកដល់និងភាពសំខាន់នៃអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដា ថែមទាំងបានបង្ហាញនូវទិដ្ឋភាពនៃតម្លៃនៃការយឺតយ៉ាវគឺត្រូវការជាចាំបាច់នូវការរួមគ្នាឲ្យបានឆាប់រហ័សនិងគ្មានប្រកាន់និន្នាការនយោបាយ ។ ជាការគួរឲ្យកត់សម្គាល់មេបញ្ជាការកងកម្លាំងអង្គការសហប្រជាជាតិជនជាតិរ៉្វាន់ដា បានព្រមានអង្គការសហប្រជាជាតិអំពីការបន្តកាប់សម្លាប់នៅពេលខាងមុខទៀត ។ ទោះជាមានការព្រមានយ៉ាងនេះក៏ដោយ ក៏លោកខាងលិចមិនបានព្យាយាមទប់ស្កាត់ការកាប់សម្លាប់ដែរ ។ ហើយនៅពេលដែលអំពើប្រល័យពូជសាសន៍បានកើតឡើង ប្រទេសលោកខាងលិចមិនបានព្យាយាមរារាំងអំពើនេះឡើយ ។ ការបដិសេធរបស់អង្គការសហប្រជាជាតិនិងសហរដ្ឋអាមេរិកមិនព្រមចាត់ទុកការសម្លាប់រង្គាលថាជាអំពើប្រល័យពូជសាសន៍ ជារនាំងខណ្ឌរវាងអង្គការសហប្រជាជាតិនិងសហរដ្ឋអាមេរិកមិនឲ្យចាត់វិធានការ ។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ប្រសិនបើមានយន្តការអចិន្ត្រៃយ៍មួយដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិនោះ ម៉្លេះសមល្បែងនយោបាយនឹងប្រហែលជាមិនមានផលប៉ះពាល់ដ៏ធ្ងន់ធ្ងរមកលើជនជាតិរ៉្វាន់ដាយ៉ាងដូច្នេះឡើយ ។

បើនិយាយក្នុងន័យសមធម៌វិញ ដំណើរការតុលាការពិសេសនាំដល់ការរើសអើង និងការធ្វើអំពើស្រេចតែចិត្តនៅក្នុងការសម្រេចចិត្តបង្កើតតុលាការមួយ ហើយនាំដល់ភាពមិនស្របគ្នាក្នុងការវិនិច្ឆ័យក្តី ។ យុត្តិធម៌ត្រូវតែស្ថិតក្នុងសណ្ឋានដូចៗគ្នាហើយអាចយកជាការបាន ។ ប៉ុន្តែទម្រង់ការដោះស្រាយមួយករណីម្តងៗ នាំឲ្យយុត្តិធម៌មានលក្ខណៈមិនស៊ីគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ដែលមិនមានការពាក់ព័ន្ធដល់ផ្នែកភូមិសាស្ត្រនិងសក្តានុពលសេដ្ឋកិច្ច ។ ជាឧទាហរណ៍ កិច្ចខិតខំប្រឹងប្រែងសំខាន់ៗត្រូវបានធ្វើឡើងដើម្បីកាត់សេចក្តីឧត្តមសេនីយ៍ ពីណូចេដែលបានប្រព្រឹត្តបទឧក្រិដ្ឋកម្មស្រាលជាងខ្មែរក្រហម ។ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងដ៏តិចតួចត្រូវបានធ្វើឡើងដើម្បីកាត់ទោស

ស្ថាបនិកនៃរបបដ៏យង់ឃ្នងនៅក្នុងប្រទេសកម្ពុជារហូតមកដល់សព្វថ្ងៃនេះ ។ ហេតុដូច្នេះ ប្រព័ន្ធយុត្តិធម៌នៃតុលាការអាដហុកពិសេស ផ្តល់យុត្តិធម៌ម្តងយ៉ាងនេះម្តងយ៉ាងនោះ ហើយជួនកាលថែមទាំងមិនបានផ្តល់យុត្តិធម៌ដល់អ្នកដទៃផ្សេងទៀតក៏មាន ។

សង្ខេបមកវិញ ប្រព័ន្ធពិសេសសព្វថ្ងៃគ្មានលក្ខណៈល្អ និងមិនគួរជាការប៉ងប្រាថ្នាឡើយ ដោយសារតែគ្មានប្រសិទ្ធភាពដូវច្បាប់និងធ្វើឡើងស្រេចតែអំពើចិត្ត ព្រមទាំងគ្មានការគ្រប់គ្រងយុត្តិធម៌ក្នុងលក្ខណៈដូចៗគ្នា ។ នយោបាយបានជ្រមុជដំណើរការបង្កើតតុលាការបាត់ឈឹង ហើយជាលទ្ធផលបណ្តាលឲ្យមានអយុត្តិធម៌ឬយុត្តិធម៌កម្រិតទី២សម្រាប់ប្រទេសនានាដែលមិនមានលក្ខណៈដូចគ្នាខាងវិស័យភូមិសាស្ត្រនយោបាយនិងសេដ្ឋកិច្ច ។

## ៣) ច្បាប់អនុម័តនៅទីក្រុងរ៉ូម

ច្បាប់អនុម័តនៅទីក្រុងរ៉ូមដែលមានស្រាប់ បានផ្តល់នូវដំណោះស្រាយមានលក្ខណៈអនុគ្រោះក្នុងការចាត់វិធានការចំពោះព្រហ្មទណ្ឌក្រោមច្បាប់អន្តរជាតិ ។ ច្បាប់នេះស្នើសុំបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ដែលមានដែនសមត្ថកិច្ចលើបទប្រល័យពូជសាសន៍ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងព្រហ្មទណ្ឌនៃការឈ្លានពានទឹកដី ។ ក៏ប៉ុន្តែ"ខ" មួយចំនួននៅក្នុងច្បាប់នេះលើកឡើងនូវការព្រួយបារម្ភធំៗមួយចំនួនដែលត្រូវការពិនិត្យសើរើឡើងវិញ ។ ទី១ និយមន័យនៃឧក្រិដ្ឋកម្មដែលលើកឡើងមិនសូវមានលក្ខណៈទូលំទូលាយ ធ្វើឲ្យមានភាពស្រពេចស្រពិលមិនច្បាស់លាស់ទាក់ទងទៅនឹងទំហំដែនយុត្តាធិការរបស់តុលាការ ។ ឧទាហរណ៍មាត្រាទី៨(២)(ខ)(XII) កំណត់ថា"ឧក្រិដ្ឋកម្មសង្គ្រាម"រួមបញ្ចូលទាំង"ការប្រកាសដែលមិនចាំបាច់បញ្ជាក់ពីទីកន្លែងណាឡើយ" ។ ប្រហាក់ប្រហែលគ្នានេះដែរមាត្រា៨(២)(ខ)(XXI) បានដាក់បញ្ញត្តិច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ទៅលើបុគ្គលទាំងឡាយណាដែល "រំលោភបំពានទៅលើភាពថ្លៃថ្នូររបស់បុគ្គលដទៃទៀត ជាពិសេសធ្វើឲ្យអាម៉ាស់មុខ និងធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស" ។ ជាងនេះទៅទៀត នៅក្នុងមាត្រាទី១(ក) "ឧក្រិដ្ឋកម្មនៃការឈ្លានពានទឹកដី"ដែលទម្ងន់ស្មើនឹងអំពើប្រល័យពូជសាសន៍ព្រហ្មទណ្ឌសង្គ្រាមនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរនោះ ច្បាប់នេះបានបន្ថយកម្រិតរំលោភបំពាន ហើយធ្វើឲ្យអន្តរាយដល់ប្រសិទ្ធភាពរបស់តុលាការក្នុងការពង្រីកដែនសមត្ថកិច្ចរបស់ខ្លួន ។

ដែនសមត្ថកិច្ចនិងមុខងាររបស់ព្រះរាជអាជ្ញាបង្កើតជាការព្រួយបារម្ភទី២ នៅក្នុងច្បាប់អនុម័តនៅទីក្រុងរ៉ូម ។ ដូចគ្នាទៅនឹងភាគីរដ្ឋនិងក្រុមប្រឹក្សាអន្តរការសហប្រជាជាតិ មាត្រាទី១៣យល់ព្រមផ្តល់អំណាចដល់ព្រះរាជអាជ្ញាក្នុងការអនុវត្តដែនសមត្ថកិច្ចរបស់ខ្លួន ។ ដូចនេះ សហគមន៍អន្តរជាតិគួរតែផ្អាកដំណើរការសិន ហើយគិតសាជាថ្មីចេញពីការយល់ឃើញរបស់ខ្លួន គិតពីតួនាទីរបស់ព្រះរាជអាជ្ញាឲ្យមានការសម្រេចចិត្តទូលំទូលាយនិងមានឯករាជ្យភាព ។

សហរដ្ឋអាមេរិកបានបដិសេធមិនព្រមផ្តល់សច្ចាប័នដល់ច្បាប់ដែលអនុម័តនៅទីក្រុងរ៉ូម ស្ថិតនៅក្នុងទម្រង់ការបច្ចុប្បន្នទេ ។ ក្រៅពីការព្រួយបារម្ភដូចដែលបានលើកឡើងខាងលើ សហរដ្ឋអាមេរិកមានការព្រួយបារម្ភចំពោះពាក្យបណ្តឹងដោយហេតុផលនយោបាយប្រឆាំងនឹងខ្លួនឯង ។ មិនតែប៉ុណ្ណោះ សហរដ្ឋអាមេរិកបានជំទាស់នឹងមាត្រាទី១២០ដែលហាមប្រាមការដាក់"ខរក្សាសិទ្ធិ"ទៅលើច្បាប់រ៉ូម ។ សហរដ្ឋអាមេរិកចាត់ទុកថា ការ"យកឬមិនយកចំណុចនេះ" ជា "ភាពតានតឹងជាមួយនឹងតម្រូវការផ្នែកច្បាប់ក្នុងស្រុករបស់ខ្លួន ។

ប៉ុន្តែទោះជាការព្រួយបារម្ភមានភាពធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ក៏ច្បាប់នេះបានផ្តល់នូវការការពារមួយចំនួនដែរ ។ ទី១ គឺច្បាប់នេះផ្តល់នូវអាទិភាពដល់តុលាការជាតិប្រសិនបើតុលាការទាំងនោះដំណើរការរឿងក្តីដោយសុទ្ធចិត្ត ។ ទី២ ព្រហ្មទណ្ឌប្រឆាំងនឹងមនុស្សជាតិត្រូវតែមានលក្ខណៈជាអន្តរជាតិ ដើម្បីបន្ធូរបន្ថយការភ័យខ្លាចអំពីការកាត់សេចក្តីទៅលើករណីទម្លាក់គ្រាប់បែកជាយថាហេតុ ។ ហើយច្បាប់ដែលអនុម័តនៅទីក្រុងរ៉ូមក៏បានកំណត់ទីកន្លែងសម្រាប់ការការពារព័ត៌មានសន្តិសុខរបស់ជាតិដែលផាយនឹងបែកការណ៍ដែរ ។ ជាងនេះទៅទៀត មាត្រាទី១១ បានប្រកាសឲ្យជនគ្រប់រូបជ្រាបនូវព័ត៌មាននេះ ។ តុលាការមានដែនសមត្ថកិច្ចត្រឹមតែព្រហ្មទណ្ឌដែលត្រូវបានប្រព្រឹត្តឡើងក្រោយពេលច្បាប់នេះចូលជាធរមានតែប៉ុណ្ណោះ ។**(តទៅទំព័រ៩០)**

# តើមេដឹកនាំខ្មែរក្រហមគួរតែត្រូវជំនុំជម្រះទោសពីបទ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ?

តើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមនៅក្នុងឆ្នាំ១៩៧៥-១៩៧៩ ជា«អំពើប្រល័យពូជសាសន៍»ដែរឬទេ? ។ អស់រយៈកាលជាច្រើនឆ្នាំកន្លងមកនេះ «ការនិយាយអំពីប្រល័យពូជសាសន៍នៅកម្ពុជា» ត្រូវបានយកមកប្រើប្រាស់យ៉ាងទូលំទូលាយ នៅក្នុងមជ្ឈដ្ឋាននៃកិច្ចការសិទ្ធិមនុស្ស ។ ដោយសារតែសេចក្តីសង្ឃឹមក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមកាន់តែចេញរូបរាងច្បាស់ឡើងៗ ហើយនោះ ចាំបាច់ត្រូវមានការកំណត់ឲ្យបានច្បាស់ថាតើវាជាការសមស្របតាមផ្លូវច្បាប់ដែរឬទេក្នុងការប្រើពាក្យ «ប្រល័យពូជសាសន៍» ។

ការបង្កើតយ៉ាងហ្មត់ចត់ទៅលើទំហំនៃពាក្យដូចដែលបានកំណត់នៅក្នុងមាត្រាទីពីរនៃអនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ បានបញ្ជាក់ជាសេចក្តីសន្និដ្ឋានមួយថា អំពើឃោរឃៅដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមមិនមែនជាអំពើប្រល័យពូជសាសន៍ទេ ។ ដោយអនុលោមតាមអនុសញ្ញានេះគឺថា នៅក្នុងអនុសញ្ញានេះប្រល័យពូជសាសន៍គឺជាអំពើទាំងឡាយណាក្នុងចំណោមអំពើទាំងប៉ុន្មានដែលមានរៀបរាប់ខាងក្រោម ដែលបានប្រព្រឹត្តឡើងដោយមានចេតនាក្នុងគោលបំណងបំផ្លាញទាំងស្រុង ឬដោយផ្នែកណាមួយនៃក្រុមជនជាតិ ជាតិពន្ធ ពូជសាសន៍ ឬសាសនាមួយ ហើយអំពើទាំងឡាយនោះមានដូចជា÷

ក) ការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម ។

ខ) ការបង្កការឈឺចាប់និងខូចខាតជាដំណំខាងរូបរាងកាយឬសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុម ។

គ) ការបង្កឡើងដោយចេតនានូវមហន្តរាយដល់ស្ថានភាពរស់នៅរបស់ក្រុមមនុស្សដែលនាំដល់ការបំផ្លិចបំផ្លាញទាំងស្រុង ឬខាងផ្នែករូបរាងកាយសមាជិកក្នុងក្រុម ។

ឃ) ការដាក់បង្ខំនូវវិធានការនានាក្នុងគោលបំណងបង្ការមិនឲ្យមានកំណើតទារកនៅក្នុងក្រុម ។

ង) ការយកកូនក្មេងចេញពីក្រុមមួយទៅដាក់ឲ្យរស់នៅក្នុងក្រុមមួយទៀតដោយបង្ខំ ។

អត្ថបទពិភាក្សានេះមិនមែននិយាយថាតើឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយ ប៉ុល ពត និង មីឡូសីវិច ពិតជាបានកើតឡើងមែនឬមិនមែននោះទេ ប៉ុន្តែគឺចង់បញ្ជាក់ថាតើឧក្រិដ្ឋកម្មទាំងអស់នោះត្រូវបានកំណត់យ៉ាងត្រឹមត្រូវជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬក៏ជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ការឲ្យនិយមន័យផ្សេងៗពីគ្នាច្រើនណាស់ទៅលើបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែនិយមន័យទាំងនេះមានភាពស្របគ្នាលើចំណុចរួមមួយគឺការធ្វើទុក្ខបុកម្នេញទៅលើបុគ្គលម្នាក់ៗ ឬបុគ្គលក្នុងក្រុមជាទ្រង់ទ្រាយធំនិងលក្ខណៈជាប្រព័ន្ធ ។ នៅទសវត្សរ៍ឆ្នាំ១៩៧០ និយមន័យដែលត្រូវបានទទួលស្គាល់ជាទូទៅស្តីអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ បានដកស្រង់ចេញពីមាត្រាទី៦ក្នុងធម្មនុញ្ញនៃតុលាការនូរិមប៊ឺក÷ «មនុស្សឃាត ការសម្លាប់រង្គាល ទាសភាព ការនិរទេសនិងអំពើអមនុស្សធម៌ផ្សេងៗទៀត ដែលប្រព្រឹត្តឡើងក្នុងគោលបំណងប្រឆាំងនឹងប្រជាជនស៊ីវិលនៅមុនពេល ឬក្នុងអំឡុងពេលនៃសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា» ។

ប្រសិនបើពាក្យថា«ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ» មានន័យកាន់តែច្បាស់ហើយនោះ ហេតុអ្វីយើងទាំងអស់មានទំនោរចង់តែហៅបទឧក្រិដ្ឋនេះថាជា«បទឧក្រិដ្ឋប្រល័យពូជសាសន៍» ទៅវិញ ។ មានហេតុផលច្រើនយ៉ាងគឺថា ទី១ អំពើប្រល័យពូជសាសន៍ជាបទឧក្រិដ្ឋកម្មមួយដែលមានលក្ខណៈធ្ងន់ធ្ងរជាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ទោះបីជាបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ មានស្លាកស្នាមធ្ងន់ធ្ងរយ៉ាងណាក៏ដោយក៏អំពើនេះនៅមិនទាន់ដល់ថ្នាក់អាក្រក់រហូតធ្វើឲ្យចាត់ចូលជា

អំពើប្រល័យពូជសាសន៍មួយដែរ ។ ទី២ អត្ថិភាពនៃអនុសញ្ញាស្តីអំពីការបង្ការនិងផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ដែលប្រទេសកម្ពុជាជាភាគីមួយនៅគ្រប់ចំណុចពេលវេលានោះ បានតម្រូវឲ្យគោរពនូវកាតព្វកិច្ចច្បាប់ជាលក្ខណៈអន្តរជាតិយ៉ាងច្បាស់ ។ យើងមិនអាចនិយាយដូចគ្នាទេ ចំពោះបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ពីព្រោះបទឧក្រិដ្ឋនេះគ្មាននៅក្នុងការអនុវត្តជាគោលការណ៍នៃសន្ធិសញ្ញាអន្តរជាតិ រហូតមកដល់មានការអនុម័តច្បាប់បង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិនាទីក្រុងរ៉ូមក្នុងឆ្នាំ ១៩៩៨ ។ ច្បាប់ដែលអនុម័តនៅទីក្រុងរ៉ូមពុំមានដែនអនុវត្តប្រតិសកម្មទេ ទោះជាមានការអះអាងថាច្បាប់នេះមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ដែលក្នុងនោះរួមទាំងនិយមន័យនៃបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ទោះបីពេលបច្ចុប្បន្ននេះជាការច្បាស់លាស់ថា បទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អាចត្រូវបានប្រព្រឹត្តឡើងនៅពេលមានសន្តិភាព ប៉ុន្តែនេះមិនមែនជាករណីនៅនូរិមប៊ឺកឡើយ ។ នៅចំណុចពេលវេលាណាមួយក្នុងចន្លោះឆ្នាំ១៩៤៥និងឆ្នាំ១៩៩៨ សម្ព័ន្ធបុការពាក់ព័ន្ធគ្នារវាងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធត្រូវលុបចោល ។ ប៉ុន្តែនៅពេលណា? ភាគីចុងចោទខ្មែរក្រហមនឹងទាញហេតុផលថា អំពើនេះបានកើតឡើងនៅក្រោយឆ្នាំ១៩៧៩ ហើយថាដូច្នេះខ្លួនមិនអាចទទួលការវិនិច្ឆ័យទោសពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបានទេ ពីព្រោះគ្មានភ័ស្តុតាងបង្ហាញថា នៅក្នុងឆ្នាំ១៩៧៥-១៩៧៩ មានជម្លោះប្រដាប់អាវុធកើតឡើងនៅក្នុងប្រទេសកម្ពុជា ។ ការបង្ហាញថា ជាប្រល័យពូជសាសន៍គឺពុំមានជួបការលំបាកខាងផ្លូវច្បាប់ដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេ ដោយហេតុថា មាត្រាទី១នៃអនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ បញ្ជាក់ច្បាស់ថាបទឧក្រិដ្ឋកម្មនេះអាចត្រូវបានប្រព្រឹត្តឡើង«នៅក្នុងពេលមានសន្តិភាពឬពេលមានសង្គ្រាម» ។

ទំនងជាយល់ដឹងអំពីភាពស្មុគស្មាញក្នុងច្បាប់ដែលពាក់ព័ន្ធនឹងការជំនុំជម្រះក្តីពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ទើបនៅឆ្នាំ១៩៧៩ របបដែលបានផ្តួលរំលំខ្មែរក្រហមពីអំណាចបានរៀបចំកាត់ទោសលំៗទៅលើ ប៉ុល ពត និង អៀង សារី ពីបទប្រល័យពូជសាសន៍ ។ ចុងបញ្ចប់ ប៉ុល ពត និង អៀង សារី ត្រូវបានកាត់ឲ្យជាប់ទោសពីបទប្រល័យពូជសាសន៍មែន ។ ករណីនេះមិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ដោយសារតែបុព្វកថានៃក្រឹត្យច្បាប់ដែលបង្កើតតុលាការប្រជាជនបដិវត្តន៍នោះប្រកាសថ្កោលទោសការសម្លាប់រង្គាលដែលប្រព្រឹត្តឡើងដោយបន«ប៉ុល ពត, អៀង សារី» ។ ការសម្រេចឲ្យបន«ប៉ុល ពត, អៀង សារី» ជាប់ទោសនេះ តាមសារជាតិពិតគឺមិនមែនជាបទប្រល័យពូជសាសន៍ដូចដែលបានចែងនៅក្នុងអនុសញ្ញាឆ្នាំ១៩៤៨ឡើយ ប៉ុន្តែវាជានិយមន័យដែលមានលក្ខណៈពិសេសចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៅវិញទេ÷

«ការសម្លាប់រង្គាលសមាជិកក្រុមស្លូតត្រង់ដោយមានផែនការច្បាស់លាស់ ការបណ្តេញប្រជាជននៅទីក្រុងនិងប្រជាជននៅតាមភូមិចេញ ដើម្បីប្រមូលផ្តុំនិងបង្ខំអ្នកទាំងនោះឲ្យធ្វើការងារធ្ងន់ៗដែលបង្កឲ្យមានការទ្រុឌទ្រោមដល់រាងកាយនិងសតិបញ្ញា លុបបំបាត់សាសនា កម្ទេចចោលនូវរចនាសម្ព័ន្ធនយោបាយ វប្បធម៌ និងសង្គមព្រមទាំងទំនាក់ទំនងក្នុងគ្រួសារ និងទំនាក់ទំនងសង្គម» ។

ដើម្បីឲ្យក្លាយជាអំពើប្រល័យពូជសាសន៍ដូចដែលមានចែងនៅក្នុងអនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសករណីប្រល័យពូជសាសន៍ លុះត្រាតែមាន«ការបំផ្លិចបំផ្លាញដោយចេតនានូវក្រុមជាតិ ជាតិពន្ធ ពូជសាសន៍ ឬសាសនាណាមួយ» ។ តើក្រុមណាមួយក្នុងចំណោមក្រុមទាំងអស់នេះមាននៅក្នុងប្រទេសកម្ពុជា ។ ដីកាចោទប្រកាន់របស់តុលាការឆ្នាំ១៩៧៩ និយាយអំពី«ផែនការដែលរៀបចំឡើងជាប្រព័ន្ធក្នុងការសម្លាប់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ» ។ មិនតែប៉ុណ្ណោះ មានការយល់ស្របជាទូទៅថា ជនរងគ្រោះខ្មែរដែលទទួលរងនូវអំពើឃោរឃៅ សម្គាល់ឲ្យឃើញតាមរយៈឋានៈសង្គមឬសេដ្ឋកិច្ចរបស់ខ្លួន ។ ឧទាហរណ៍ អ្នកដែលមានពាក់វ៉ែនតាត្រូវបានចាត់ចូលទៅក្នុងមុខសញ្ញានៃការធ្វើទុក្ខបុកម្នេញ ពីព្រោះអ្នកទាំងនោះចូលទៅក្នុងក្រុមបញ្ញវន្តដែលជាក្រុមស្ថិតនៅក្រោមមន្ទិលសង្ស័យរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ ខណៈដែលនិយមន័យនៃអំពើប្រល័យពូជសាសន៍

ត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការទី៦ នៃមហាសន្និបាតអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៤៨ មានសំណើមួយចំនួនសុំឲ្យបញ្ចូលក្រុមសង្គម និងក្រុមសេដ្ឋកិច្ច ប៉ុន្តែសំណើទាំងនេះត្រូវបានទាត់ចោល ។ អស់រយៈកាលជាច្រើនឆ្នាំក្រោយមកទៀត មានបុគ្គលជាច្រើនរូបសុំឲ្យពង្រីកទំហំនៃអនុសញ្ញាដើម្បីអាចគ្រោបយកនូវក្រុមនយោបាយ ក្រុមសេដ្ឋកិច្ច និងក្រុមសង្គម ប៉ុន្តែមិនបានសម្រេចជោគជ័យ ។

ហើស ហានណាំ និងអ្នកដទៃទៀត បានអះអាងដោយហេតុផលថា ដោយសារតែជនរងគ្រោះជាសមាជិករបស់ក្រុមជនជាតិ ចំណុចនេះពិតជាបង្កើតបានជាបទប្រល័យពូជសាសន៍ ។ ប៉ុន្តែការអះអាងនេះនាំដល់ការទាញសេចក្តីសន្និដ្ឋានមួយថា រាល់ការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំគឺមានន័យស្មើនឹងអំពើប្រល័យពូជសាសន៍ ពីព្រោះថា តាមជាក់ស្តែងមនុស្សក្នុងក្រុមធំៗណាមួយពិតជាមានក្រុមជនជាតិផ្សេងៗគ្នាមួយឬច្រើនក្រុមទៀត ។ ការអះអាងនេះត្រូវយកមកប្រើប្រាស់វិញដែលគ្រាន់តែប្តូរពាក្យផ្សេងប៉ុណ្ណោះ ហើយជាផលវិបាកគឺធ្វើឲ្យគំនិតខុសគ្នានៃអំពើប្រល័យពូជសាសន៍ថយចុះនូវខ្លឹមសារពិត ។ និយាយកុំឲ្យលម្អៀងការទាញហេតុផលនេះ មានភាពស្របគ្នាខ្លះនៅចំពោះមុខតុលាការនៃប្រទេសអេស្ប៉ាញដែលកំពុងតែដោះស្រាយរឿងក្តីរបស់ឧត្តមសេនីយ៍ ពីណូចេ ។ ផលវិបាកផ្សេងៗដែលកើតចេញពីការទាញហេតុផលនេះបានលេចឡើងនៅពេលដែលអតីតប្រធានាធិបតីយូហ្គោស្លាវី ស្លូបូដាន មីឡូសីវិច ចោទប្រទេសមួយចំនួននៅក្នុងអង្គការណាតូពីបទប្រល័យពូជសាសន៍ ដោយឈរលើមូលដ្ឋានដូចគ្នានៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ នៅក្នុងអ្វីដែលជាការអះអាងមួយក្នុងចំណោមការអះអាងឥតបានការនានា ដែលនឹងត្រូវដាក់ជូនស្ថាប័នជាន់ខ្ពស់នេះ ។

ឥឡូវនេះ អ្នកសង្កេតការណ៍ពិតប្រាកដមួយចំនួនបានបដិសេធចោលនូវការបង្កើតអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ង៉ាយៗបែបនេះ ។ ក្រុមអ្នកជំនាញការរបស់អង្គការសហប្រជាជាតិដែលបានតាមដានដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ក៏បានរិះគន់ដល់ការទាញហេតុផលនេះដែរ ។ ក្រុមអ្នកជំនាញការយល់ស្របថា ប្រជាជនខ្មែរគឺជាក្រុមជនជាតិមួយនៃប្រទេសកម្ពុជា ហើយបាននិយាយថា“ទាក់ទងនឹងក្រុមជនជាតិខ្មែរ ថាតើខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែរឬទេ នោះគឺជាបញ្ហាដែលតម្រូវឲ្យមានការបកស្រាយច្បាស់លាស់ ជាពិសេសអំពីចេតនារបស់ខ្មែរក្រហមមកលើជនរងគ្រោះរបស់ខ្លួនដែលមិនមែនជាជនជាតិភាគតិច” ។ ក្រុមអ្នកជំនាញការអង្គការសហប្រជាជាតិ បានបដិសេធពុំព្រមប្រកាន់យកជំហរ



ណាមួយនៅក្នុងបញ្ហានេះទេ ដោយនិយាយថា បញ្ហានេះគួរតែត្រូវដោះស្រាយដោយតុលាការ ប្រសិនបើមេដឹកនាំខ្មែរក្រហមត្រូវបានចោទប្រកាន់ថា បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍មកលើក្រុមជនជាតិនោះ ។

ហេតុដូច្នេះ បញ្ហាលំបាកដ៏ធំបំផុតក្នុងការប្រើពាក្យប្រល័យពូជសាសន៍ដើម្បីនិយាយយោងដល់អំពើឃោរឃៅនៅប្រទេសកម្ពុជានោះ គឺស្ថិតនៅត្រង់ក្រុមជនជាតិដែលជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ។ ការបំផ្លិចបំផ្លាញជនជាតិខ្មែរ

ដោយខ្មែរគ្នាឯង បានពង្រីកនិយមន័យអំពើប្រល័យពូជសាសន៍ ឲ្យមានទំហំធំ ។ ទន្ទឹមពេលគ្នានេះដែរ អ្នកឃ្លាំមើលសភាពការណ៍ ជាច្រើនព្យាយាមនិយាយថា មានអំពើប្រល័យពូជសាសន៍នៅ កម្ពុជា ដោយផ្តោតសំខាន់ទៅលើការធ្វើទុក្ខបុកម្នេញក្រុម ជាតិសាសន៍ ដែលពិតជាធាតុផ្សំមួយនៅក្នុងនិយមន័យនៃ អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ។ ខ្មែរក្រហមចាត់ទុក



ព្រះសង្ឃជាបញ្ញើក្អែកសង្គម ។ ខ្មែរក្រហមបានផ្សឹកព្រះសង្ឃ ហើយបង្ខំឲ្យធ្វើការជាមួយប្រជាកសិករ ។ ព្រះសង្ឃអង្គណាដែល ហ៊ានជំទាស់នឹងបញ្ជា នឹងត្រូវផ្តន្ទាទោសយ៉ាងឃោរឃៅ ។ សញ្ញាណសាសនាដូចជាវត្តអារាម ត្រូវបានបំផ្លាញចោលនិង លួចឆក់ប្លន់ឲ្យហិនហោចអស់ ។ ខ្មែរក្រហមមិនបានអត់ឱនចំពោះ សាសនាភាគតិចផ្សេងៗជាងព្រះពុទ្ធសាសនាដែលជាសាសនារបស់ ជនជាតិភាគច្រើនឡើយ ។ ឧទាហរណ៍ជនជាតិចាមក៏ត្រូវក្លាយ ជាមុខសញ្ញានៃការវាយប្រហារដូចគ្នានេះដែរ និងគោលបំណង “បញ្ចូល” ជនជាតិចាមឲ្យរស់នៅលាយឡំគ្នាជាជនជាតិខ្មែរ ។

ការបំផ្លិចបំផ្លាញគ្រឹះស្ថានវប្បធម៌និងការបង្ខំឲ្យរស់នៅ ជាមួយគ្នាគឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការកម្ទេចក្រុម សាសនា ឬក្រុមជាតិពន្ធុ ។ អំពើទាំងពីរត្រូវបានហាមប្រាម ដោយច្បាប់អន្តរជាតិ ។ បញ្ហានៅទីនេះគឺថា អំពើទាំងនេះមិនមែន ជាអំពើប្រល័យពូជសាសន៍ទេ ប្រសិនបើអនុលោមតាមការកំណត់ ក្នុងមាត្រាទី២ នៃអនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសអំពើ ប្រល័យពូជសាសន៍ ។ មិនតែប៉ុណ្ណោះ អ្នកធ្វើសេចក្តីព្រាងអនុ សញ្ញា ថែមទាំងមិនបានបញ្ចូលការប្រល័យពូជសាសន៍វប្បធម៌ ទេ លើកលែងតែមួយគត់គឺការបញ្ជូនកុមារពីក្រុមមួយទៅដាក់ នៅក្នុងក្រុមមួយផ្សេងទៀតដោយបង្ខិតបង្ខំ ។ ការជំទាស់ដ៏ សំខាន់ក្នុងការមិនបញ្ចូលក្រុមវប្បធម៌នេះកើតចេញមកពីប្រទេស មួយចំនួននៃ“ពិភពលោកថ្មី” ជាពិសេសគឺសហរដ្ឋអាមេរិកនិង ប្រទេសកាណាដា ។ ប្រទេសទាំងនេះចង់បង្ក្រាបការរឹងរូស ចំពោះអន្តោប្រវេសន៍ដែលមិនព្រមចូលរួមរស់ជាមួយគ្នា និង (ប្រហែលតាមការពិចារណាឃើញពេលនោះ) រអើលខ្លាចមានការ ប្តឹងផ្តល់នៅពេលអនាគតពីសំណាក់ក្រុមជនជាតិដើម ។ ទោះជា យ៉ាងណាក៏ដោយ ការដែលថា“ការប្រល័យពូជសាសន៍វប្បធម៌” មិនត្រូវបានបញ្ចូលនៅក្នុងអនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោស បទប្រល័យពូជសាសន៍នោះគឺមិនប្រកែកបានទេ ។ ដោយសារ ហេតុផលនេះ អ្វីដែលជាអំពើប្រល័យពូជសាសន៍វប្បធម៌ដែល ប្រព្រឹត្តមកលើជនជាតិចាមនិងព្រះសង្ឃនោះ មិនទាន់ដល់កម្រិត ដែលត្រូវអនុសញ្ញាហាមឃាត់ឡើយ ។ ការប្រព្រឹត្តមកលើព្រះ សង្ឃនិងជនជាតិចាមត្រូវនឹងនិយមន័យសព្វថ្ងៃនៃឧក្រិដ្ឋកម្ម ប្រឆាំងមនុស្សជាតិយ៉ាងងាយ ។ អំពើទាំងនេះ វាត្រូវទៅនឹង និយមន័យនៃអំពើប្រល័យពូជសាសន៍ដែលអនុម័តដោយអ្នក រៀបចំតុលាការឆ្នាំ១៩៧៩ ដែលតុលាការនេះសម្រាប់បម្រើ ផលប្រយោជន៍របស់អ្នកទាំងនោះតែប៉ុណ្ណោះ ។

ទោះជាយ៉ាងនេះក្តី ពេលដែលពាក្យ“ប្រល័យពូជសាសន៍” មិនមានលក្ខណៈត្រឹមត្រូវតាមច្បាប់សម្រាប់ហៅអំពើឃោរឃៅ ប្រព្រឹត្តឡើងដោយខ្មែរក្រហម វាប្រហែលជាចូលនៅក្នុងពាក្យ ដែលត្រូវបាននិយមប្រើជាទូទៅក្នុងមជ្ឈដ្ឋានអ្នកសិទ្ធិមនុស្សដាក់

ជាមិនខាន ។ ជាពិសេសជាងនេះទៅទៀត ពាក្យនេះត្រូវបានយកមកប្រើប្រាស់សម្រាប់កម្មវិធីមួយឈ្មោះថា«កម្មវិធីសិក្សាស្រាវជ្រាវអំពើប្រល័យពូជសាសន៍» នៅឯសាកលវិទ្យាល័យយែលទៀតផង ។ ច្បាប់ដែលសហរដ្ឋអាមេរិកអនុម័តនៅឆ្នាំ១៩៩៤ ចែងថា «ការធ្វើទុក្ខបុកម្នេញមកលើប្រជាជនខ្មែរក្រោមរបបខ្មែរក្រហមបង្កើតជាឧទាហរណ៍មួយយ៉ាងច្បាស់នៃអំពើប្រល័យពូជសាសន៍នៅក្នុងប្រវត្តិសាស្ត្រសម័យនេះ ។ សេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិដែលអនុម័តនៅក្នុងឆ្នាំ១៩៩៧សរសេរថា÷ «សំណើសូមឲ្យអង្គការសហប្រជាជាតិឆ្លើយតបជាវិជ្ជមាន ដើម្បីជួយជំរុញឲ្យកិច្ចខិតខំប្រឹងប្រែងក្នុងការស៊ើបអង្កេតប្រវត្តិសាស្ត្រប្រកបដោយសោកនាដកម្មនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា រួមទាំងការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មអន្តរជាតិកាលពីអតីតកាល មានជាអាទិ៍ដូចជាអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ» ។

ដោយពាក្យប្រល័យពូជសាសន៍អាចនៅតែប្រើជាទូទៅដូចសព្វថ្ងៃនេះ វានឹងមានបញ្ហានៅពេលមានការវិនិច្ឆ័យបទឧក្រិដ្ឋដែលនឹងត្រូវបានគិតបម្រុងរៀបចំឡើង ជាពិសេសករណីថ្មីៗដែលទាក់ទងនឹងអំពើឃោរឃៅរបស់ខ្មែរក្រហមតែម្តង ។ នៅក្នុងដំណើរការចរចាពីបញ្ហាបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលឧបត្ថម្ភគាំទ្រដោយអង្គការសហប្រជាជាតិ រដ្ឋាភិបាលកម្ពុជាបានស្នើឲ្យមានការកំណត់និយមន័យនៃពាក្យប្រល័យពូជសាសន៍ឲ្យបានច្បាស់ឡើងវិញដើម្បីងាយស្រួលក្នុងការវិនិច្ឆ័យទោស ។ គណៈប្រតិភូមួយក្រុមដឹកនាំដោយមន្ត្រីជំនាញផ្នែកច្បាប់គឺលោក រ៉ាហ្វ ហ្សាកលីន បានធ្វើការកត់សម្គាល់ភាពមិនស្របគ្នាដោយអន្ទើទាក់ទងនឹងការឲ្យនិយមន័យទៅលើពាក្យប្រល័យពូជសាសន៍នៅក្នុងអនុសញ្ញា ហើយចោទថារាល់«ខ» ណាមួយក៏ដោយ ក៏រំលោភទៅនឹងការហាមប្រាមចំពោះភាពប្រតិសកម្មបទល្មើសដែរ ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី គណៈប្រតិភូបានបន្ថែមទៀតថា ប្រភេទនៃអំពើទាំងនេះដែលនិយមន័យក្នុងអនុសញ្ញាមិនបានក្រសោបយក នឹងត្រូវចូលទៅក្នុងបទដ្ឋានឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ សេចក្តីស្នើជំទាស់មួយរបស់អង្គការសហប្រជាជាតិផ្តោតសំខាន់ទៅលើមាត្រាទី២នៃអនុសញ្ញានេះតែប៉ុណ្ណោះ ។ នេះគឺជាមធ្យោបាយដ៏ល្អមួយ ប៉ុន្តែការកាត់ឲ្យជាប់ទោសពីបទប្រល័យពូជសាសន៍ (ផ្ទុយទៅនឹងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) និងមានលទ្ធភាពកាន់តែតិច ។

**ទីរៀម ស្កាបាស់**

---

## (តពីទំព័រ៤៥) សេចក្តីសន្និដ្ឋាន

ដើម្បីអះអាងថាព្រហ្មទណ្ឌដ៏ធ្ងន់ធ្ងរបំផុតដែលសហគមន៍អន្តរជាតិមានការព្រួយបារម្ភមិនត្រូវបណ្តោយឲ្យរួចពីទណ្ឌកម្មនោះ និក្ខេបបទនេះបានទាញហេតុផលឲ្យមានការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ការបង្កើតស្ថាប័នអចិន្ត្រៃយ៍នេះគឺដោយហេតុផលសីលធម៌ដែលចាក់ឫសនៅក្នុងគំនិតមូលដ្ឋាននៃភាពថ្លៃថ្នូររបស់មនុស្សជាតិ និងដោយហេតុថា ករណីច្បាប់និងប្រវត្តិសាស្ត្រនៅក្នុងផ្នែកសិទ្ធិមនុស្សធ្លាប់មានពីមុនមកហើយ ។ មិនតែប៉ុណ្ណោះ តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងមិនមែនមានភាពឥតខ្ចោះនោះទេ តែវានឹងជាជម្រើសដ៏ល្អជាងគេនៅក្នុងជម្រើសទាំងឡាយដែលបានលើកឡើង ។ នៅក្នុងកាលៈទេសៈបែបនេះ សំណើនៅក្នុងច្បាប់ដែលអនុម័តនៅទីក្រុងរ៉ូមបានបង្កើតឲ្យមានគំរូដ៏គួរឲ្យសរសើរ សម្រាប់ការបង្កើតឲ្យមានយន្តការអចិន្ត្រៃយ៍ ប៉ុន្តែមិនគួរត្រូវបានផ្តល់សច្ចាប័នទេ ល្គឹកណាគុណវិបត្តិចម្បងពីរមិនទាន់ត្រូវបានដោះស្រាយ ។ សហគមន៍អន្តរជាតិត្រូវតែបញ្ឈប់ការឲ្យនិយមន័យរបស់រដ្ឋដែលក្តោបបទព្រហ្មទណ្ឌច្រើនពេកហើយមិនច្បាស់លាស់ ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់តុលាការ ព្រមទាំងបញ្ឈប់ការសម្រេចចិត្តទូលំទូលាយដែលផ្តល់ចំពោះព្រះរាជអាជ្ញាឯករាជ្យ ។ សហរដ្ឋអាមេរិកមានបុព្វហេតុក្នុងការព្រួយបារម្ភអំពីការឲ្យសច្ចាប័នទៅលើច្បាប់នេះ ។ ប៉ុន្តែដើម្បីចៀសវាងកុំឲ្យដំណើរការនេះបម្រើឲ្យសហរដ្ឋអាមេរិកនោះ សហរដ្ឋអាមេរិកគួរតែរក្សាកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីបង្កើតរចនាសម្ព័ន្ធដ៏បិតថេរមួយសម្រាប់ឆ្លើយតបនឹងព្រហ្មទណ្ឌដ៏គួរឲ្យព្រឺព្រួច ។ ដូច្នេះដើម្បីធ្វើយ៉ាងនេះបាន សហរដ្ឋអាមេរិកត្រូវជួយបង្កើត«ចលនាតាមផ្លូវច្បាប់» ដែលធ្វើឲ្យពាក្យជាស់តឿនក្លាយជាច្បាប់និងវិធីបញ្ចុះបញ្ចូលឲ្យក្លាយជាចលករជំរុញឲ្យមានការអនុវត្តច្បាប់ ។

**សេខ ធារី**



# ◆ការពិភាក្សារវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិៈ តើកិច្ចព្រមព្រៀងទៅលើការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម កើតឡើងដោយរបៀបណា?




***(តពីលេខមុន)***

ច្បាប់ដែលជំរុញឲ្យមានដំណើរការនេះនឹងកំណត់ច្បាស់ថា មានតែបុគ្គលមួយចំនួនតូចតែប៉ុណ្ណោះនឹងត្រូវយកមកកាត់ទោស ។ ច្បាប់នេះនឹងប្រើឃ្លាដូចជា «គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមនិងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត» ។ រដ្ឋាភិបាលក៏នៅបានសន្យាថា ជនដែលត្រូវបានចោទប្រកាន់រួចហើយនឹងត្រូវចាប់ខ្លួនទាល់តែបាន ។ រដ្ឋាភិបាលក៏បានបញ្ជាក់ទៅលើរូបមន្តដូចដែលបានលើកឡើងនៅក្នុងសំបុត្រចុះខែមិថុនា ឆ្នាំ១៩៩៧ ដែលថាដែនសមត្ថកិច្ចបណ្តោះអាសន្នគឺឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដូច្នេះវាជាការបំភ្លេចចោលនូវគំនិតដែលថាសម្តេច ហ៊ុន សែន បានផ្សព្វផ្សាយថា ឧក្រិដ្ឋកម្មមុននិងក្រោយសម័យកាលនោះនឹងត្រូវរួមបញ្ចូលដែរ ។

អង្គការសហប្រជាជាតិបានបញ្ជាក់ច្បាស់ថា លទ្ធភាពនៃការលើកលែងទោសនិងនិរទោសមិនគួរឲ្យមានឡើយ នៅក្នុងករណីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ប៉ុន្តែរដ្ឋាភិបាលមិនបានរៀបចំខ្លួនរារាំងជាផ្លូវការដល់សិទ្ធិតាមរដ្ឋធម្មនុញ្ញរបស់ព្រះមហាក្សត្រក្នុងការប្រទានការលើកលែងទោស ឬការអនុគ្រោះទោសឡើយ ។ ប៉ុន្តែនេះហាក់ដូចជាមិនសំខាន់ប៉ុន្មានទេ ។

និយាយជារួម អន្តរាគមន៍របស់អាមេរិកាំងបានបង្កើតមានសុទិដ្ឋិនិយមខ្លះដែរ ប៉ុន្តែក៏បណ្តាលឲ្យមានការភ័ន្តច្រឡំដែរ ។ ការដែលថាអាមេរិកាំងនឹងដើរតួម្នាក់ឯងគឺជាការសំខាន់ណាស់ ។ សម្តេច ហ៊ុន សែន និងអ្នកដទៃទៀតជឿជាក់ថា ដោយមានកិច្ចគាំទ្រពីសំណាក់សហរដ្ឋអាមេរិក រាល់ដំណើរការជំនុំជម្រះក្តីនឹងមិនមានការរិះគន់ពីខាងក្រៅច្រើនពេកទេ ។

សម្តេច ហ៊ុន សែន ធ្វើសេចក្តីថ្លែងការណ៍នៅថ្ងៃទី១៩ ខែតុលា នៅឯអាកាសយានដ្ឋានពោធិចិនតុង ដែលគ្មានការគ្រោងទុកហើយ ធ្វើឲ្យអ្នកដទៃនៅក្នុងជួររដ្ឋាភិបាលមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ «នៅម៉ោងនេះយើងនិងអង្គការសហប្រជាជាតិដែលធ្វើការគិតពិចារណាយ៉ាងសំខាន់ទៅលើជំហររបស់សហរដ្ឋអាមេរិក ចំពោះយើងអាចឈានដល់កិច្ចព្រមព្រៀង ហើយខ្ញុំបានយល់ទៅលើសំណើនេះគ្មាននៅសល់មន្ទិលសង្ស័យអ្វីទៀតទេ» ។ ប៉ុន្មានថ្ងៃក្រោយមកនៅពេលដែលខ្ញុំជួបសម្តេច ហ៊ុន សែន សម្តេចមិននិយាយយោងដល់សេចក្តីថ្លែងការណ៍នេះឡើយ ហើយថែមទាំងមានចំណាប់អារម្មណ៍ផ្ទុយស្រឡះ ។

### ការឆ្លើយតបរបស់រដ្ឋាភិបាល

មហាសន្និបាតរបស់អង្គការសហប្រជាជាតិនៅក្នុងសេចក្តីសម្រេចប្រចាំឆ្នាំរបស់ខ្លួនស្តីពីសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជាបានជំរុញរដ្ឋាភិបាលកម្ពុជាឲ្យបន្តកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយនឹងអង្គការសហប្រជាជាតិ ក្នុងគោលបំណងឈានដល់កិច្ចព្រមព្រៀងមួយស្តីពីបញ្ហាបង្កើតតុលាការ ។

ការឆ្លើយតបទៅនឹងឯកសារដែលលោក ហ្សាកលីន បានផ្តល់ជូនកាលពីចុងខែសីហា កន្លងទៅ បានមកដល់ថ្ងៃទី២០ ខែធ្នូ ។ ឯកសារនេះមានចរិតយ៉ាងច្បាស់ដូចគ្នាទៅនឹងសំណើរបស់លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក វៀដឺមែន ។ អង្គជំនុំជម្រះ

វិសាមញ្ញនឹងត្រូវបង្កើតឡើងនៅតុលាការក្រុង សាលាឧទ្ធរណ៍ និងតុលាការកំពូល ។ មានចៅក្រមកម្ពុជាភាគច្រើននៅគ្រប់កម្រិត÷ ចៅក្រមខ្មែរបីរូបបរទេសពីររូបនៅសាលាដំបូង ចៅក្រមខ្មែរបួនរូប បរទេសបីរូបនៅសាលាឧទ្ធរណ៍ និងចៅក្រមខ្មែរប្រាំរូប បរទេសបួនរូប នៅតុលាការកំពូល ។ ប្រធានតុលាការត្រូវតែជាជនជាតិខ្មែរទាំងអស់ ។ សរុបទាំងអស់ចៅក្រមខ្មែរមានចំនួន១៨រូប និងបរទេស៩រូប ។ បុគ្គលទាំងអស់នេះនឹងត្រូវជ្រើសរើសតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ ចៅក្រមបរទេស អាចត្រូវបានជ្រើសតាំងដោយលោកអគ្គលេខាធិការ ក្រោយពីបានពិគ្រោះយោបល់ជាមួយនឹងរដ្ឋាភិបាលកម្ពុជា ។

ការសម្រេចចិត្តរបស់អង្គចៅក្រមត្រូវតែបានទទួលយកដោយ “មតិភាគច្រើនលើសលប់” ដូចដែលបានស្នើឡើងដោយ លោកឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក វៀដឺមែន ។ ឧទាហរណ៍ ចំពោះសេចក្តីសម្រេចរបស់សាលាដំបូង ត្រូវមានការគាំទ្រពីសំណាក់ ចៅក្រមបួនរូបក្នុងចំណោមចៅក្រមប្រាំរូប ហើយសម្រាប់សាលាឧទ្ធរណ៍គឺប្រាំរូបក្នុងចំណោមប្រាំពីររូប ។

មានលក្ខណៈវិនិច្ឆ័យមួយចំនួនក្នុងការជ្រើសរើសចៅក្រមនិងព្រះរាជអាជ្ញាដែលនឹងត្រូវសម្រេចនៅពេលក្រោយ ។ លក្ខណៈវិនិច្ឆ័យទាំងនេះហាក់ដូចជាមានន័យថាជនជាតិខ្មែរដែលនឹងត្រូវជ្រើសរើសឲ្យធ្វើចៅក្រមគឺអ្នកដែលកំពុងធ្វើការងារដើម្បី រឹតត្បិតត្រឹមត្រូវក្នុងគោលបំណងកំណត់ចំនួនឲ្យបានច្បាស់លាស់នូវអ្នកដែលមានវិជ្ជាជីវៈពិតប្រាកដនៅក្នុងចំណោមអ្នកដែលនឹងត្រូវ ជ្រើសរើស ។ ការរឹតត្បិតមួយទៀតដែលគួរឲ្យចាប់អារម្មណ៍នោះគឺថា បុគ្គលិកបម្រុងនឹងត្រូវជ្រើសរើសមកពីបុគ្គលិករដ្ឋ(នេះ ច្បាស់ជាមិនរួមបញ្ចូលបេក្ខជនមកពីសង្គមស៊ីវិលឡើយ ដែលជាក្រុមមួយដ៏សំខាន់នៅក្នុងប្រទេសកម្ពុជា) ។ រដ្ឋាភិបាលនឹងជ្រើស តាំងប្រធានការិយាល័យរដ្ឋបាលដោយខ្លួនឯង ។

នឹងមានសហព្រះរាជអាជ្ញាដែលមានមួយរូបជាជនជាតិកម្ពុជានិងមួយរូបទៀតជាបរទេស ។ សហព្រះរាជអាជ្ញាខ្មែរនឹង ត្រូវជ្រើសតាំងឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម រីឯសហព្រះរាជអាជ្ញាបរទេសនឹងត្រូវជ្រើសតាំងដោយលោក អគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ចំពោះការកាត់សេចក្តីអ្នកទាំងពីរត្រូវអនុម័តសម្រេចដីកាចោទប្រកាន់ដែលមានន័យ ថាសហព្រះរាជអាជ្ញាមួយរូបអាចបង្អាក់ការកាត់សេចក្តីដែលស្នើឡើងដោយសហព្រះរាជអាជ្ញាមួយរូបទៀត ។

មានបញ្ហាមួយចំនួនទៅលើផ្នែកច្បាប់សារធាតុ រួមទាំងការបង្កើតនិយមន័យសាជាថ្មីចំពោះពាក្យអំពើប្រល័យពូជសាសន៍ ដោយប្រៀបធៀបជាមួយនឹងអនុសញ្ញាដែលអាចនឹងបង្កើតជាបញ្ហាបាន ។ ប៉ុន្តែបញ្ហាសំខាន់ចម្បងគឺថាគ្មានការធានាឲ្យបាន គ្រប់គ្រាន់ចំពោះដំណើរការមួយដែលមានឯករាជ្យភាព ។

ប្រវត្តិឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទាក់ទងនឹងសុចរិតភាព គឺមិនអាចទុកចិត្តបានឡើយ ។ តាមពិត ទោះបីជាក្រុមប្រឹក្សានៃ អង្គចៅក្រមមិនអាចបដិសេធចោលនូវការជ្រើសតាំងពីសំណាក់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិក៏ដោយ ក៏វាជា គុណវិបត្តិមួយដ៏ធំដែលថាសហគមន៍អន្តរជាតិមិនត្រូវបានផ្តល់នូវឱកាសឲ្យមានមតិទៅលើការជ្រើសតាំងជនជាតិកម្ពុជា ។ នេះក៏នឹង អាចបង្កើតចំណាប់អារម្មណ៍ទៅលើប្រភេទពីរផ្សេងគ្នានៃចៅក្រម ហើយចៅក្រមមួយប្រភេទមិនអាចនិយាយថាខ្លួនមានការគាំទ្រ ពីសំណាក់អន្តរជាតិ ។ បើតាមសេចក្តីព្រាងច្បាប់នេះការដែលថាសហព្រះរាជអាជ្ញាមួយរូបអាចរារាំងមិនឲ្យសហព្រះរាជអាជ្ញាមួយ រូបទៀតមានសកម្មភាពបាននោះក៏ជាបញ្ហាចម្បងដែរ ។ តាមពិតវាអាចធ្វើឲ្យអាក់ខានដល់ការកាត់ក្តីដែលមានលក្ខណៈស្របច្បាប់ ។

នៅដើមខែធ្នូ សម្តេចនាយករដ្ឋមន្ត្រីខ្លួនឯងបានធ្វើអន្តរាគមន៍ដ៏សំខាន់មួយនៅក្នុងប្រព័ន្ធតុលាការ ។ សម្តេចបានចោទ ប្រកាន់ចៅក្រមថា បានប្រព្រឹត្តអំពើពុករលួយហើយបានបញ្ជាឲ្យចាប់ខ្លួនសាជាថ្មីចំពោះអ្នកដែលត្រូវបានតុលាការឲ្យរួចខ្លួនពីការ ចោទប្រកាន់ ។ ទោះបីជាការរិះគន់ទៅលើការធ្វេសប្រហែសទាំងនេះមានលក្ខណៈស្របជាមួយនឹងការសង្កេតហេតុការណ៍របស់ខ្ញុំ ក៏ដោយ តែការធ្វើអន្តរាគមន៍របស់សម្តេច ហ៊ុន សែន ក៏បង្ហាញដែរថា សុចរិតភាពរបស់ប្រព័ន្ធតុលាការមិនត្រូវបានគោរពដោយ អំណាចនីតិប្រតិបត្តិឡើយ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមិនទាក់ទងដោយផ្ទាល់នៅក្នុងព្រឹត្តិការណ៍នេះឡើយ ដែលជាប្រផ្នូល

អាក្រក់ ក្នុងវិភាគទានដល់តុលាការខ្មែរក្រហម ។

នៅលើបញ្ហាចម្រូងចម្រាសស្តីអំពីថាតើមេដឹកនាំខ្មែរក្រហមប៉ុន្មាននាក់នឹងត្រូវបានចោទប្រកាន់ នេះជាប្រសាសន៍របស់សម្តេច ហ៊ុន សែន ដែលថ្លែងជាសាធារណៈជាថ្មីម្តងទៀត ។ សម្តេច ហ៊ុន សែន មានប្រសាសន៍នៅក្នុងសុន្ទរកថាមួយថា "យើងនឹងព្យាយាមកាត់ទោសបុគ្គលបួនឬប្រាំនាក់តែប៉ុណ្ណោះដែលមានការទទួលខុសត្រូវ" ។ នេះជាប្រការគួរឲ្យសោកស្តាយ ជាពិសេសប្រឆាំងទៅនឹងបញ្ហាទាក់ទងនឹងចំណុចផ្សេងៗទៀតស្តីអំពីឯករាជ្យភាពរបស់ប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជា ។ ចំនួនអ្នកដែលត្រូវបានចោទប្រកាន់បួនឬប្រាំនាក់នោះ ស្ទើរតែអាចដាក់ឈ្មោះរួចជាស្រេចទៅហើយ ។ ស្តីអំពីបញ្ហាថាតើ អៀង សារី នឹងត្រូវចោទប្រកាន់ដែរឬទេ សម្តេចនាយករដ្ឋមន្ត្រីបានប្រកាសជំហរផ្សេងៗពីគ្នាទៅតាមឱកាស ។ នៅខែធ្នូ សម្តេចមានប្រសាសន៍ថា អៀង សារី មិនគួរត្រូវបានបញ្ចូលទៅក្នុងដំណើរការកាត់សេចក្តីឡើយ ។

ជាសង្ខេបមក សំណើសេចក្តីព្រាងច្បាប់គឺមិនអាចទទួលយកបានទេ ។ សេចក្តីព្រាងនេះមិនមានការធានាឲ្យបានគ្រប់គ្រាន់ចំពោះយុត្តិធម៌ពិតប្រាកដភាពគ្មានលម្អៀងនិងនីតិវិធីត្រឹមត្រូវតាមច្បាប់ ។ សូម្បីតែនៅក្នុងន័យដូវការ ក៏រដ្ឋាភិបាលមិនបានដាច់ខ្លួនចេញពីដំណើរការកាត់ទោសដែរ ។ ដោយបានដឹងអំពីឥទ្ធិពលពិតប្រាកដពីសំណាក់រដ្ឋាភិបាលទៅលើបញ្ហាតុលាការ យើងត្រូវតែទាញសន្និដ្ឋានថា គ្មានការការពារគ្រប់គ្រាន់ដែលត្រូវបានកសាងឡើងនៅក្នុងសំណើនេះឡើយ ។

គំនិតរបស់ខ្ញុំគឺថារូបមន្ត"មតិភាគច្រើនលើសលប់" អាចត្រូវបានទទួលយក ប្រសិនបើយន្តការអន្តរជាតិមួយបានពិនិត្យជ្រើសរើសចៅក្រមនិងព្រះរាជអាជ្ញាទាំងអស់ ។ យ៉ាងហោចណាស់សហគមន៍អន្តរជាតិគួរតែត្រូវបានទទួលឋានៈស្មើភាពជាមួយនឹងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៅក្នុងការជ្រើសតាំងនេះ ។

គំនិតបង្កើតតុលាការ"ចម្រុះ"ត្រូវបានបង្កើតឡើងតាមការសន្និដ្ឋានដែលថាសហគមន៍អន្តរជាតិនឹងបង្ហាញចេញគំរូបទដ្ឋានដែលមានលក្ខណៈចាំបាច់ ។ ជាការសំខាន់ណាស់ដែលថាតុលាការអាចមានភាពគួរឲ្យទុកចិត្តបាននៅក្នុងប្រទេសកម្ពុជា ។ នេះវាអាស្រ័យដោយផ្ទាល់ទៅលើកម្រិតនៃការចូលរួមរបស់អន្តរជាតិ ។ ជាការសំខាន់ណាស់ថាក្រុមសិទ្ធិមនុស្សក្នុងស្រុកបានទាញហេតុផលឲ្យមានមតិភាគច្រើនសម្រាប់ចៅក្រមបរទេស ប្រសិនបើមិនមែនជាតុលាការអន្តរជាតិទាំងស្រុងទេនោះ ។ ដើម្បីភាពជឿជាក់ជាការចាំបាច់គឺត្រូវបង្ហាញឲ្យឃើញថាដំណើរការកាត់សេចក្តីខ្មែរក្រហម ត្រូវបានរៀបចំឡើងនៅក្នុងផ្លូវមួយដែលមានលក្ខណៈខុសប្លែកពីគន្លងចាស់ៗនៅក្នុងប្រទេសកម្ពុជា ។ នេះជាការទាញហេតុផលមួយឲ្យមានដំណោះស្រាយតុលាការពិសេសជាជាង"អង្គជំនុំជម្រះវិសាមញ្ញ"ដែលភ្ជាប់ខ្លួនទៅនឹងប្រព័ន្ធតុលាការដែលមានស្រាប់ ។

## សេចក្តីបញ្ជាក់ថែមទៀតរបស់អង្គការសហប្រជាជាតិ

នៅក្នុងការដាក់ជូនលេខាធិការដ្ឋានអង្គការសហប្រជាជាតិនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ រដ្ឋាភិបាលកម្ពុជាបានសុំឲ្យលេខាធិការដ្ឋានអង្គការសហប្រជាជាតិឆ្លើយតបឲ្យបានឆាប់រហ័ស ហើយពេលនោះលេខាធិការដ្ឋានក៏ឆ្លើយតបទាន់ចិត្តមែន ។ នៅថ្ងៃទី២៣ ខែធ្នូ ការឆ្លើយតបមួយត្រូវបានធ្វើឡើងដោយមានចំណុចនានាដូចដែលបានលើកឡើងនៅខាងលើ ។ គណៈរដ្ឋមន្ត្រីពេលនេះគឺកំពុងតែធ្វើការនៅទីក្រុងភ្នំពេញ ហើយនៅថ្ងៃទី២៨ ខែធ្នូ អង្គការសហប្រជាជាតិបានទទួលសំណើមួយទៀតដែលមានការកែប្រែមួយចំនួនតូចទៅនឹងឯកសារចុះថ្ងៃទី២០ខែធ្នូ ហើយក៏ដូចជាលើកមុនដែរ គឺមានការទទូចឲ្យឆ្លើយតបឲ្យបានឆាប់រហ័ស ។ លេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិបានផ្ញើនូវការឆ្លើយតបវិញនៅថ្ងៃទី៥ ខែមករា ។ នៅថ្ងៃទី១៨ ខែមករា អង្គការសហប្រជាជាតិបានទទួលនូវសេចក្តីព្រាងច្បាប់ប្រែសម្រួលមួយ ហើយសេចក្តីព្រាងច្បាប់នេះក៏ត្រូវបានដាក់ជូនសភាជាតិ ហើយចេញផ្សាយជាសាធារណៈនៅពេលនោះដែរ ។

សំណើរបស់រដ្ឋាភិបាលចំពោះសភាជាតិមានជម្រើសមួយចំនួនទៅលើបញ្ហាថា តើអ្នកណានឹងជ្រើសតាំងចៅក្រមនិងព្រះរាជ

អាជ្ញាបរទេស ។ ក្រៅពីលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ រដ្ឋាភិបាលបរទេសនានាក៏អាចត្រូវបានអញ្ជើញឲ្យផ្ញើសេចក្តីស្នើនេះដែរ ។ ជម្រើសផ្សេងទៀតដែលត្រូវបានលើកបញ្ជាក់ច្បាស់គឺរដ្ឋាភិបាលកម្ពុជាខ្លួនឯងក៏អាចជ្រើសរើសនៅក្នុងចំណោមអ្នកច្បាប់បរទេស (ប្រការទាំងនេះមាននៅក្នុងសេចក្តីព្រាងច្បាប់ដើម បន្ទាប់មកត្រូវបានលុបចេញរួច ហើយដាក់ចេញសាជាថ្មី) ។

មានចំណុចផ្សេងៗទៀតនៅក្នុងសេចក្តីព្រាងច្បាប់ថ្មីនេះដែលមានបញ្ហា ។ ការនិយាយយោងដល់ចៅក្រមស៊ើបអង្កេតត្រូវបានរក្សាទុកដដែល ដែលតាមការពិតមានន័យថាជាការចម្រាញ់មួយទៀតចំពោះការសម្រេចរបស់ព្រះរាជអាជ្ញា ។ សូម្បីតែនៅក្នុងប្រព័ន្ធតុលាការសាមញ្ញទូទៅនៅក្នុងប្រទេសកម្ពុជា ក៏នីតិវិធីរបស់ចៅក្រមស៊ើបអង្កេតមានភាពច្របូកច្របល់និងមិនដំណើរការទៅបានរលូនដែរ ។

មិនតែប៉ុណ្ណោះ នៅគ្មានការចែងគ្រាប់គ្រាន់សម្រាប់ឲ្យមានការចូលរួមរបស់មេធាវីការពារក្តីបរទេស និងការការពារចំពោះសាក្សីឡើយ ។ ជាងនេះទៅទៀតមិនមានការបញ្ជាក់ឲ្យបានច្បាស់លាស់ថា ការលើកលែងទោសកន្លងទៅនឹងមិនមានការរារាំងដល់ការកាត់ក្តីនេះឡើយ ។

ក៏ប៉ុន្តែរដ្ឋាភិបាលកម្ពុជាឲ្យសញ្ញាថា កិច្ចចរចារបស់ខ្លួនជាមួយនឹងអង្គការសហប្រជាជាតិ ប្រហែលជាមិនអាចត្រូវបានមើលឃើញថាមានលក្ខណៈជិតដិតទេ ។ តាមការពិតអង្គការសហប្រជាជាតិ បានអញ្ជើញរដ្ឋាភិបាលកម្ពុជាឲ្យបញ្ជូនតំណាងរបស់ខ្លួនមកកាន់ទីក្រុងញូវយ៉ក ដើម្បីពិភាក្សាស៊ីជម្រៅថែមទៀត ។ ប៉ុន្តែរដ្ឋាភិបាលចង់ឲ្យមានអ្នកជំនាញការរបស់អង្គការសហប្រជាជាតិមកកាន់ទីក្រុងភ្នំពេញវិញ ។ អង្គការសហប្រជាជាតិស្នើសុំពិភាក្សាទៅលើបញ្ហាធំៗទាក់ទងនឹងដំណោះស្រាយនិងគោលការណ៍ចំណែកខាងរដ្ឋាភិបាលកម្ពុជាចង់ឲ្យមានការពិភាក្សាលើបញ្ហាបច្ចេកទេស ។

ការព្រួយបារម្ភនៅតែមាននៅក្នុងសេចក្តីព្រាងច្បាប់ដែលត្រូវបានដាក់ស្នើទៅរដ្ឋសភាជាតិ ដូចដែលបានពន្យល់នៅក្នុងសំបុត្ររបស់លោកអគ្គលេខាធិការជូនចំពោះនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅថ្ងៃទី៨ ខែកុម្ភៈ ។ កង្វល់ទាំងអស់នេះរួមមានបួនចំណុចដូចជា÷ ១) សូមឲ្យមានការធានាថា ក្រោយពីមានការចេញដីកាចោទប្រកាន់ ជនជាប់ចោទត្រូវតែបានចាប់ខ្លួនឲ្យខាងតែបាន ។ ២) សូមឲ្យគ្មានការលើកលែងទោសឬបន្ធូរបន្ថយទោស ។ ៣) សូមឲ្យមានព្រះរាជអាជ្ញាជាជនបរទេស ដើម្បីធានាឲ្យប្រាកដថានឹងមានឯករាជ្យភាពពិតប្រាកដ ។ ៤) ភាគច្រើននៃអង្គចៅក្រមគឺត្រូវតែជាជនជាតិបរទេសហើយត្រូវបានជ្រើសតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ លោកអគ្គលេខាធិការចង់ឲ្យមានការឆ្លើយតបចំពោះចំណុចគោលការណ៍ទាំងនេះ មុនពេលសម្រេចថានឹងបញ្ជូនក្រុមអ្នកជំនាញការមកកាន់ទីក្រុងភ្នំពេញដើម្បីធ្វើការពិភាក្សាស៊ីជម្រៅថែមទៀត ។

នៅក្នុងការឆ្លើយតបវិញនៅថ្ងៃទី១០ ខែកុម្ភៈ សម្តេច ហ៊ុន សែន បានសរសេរថា សម្តេចមានការភ្ញាក់ផ្អើលចំពោះ "គម្លាតរវាងជំហរដែលបានលើកឡើងនៅក្នុងសំបុត្ររបស់លោកអគ្គលេខានិងសំបុត្ររបស់យើងដែលត្រូវបានគាំទ្រដោយប្រទេសជាសមាជិកមួយចំនួនរួចទៅហើយនោះ" ។

លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានជួបជាមួយសម្តេច ហ៊ុន សែន នៅថ្ងៃទី១៧ ខែមករា នៅទីក្រុងបាងកក ។ ក្រោយពីកិច្ចប្រជុំលោកអគ្គលេខាបានរាយការណ៍ថា "ការព្រួយបារម្ភសំខាន់របស់អង្គការសហប្រជាជាតិគឺប្រព័ន្ធតុលាការដែលនឹងត្រូវបានបង្កើតឡើងក្រោមច្បាប់របស់កម្ពុជាមិនអាចមានកម្រិតបទដ្ឋានអន្តរជាតិពិតប្រាកដ ។ ត្រូវមានការធានាចាប់ខ្លួន និងប្រគល់ខ្លួនជនជាប់ចោទ ។ មិនត្រូវគិតបញ្ចូលការលើកលែងទោសចំពោះអំពើប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយត្រូវបញ្ចូលធាតុផ្សំអន្តរជាតិមួយសមស្របនៅក្នុងចំណោមព្រះរាជអាជ្ញានិងចៅក្រម" ។

លោក ហេន កូរែល បានមកធ្វើទស្សនកិច្ចនៅទីក្រុងភ្នំពេញចាប់ពីថ្ងៃទី១៦ ដល់ថ្ងៃទី២២ ខែមីនា ដោយដឹកនាំគណៈប្រតិភូអង្គការសហប្រជាជាតិដែលមានសមាជិក៧រូបជំនាញខាងកិច្ចការនយោបាយនិងច្បាប់ ។ នៅពេលនោះមានការឈានដល់កិច្ចព្រម

ព្រៀងមួយចំនួន ប៉ុន្តែខាងរដ្ឋាភិបាលកម្ពុជាសម្រេចចិត្តមិនបញ្ជូនទៅកាន់សភាជាតិដែលក្រោយមកបន្តជាការភ័ន្តច្រឡំខ្លះ ។ បញ្ហាដែលលេចធ្លោនៅចុងបញ្ចប់នៃបេសកកម្មរបស់លោក ហេន កូរ៉េល គឺលទ្ធភាពរបស់ព្រះរាជអាជ្ញាបរទេសក្នុងការសម្រេចដោយគ្មានការគាំទ្រពីសំណាក់សហការីខាងកម្ពុជា ។

សម្តេច ហ៊ុន សែន បានបរិយាយត្រួសៗទៅលើបញ្ហានេះនៅក្នុងសេចក្តីថ្លែងការណ៍របស់សម្តេចពេលចេញទៅចូលរួមកិច្ចប្រជុំក្រុម៧៧នៅទីក្រុងហាវ៉ាណានាពាក់កណ្តាលខែមេសា ដែលនៅទីនោះសម្តេចក៏បានជួបលោក កូហ្វីអាណាន់ ដែរ ។ សម្តេចបានព្រមានថា ប្រសិនបើគ្មានការគាំទ្រដល់ជំហររបស់សម្តេចដែលថា ព្រះរាជអាជ្ញាពីររូបត្រូវតែយល់ព្រមចំពោះការចេញដីកាចោទប្រកាន់ទេនោះ ព្រះរាជអាជ្ញាមួយរូប (សម្តេចចង់និយាយដល់ព្រះរាជអាជ្ញាជនជាតិកម្ពុជា) ក្នុងចំណោមព្រះរាជអាជ្ញាដទៃទៀត អាចសង្កត់ឲ្យមានការពាក់ព័ន្ធដល់មេដឹកនាំអាមេរិក ឬអ្នកដែលបានគាំទ្រដល់ខ្មែរក្រហម ។

នៅក្នុងកិច្ចប្រជុំជាមួយគ្នានៅទីក្រុងហាវ៉ាណា សម្តេច ហ៊ុន សែន និង លោកអគ្គលេខាអង្គការសហប្រជាជាតិបានយល់ព្រមឲ្យក្រុមការងាររបស់ខ្លួនជួបគ្នាជាថ្មីម្តងទៀត ដើម្បីបន្តកិច្ចពិភាក្សាក្នុងគោលបំណងដោះស្រាយជាលើកចុងក្រោយនូវការខ្វែងគំនិតគ្នានានាកន្លងមក ។ ប៉ុន្តែនៅថ្ងៃទី២៧ ខែមេសា លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសរសេរសំបុត្រទៅកាន់លោកអគ្គលេខាជាថ្មីម្តងទៀតដោយបញ្ជាក់ថា ច្បាប់នេះក៏នឹងបើកចំហឲ្យមានការកាត់សេចក្តីទៅលើបទឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងអំឡុងឆ្នាំ១៩៧០ - ១៩៩៩ ។ នេះអាចមានន័យថា ជាការធ្វើនយោបាយកម្មយ៉ាងជាក់ច្បាស់ទៅលើដំណើរការនេះ ។ បញ្ហាថាតើព្រះរាជអាជ្ញាមួយរូប អាចជំទាស់ការចោទប្រកាន់បានដែរឬយ៉ាងណា ទើបចេញជារូបរាងឡើងសម្រាប់ការពិភាក្សាស៊ីជម្រៅថែមទៀតរួមទាំងនៅក្នុងកិច្ចប្រជុំនៅចុងខែមេសា រវាងសម្តេច ហ៊ុន សែន និងសមាជិកព្រឹទ្ធសភា ចន ឃែរី ដែលនៅពេលនេះបានធ្វើការពិគ្រោះយោបល់ជាមួយនឹងលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិដែលនាំឲ្យមានសំណើមួយនៅទីក្រុងភ្នំពេញ សុំឲ្យអង្គចៅក្រមផ្សេងៗពីគ្នាដោះស្រាយនូវជម្លោះរវាងព្រះរាជអាជ្ញាទាំងពីរ ។ សំណើដាច់ដោយឡែកមួយមកពីព្រះរាជអាជ្ញាមួយរូបអាចត្រូវបានជំទាស់ ប្រសិនបើអង្គចៅក្រមបួនរូបក្នុងចំណោមអង្គចៅក្រមទាំងប្រាំរូប (បីរូបជាខ្មែរនិងពីររូបជាបរទេស) នៅក្នុងក្រុមនេះបដិសេធ ។ ទោះបីជាដំណោះស្រាយនេះហាក់ដូចជាចម្លែកបន្តិច ហើយគ្មានគោលការណ៍ត្រឹមត្រូវក៏ពិតមែន តែនៅតាមប្រព័ន្ធឃោសនាមួយចំនួន ដំណោះស្រាយនេះត្រូវបានហៅថាជាការសម្របសម្រួលមួយយ៉ាងធំពីសំណាក់ខាងរដ្ឋាភិបាលកម្ពុជា ។

**ទឹកចុងក្រោយៈ** លោក ហេន កូរ៉េល បានវិលត្រឡប់មកទីក្រុងភ្នំពេញនៅដើមខែកក្កដា ដើម្បីចូលរួមកិច្ចចរចាជាលើកចុងក្រោយផ្តាច់ព្រ័ត្រ ។ នៅក្រោយពីកិច្ចពិភាក្សាលោក ហេន កូរ៉េល ហៅតុលាការនេះថាជា“សាលាជំនុំជម្រះក្តីកម្ពុជាដោយមានការចូលរួមពីសំណាក់ចៅក្រមនិងព្រះរាជអាជ្ញាអន្តរជាតិ”នេះជាការស្រាយបំភ្លឺឲ្យដឹងថា ដំណើរការជំនុំជម្រះក្តីនឹងលែងមានលក្ខណៈអន្តរជាតិនៅលើទឹកដីកម្ពុជា ឬតុលាការចម្រុះ ពោលគឺដំណើរការជំនុំជម្រះក្តីរបស់កម្ពុជាដោយមានជំនួយពីខាងក្រៅ ។ ការនេះហាក់បញ្ជាក់មិនត្រឹមតែថាជាបញ្ហាទទួលស្គាល់ថាលក្ខន្តិកៈគ្រឹះនឹងត្រូវជាច្បាប់អនុម័តដោយសភាជាតិប៉ុណ្ណោះទេ តែថែមទាំងជាសារមួយមួយបង្ហាញថាអង្គការសហប្រជាជាតិនឹងមិនមានតួនាទីថ្លឹងតុល្យភាពទៀតផង ។

លោក ហេន កូរ៉េល បានប្រគល់សេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នាដែលនឹងរក្សាទំនាក់ទំនងរវាងអង្គការសហប្រជាជាតិនិងកម្ពុជា ស្តីអំពីបញ្ហាតុលាការ ។ អនុស្សរណៈនេះនឹងចុះហត្ថលេខាក្រោយពីសភាជាតិបានអនុម័តច្បាប់ស្របតាមការយោគយល់គ្នារវាងភាគីទាំងពីរជាមុនសិន ។ មានការចែងច្បាស់ថា អង្គការសហប្រជាជាតិនឹងគ្មានលទ្ធភាពគាំទ្រដល់“អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ” ប្រសិនបើសភាជាតិអនុម័តច្បាប់ដែលមានចរិតខុសពីអ្វីដែលបានគ្រោងឡើងនៅក្នុងសេចក្តីព្រាងនៃអនុស្សរណៈនៃការយោគយល់គ្នាទេនោះ ។

**(នៅមានត)**

**ចិនបរិយាយៈ**

# ហេតុអ្វីបានជាអាជ្ញាធរវៀតណាមបង្កជម្លោះព្រំដែនវៀតណាម-កម្ពុជា?

***(ថ្ងៃទី១២ ខែកក្កដា ឆ្នាំ១៩៧៨)***

ជម្លោះព្រំដែនដែលបានបន្តមកអស់ជាងបីឆ្នាំហើយនោះ កាន់តែរីករាលដាលធំឡើងកាលពីឆ្នាំទៅមិញ ។ ប្រទេសចិនតែងតែបានគាំទ្រឲ្យមានដំណោះស្រាយជម្លោះតាមគោលការណ៍សន្តិសហវិជ្ជមានទាំង៥ និងតាមរយៈការពិគ្រោះយោបល់និងចរចាជាលក្ខណៈមិត្តភាពជានិច្ច ។ ចិនតែងតែជំទាស់ទៅនឹងការងាកមកប្រើកម្លាំង ឬការគំរាមកំហែងប្រើកម្លាំងនៅក្នុងរឿងនេះ ។ ចំពោះជម្លោះរវាងវៀតណាមនិងកម្ពុជា ចិនតែងសង្ឃឹមថា ភាគីទាំងសងខាងនឹងបង្កលក្ខណៈងាយស្រួលក្នុងការដោះស្រាយតាមផ្លូវចរចាជាមិនខាន ។

នៅពេលមានការមិនទទួលស្គាល់ជាសមាជិកសង្គម ការធ្វើទុក្ខបុកម្នេញនិងការបណ្តេញជនជាតិចិនជាច្រើនចេញពីប្រទេសវៀតណាម អាជ្ញាធរវៀតណាមបានបង្កជម្លោះព្រំដែនវៀតណាមកម្ពុជាក្នុងគោលបំណងបង្ខូចកេរ្តិ៍ឈ្មោះប្រទេសចិន ។ វៀតណាមបានភូតកុហក«តាមរបៀបសម្ងាត់»ថា ចិនមិនត្រឹមតែបានជំរុញឲ្យកម្ពុជាប្រឆាំងវៀតណាមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង«បង្កឲ្យមានសង្គ្រាមព្រំដែនវៀតណាម-កម្ពុជាទៀតផង» ។ វៀតណាមនៅបានឃោសនាមួលបង្កាច់ថា ចិនកំពុងតែអនុវត្ត«អនុត្តរភាព» និងស្វែងរកអំណាចផ្តាច់មុខនៅភូមិភាគអាស៊ី-អគ្នេយ៍នេះ ។ ហេតុដូច្នេះយើងយល់ថា ជាការសំខាន់ណាស់ក្នុងការលាតត្រដាងការពិតស្តីអំពីជម្លោះព្រំដែនវៀតណាម-កម្ពុជា ហើយនិងសូមបដិសេធការការបង្ខូចកេរ្តិ៍ឈ្មោះរបស់អាជ្ញាធរវៀតណាមមកលើចិន ។

ដូចអ្នកផងទាំងពួងដឹងស្រាប់ហើយថា ខ្សែបន្ទាត់ព្រំដែនដែលមានស្រាប់រវាងវៀតណាមនិងកម្ពុជា ត្រូវបានកំណត់ឡើងដោយពួកអាណានិគម ។ មានរឿងលើកឡើងថា មានការកាត់ដីកម្ពុជាក្រោមរាប់សែនគីឡូម៉ែត្រក្រឡាជាមួយនឹងកោះមួយចំនួន និងតំបន់នៅជាប់សមុទ្រដែលជារបស់កម្ពុជាតាំងពីដើមមក ។ តែទោះបីជាយ៉ាងណាក៏ដោយ ក៏រដ្ឋាភិបាលកម្ពុជាទាំងអតីតនិងបច្ចុប្បន្នបានទទួលស្គាល់ខ្សែបន្ទាត់ព្រំដែននេះថាមានលក្ខណៈត្រឹមត្រូវហើយ ។ នៅឆ្នាំ១៩៦៦ វៀតណាមនិងកម្ពុជាបានចរចាលើបញ្ហាព្រំដែន ។ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៦៧ គណៈកម្មាធិការមជ្ឈិមបក្សនៃរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង បានចេញសេចក្តីថ្លែងការណ៍មួយដែលទទួលស្គាល់និងគោរពបូរណភាពទឹកដីនៅក្នុងខ្សែបន្ទាត់ព្រំដែនបច្ចុប្បន្ននេះ ។ នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៦៧ រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមក៏បានចេញសេចក្តីថ្លែងការណ៍មួយដែរក្នុងការទទួលស្គាល់ខ្សែបន្ទាត់ព្រំដែនដែលមានស្រាប់រវាងវៀតណាមនិងកម្ពុជា ។ ១២ថ្ងៃ(ក្រោយពីសេចក្តីថ្លែងការណ៍ថ្ងៃទី២០) នេះមានសំបុត្រមួយច្បាប់របស់នាយករដ្ឋមន្ត្រី ផាម វ៉ាន់ ដុង និងសំបុត្រមួយច្បាប់ទៀតរបស់ប្រធានរដ្ឋ ហូជីមិញ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៦៧ ផ្ញើមកមេដឹកនាំកម្ពុជាកាលនោះ ដោយបញ្ជាក់ជាថ្មីម្តងទៀតថា«វៀតណាមទទួលស្គាល់បូរណភាពទឹកដីរបស់កម្ពុជាដែលមានព្រំប្រទល់ដូចសព្វថ្ងៃនេះ» ។ នៅក្នុងសេចក្តីសំបុត្រនេះ នាយករដ្ឋមន្ត្រី ផាម វ៉ាន់ដុង មានប្រសាសន៍ថា សេចក្តីប្រកាសទទួលស្គាល់របស់វៀតណាម «គឺពិតជាមូលដ្ឋានត្រឹមត្រូវនិងរឹងមាំនៃយុទ្ធសាមគ្គីភាពសម្រាប់ទប់ទល់ជាមួយខ្មាំងសត្រូវដូចជាពួកឈ្លានពានអាមេរិកាំងជាដើម និងជាភាតរភាពដែលចង់រឹតចំណងសាមគ្គីភាពរវាងប្រជាជននៃប្រទេសយើងទាំងពីរ» ។

នេះសបញ្ជាក់ច្បាស់ថា ឥរិយាបថកម្ពុជាចំពោះបញ្ហាព្រំដែនវៀតណាម-កម្ពុជាគឺមានលក្ខណៈសមហេតុសមផល និងយុត្តិធម៌ ហើយថាវៀតណាមក៏ទទួលស្គាល់ខ្សែបន្ទាត់ព្រំដែន

សព្វថ្ងៃនេះដែរ ។

ប៉ុន្តែក្រោយពីសង្គ្រាមជាមួយសហរដ្ឋអាមេរិកបានផុតរលត់ទៅ អាជ្ញាធរវៀតណាមបានផ្លាស់ប្តូរឥរិយាបថចំពោះបញ្ហាព្រំដែនវៀតណាម-កម្ពុជា ។ ចាប់តាំងពីខ្លួនបានកាន់កាប់កោះវៃរបស់កម្ពុជាក្នុងឆ្នាំ១៩៧៥មក វៀតណាមបានទន្ទ្រានទឹកដីកម្ពុជាឥតឈប់ឈរ ។ នៅក្នុងការចរចារវាងវៀតណាមនិងកម្ពុជាក្នុងឆ្នាំ១៩៧៦ អាជ្ញាធរវៀតណាមថែមទាំងបានធ្វើឲ្យបង្វែរទិសនៃការសន្យារបស់ខ្លួនក្នុងឆ្នាំ១៩៦៦ និងឆ្នាំ១៩៦៧ ដែលថាខ្លួន«ទទួលស្គាល់និងគោរពខ្សែបន្ទាត់ព្រំដែនដែលមានស្រាប់» ។ អាជ្ញាធរវៀតណាមនិយាយថា កិច្ចព្រមព្រៀងដែលខ្លួនបានធ្វើឡើងជាមួយកម្ពុជានៅក្នុងឆ្នាំ១៩៦៦ គឺត្រូវបានធ្វើឡើងដោយបង្ខំចិត្តដើម្បីប្រយោជន៍វាយចក្រពត្តិអាមេរិក ។ នេះជាអំពើដែលមានបំណងមិនល្អធ្វើឡើងដើម្បីសម្រេចនយោបាយរបស់ខ្លួន ។ មិនតែប៉ុណ្ណោះសោត វៀតណាមបានបង្ខិតបន្ទាត់ព្រំដែនទៀតផង ។ ជាទូទៅអំពើមិនសមហេតុផលបែបនេះត្រូវបានកម្ពុជាជំទាស់មិនយល់ស្របឡើយ ។

ក្រោយពីបរាជ័យមិនបានសម្រេចតាមមហិច្ឆតារបស់ខ្លួនក្នុងការយកដីថែមទៀតតាមរយៈតុចរចា អាជ្ញាធរវៀតណាមបានងាកមកប្រើកម្លាំងប្រដាប់អាវុធវិញ ។ នៅដើមខែកញ្ញា ឆ្នាំ១៩៧៧វៀតណាមបានបញ្ជូនកងទ័ពជាច្រើនពាន់នាក់ដាក់រាយតាមព្រំដែនដើម្បីវាយកម្ពុជាក្នុងទ្រង់ទ្រាយធំ ។ សង្គ្រាមបានផ្ទុះឡើងនៅប៉ែកបូព៌ានៃប្រទេសកម្ពុជា និងនៅតាមតំបន់មួយចំនួន កងទ័ពវៀតណាមបានលួចជ្រៀតចូលរាប់សិបគីឡូម៉ែត្រមកក្នុងទឹកដីកម្ពុជា ។ នេះមិនមែនជាការវាយរបេះរបោះតាមព្រំដែនទេ ប៉ុន្តែជាសង្គ្រាមឈ្លានពានរបស់វៀតណាមចូលក្នុងទឹកដីកម្ពុជា ។ អាជ្ញាធរវៀតណាមគិតថា កម្ពុជាដែលមានប្រជាជនប៉ុន្មានលាននាក់នោះ មិនអាចក្រោកឈរទប់ទល់ជាមួយវៀតណាមដែលមានប្រជាជនរហូតដល់៥០លាននាក់ឡើយ ។ វៀតណាមគិតថាខ្លួនពិតជាអាចដាក់កម្ពុជាឲ្យស្ថិតនៅក្រោមអំណាចរបស់ខ្លួនយ៉ាងងាយ នៅពេលកងទ័ពវៀតណាមដើរចូលក្នុងទឹកដីកម្ពុជា ។ ប៉ុន្តែប្រជាជនកម្ពុជាដែលវាសនាប្រទេសជាតិខ្លួនកំពុងស្ថិតនៅក្នុងការគំរាមកំហែង បានក្រោកឈរឡើងការពារមាតុភូមិ ។ ប្រជាជនកម្ពុជាបានងើបឈរឡើងប្រយុទ្ធយ៉ាងអង់អាចក្លាហាននិងធ្វើការវាយបកនិងកម្ទេចវៀតណាមឈ្លានពានជាញឹកញាប់ ។ ក្រោយពីទទួលនូវការវាយបកយ៉ាងចាស់ដៃ អាជ្ញាធរវៀតណាម បានដំណើរការម៉ាស៊ីនឃោសនារបស់ខ្លួនភ្លាម ។ វៀតណាមបានចោទប្រកាន់ថា កម្ពុជាទេជាអ្នកឆ្លងកាត់ព្រំដែនចូលមកលុកលុយទឹកដីវៀតណាម ។ ប៉ុន្តែល្បិចនេះមិនអាចបោកអ្នកណាបានឡើយ ។ អំពើមិនអាចប្រកែកបាន នេះបានបង្ហាញឲ្យឃើញថាអាជ្ញាធរវៀតណាមទេ ដែលជាអ្នកបង្កជម្លោះព្រំដែនដោយគ្មានជំនួយពីអ្នកណាម្នាក់ក្នុងគោលបំណងកាន់កាប់និងដាក់កម្ពុជាឲ្យស្ថិតនៅក្រោមចំណុះរបស់ខ្លួនតាមរយៈការប្រើកម្លាំង ។ ការចោទប្រកាន់របស់អាជ្ញាធរវៀតណាមថាប្រទេសចិនជាអ្នក«បង្ក»ជម្លោះ គឺជាការមួលបង្កាច់ទាំងស្រុង ។

អាជ្ញាធរវៀតណាមមិនត្រឹមតែបានបង្កជម្លោះប្រដាប់អាវុធនៅតាមព្រំដែនកម្ពុជាទេ ប៉ុន្តែថែមទាំងធ្វើយុទ្ធនាការវិទ្ធង្សនាប្រឆាំងនឹងកម្ពុជាថែមទៀត ។ នេះគឺជាការប៉ុនប៉ងរួមមួយក្នុងការផ្តួលរំលំរបបបដិវត្តន៍កម្ពុជាពីខាងក្នុងនិងពីខាងក្រៅ ។ តាមរយៈយុទ្ធជនកម្ពុជាម្នាក់ដែលត្រូវបានចាប់ខ្លួន អាជ្ញាធរវៀតណាមបានគាំទ្រជាចំហនៅក្នុងសារពត៌មាននិងវិទ្យុផ្សាយសំឡេងក្នុង«ការកសាងមូលដ្ឋាន» នៅក្នុងប្រទេសកម្ពុជានិងអំពាវនាវឲ្យផ្តួលរំលំរដ្ឋាភិបាលស្របច្បាប់របស់កម្ពុជា» ។ ការរំលោភលើគោលការណ៍ទំនាក់ទំនងអន្តរជាតិ និងការឈ្លានពានដោយឥតលាក់លៀមមកលើប្រទេសជិតខាងបែបនេះ បានលាតត្រដាងឲ្យឃើញនូវមហិច្ឆតាផ្តេសផ្តាសក្នុងការកាន់កាប់ទឹកដីកម្ពុជា ។

ក្រោយពីផែនការឈ្លានពាននិងបំផ្លាញកម្ពុជាត្រូវបរាជ័យជាបន្តបន្ទាប់មក ឥឡូវនេះអាជ្ញាធរវៀតណាមបានធ្វើការរិះគន់ចំពោះប្រទេសចិនម្តង ។ អាជ្ញាធរវៀតណាមមួលបង្កាច់ចិនដោយចោទថាជាអ្នក«បង្ក»ជម្លោះព្រំដែន ប៉ុន្តែវៀតណាមមិនមានអ្វីមកសំអាងឡើយ ។ ដូច្នេះអាជ្ញាធរវៀតណាមធ្វើការឃោសនានិងបង្ខូចកេរ្តិ៍ឈ្មោះចិនដោយគ្មានសំចៃ ដោយនិយាយថាចិនជួយគាំទ្រកម្ពុជា ហើយថា ចិនជាអ្នកគាំទ្រកម្ពុជាទើបធ្វើ

ឲ្យខ្លួនត្រូវបរាជ័យយ៉ាងដូច្នេះ ។ ការវាយប្រហារនិងចោទប្រកាន់របស់អាជ្ញាធរវៀតណាមពិតជាគួរឲ្យចង់សើចណាស់ ។

ជាការពិតណាស់ថា ក្នុងនាមជាប្រទេសសង្គមនិយម ចិនបានចាត់ទុកការគាំទ្រនិងការជួយជ្រោមជ្រែងរបស់ខ្លួនចំពោះចលនាប្រឆាំងនឹងការឈ្លានពានថាជាភារកិច្ចអន្តរជាតិដ៏ខ្ពង់ខ្ពស់ ។ នៅពេលដែលចក្រពត្តិអាមេរិកឈ្លានពានវៀតណាមនិងកម្ពុជា ប្រទេសចិនបានធ្វើអ្វីៗគ្រប់យ៉ាងដែលអាចធ្វើទៅបានដើម្បីជួយជ្រោមជ្រែងវៀតណាមនិងកម្ពុជា ។ ជំនួយរបស់ចិនទៅឲ្យវៀតណាមមានច្រើនជាងជំនួយមកឲ្យកម្ពុជារាប់ដងឯណោះ ។ ឥឡូវនេះជំនួយរបស់ចិនបែរមកឲ្យកម្ពុជាដែលជាអ្នករងគ្រោះពីការឈ្លានពានរបស់វៀតណាមវិញ ។

វាមិនទំនងសោះ ការដែលអាជ្ញាធរវៀតណាមព្យាយាមប្រើជំនួយរបស់ចិនមកឲ្យកម្ពុជាធ្វើជាភស្តុតាងបង្ហាញថាចិនបាន«បង្ក»ជម្លោះព្រំដែនវៀតណាម-កម្ពុជានោះ ។ វាជាការមិនសមហេតុផលក្នុងការនិយាយថា ប្រទេសមួយកំពុងតែធ្វើតាមបញ្ជារបស់ចិនដោយសារប្រទេសនេះកំពុងតែទទួលការគាំទ្រនិងជំនួយរបស់ចិន ។ប្រទេសចិនកំពុងតែគាំទ្រនិងផ្តល់ជំនួយដល់ប្រទេសតតិយលោកជាច្រើន ។ ប៉ុន្តែតើប្រទេសណាមួយកំពុងតែធ្វើតាមបញ្ជារបស់ចិន? តើប្រទេសចិនមានបានដាក់បញ្ជាដល់ប្រទេសណាមួយទេ? ក្នុងការផ្តល់ជំនួយទៅឲ្យប្រទេសដទៃ ចិនមិនស្វែងរកផលប្រយោជន៍ផ្ទាល់ខ្លួននិងការគ្រប់គ្រងលើប្រទេសទាំងនោះឡើយ ។ ប៉ុន្តែផ្ទុយមកវិញចិនធ្វើយ៉ាងដូច្នេះគឺដើម្បីជួយឲ្យប្រទេសអ្នកទទួលជំនួយរក្សាបាននិងពង្រឹងឯករាជ្យភាពនិងអភិវឌ្ឍសេដ្ឋកិច្ចជាតិខ្លួនដោយខ្លួនឯងនិងបម្រើឲ្យបុព្វហេតុប្រទេសតតិយលោកក្នុងការវាយប្រឆាំងនឹងចក្រពត្តិនិយមអាណានិគមនិយម និងអនុត្តរភាពនិយម ។ ប្រទេសចិនបានផ្តល់ជំនួយដល់ប្រទេសវៀតណាមនៅក្នុងអំឡុងពេលមានសង្គ្រាមវាយជាមួយពួកចក្រពត្តិអាមេរិក ពីព្រោះប្រជាជនវៀតណាមសកម្មប្រយុទ្ធនៅក្នុងចលនាតស៊ូប្រកបដោយយុត្តិធម៌ប្រឆាំងនឹងការឈ្លានពាន និងដោយសារប្រជាជនចិនចាត់ទុកថា នេះជាភារកិច្ចរបស់ខ្លួនក្នុងនាមជាអ្នកអន្តរជាតិអធននិយមដែលត្រូវតែផ្តល់ជំនួយយ៉ាងដូច្នេះ ។ នេះគឺជាមូលហេតុដែលនាំឲ្យចិនបន្តយកផលប្រយោជន៍ទូទៅមកគិតពិចារណាប្រកាន់យកនូវឥរិយាបថមិនគីងគែងនិងអត់ឱនឲ្យគ្នា និងផ្តល់ជំនួយអស់ពីចិត្តពីថ្មើមមកឲ្យវៀតណាមនៅក្នុងពេលធ្វើសង្គ្រាមវាយប្រឆាំងនឹងអាមេរិកឈ្លានពានទឹកដី ទោះបីជានៅពេលអាជ្ញាធរវៀតណាមកំពុងតែបញ្ចេះកំហឹងចំពោះយុទ្ធនាការឃោសនារបស់ចិន ដោយខំជីកកកាយឡើងវិញនូវរឿងរ៉ាវប្រវត្តិសាស្ត្រដែលថា អ្នកដឹកនាំសក្តិភូមិចិនមួយចំនួនបានធ្វើការឈ្លានពានមកលើវៀតណាមក៏ដោយ ។ ហេតុការណ៍នេះបង្ហាញថា ចិនមិនប្រើជំនួយរបស់ខ្លួនដើម្បីបញ្ជាអ្នកណាទេ ។ តាមពិតអាជ្ញាធរវៀតណាមទេដែលជាអ្នកធ្វើឲ្យប្រជាជនកម្ពុជាអាម៉ាស់មុខ និងមួលបង្កាច់នយោបាយចិនក្នុងការផ្តល់ជំនួយដល់បរទេស ។ អាជ្ញាធរវៀតណាមចោទប្រកាន់ចិនថា ជាអ្នកប្រើជំនួយក្នុងគោលបំណងដាក់បញ្ជាមកលើកម្ពុជា និងបង្កជម្លោះព្រំដែនវៀតណាម-កម្ពុជា ។

ការឈ្លានពានរបស់វៀតណាមមកលើកម្ពុជាត្រូវបរាជ័យមិនមែនមកពីចិនជួយកម្ពុជានោះទេ ។ អាជ្ញាធរវៀតណាមហាក់ដូចជាបានបំភ្លេចចោលអស់ហើយថាកត្តាចម្បងក្នុងការសម្រេចលទ្ធផលសង្គ្រាម គឺមិនមែនអាវុធទេ ប៉ុន្តែគឺសារជាតិសង្គ្រាមខ្លួនឯងនិងការគាំទ្រពីសំណាក់ប្រជាជនទៅវិញទេ ។ តើជ័យជម្នះក្នុងសង្គ្រាមរបស់ប្រជាជនវៀតណាមប្រឆាំងនឹងការឈ្លានពានរបស់ចក្រពត្តិអាមេរិកបានមកពីណា បើគ្មានការប្តេជ្ញាចិត្តដាច់ខាតនិងជំនឿចិត្តក្នុងការវាយជាមួយអាមេរិកឈ្លានពាននោះ? ។ តើយ៉ាងម៉េចដែរនៅពេលដែលកម្លាំងវៀតណាម ដែលធ្លាប់តែវាយឈ្នះចក្រពត្តិអាមេរិកបែរជាមកចាញ់កម្លាំងប្រជាជនកម្ពុជាទៅវិញ? នេះមកពីអាជ្ញាធរវៀតណាមធ្វើសង្គ្រាមឈ្លានពានដែលមិនទទួលបាននូវការគាំទ្រ សូម្បីតែពីប្រជាជនវៀតណាមខ្លួនឯងផ្ទាល់ក៏មិនមានផង ។ សង្គ្រាមដែលធ្វើឡើងដោយវីរជនស្នេហាជាតិកម្ពុជា គឺជាសង្គ្រាមប្រឆាំងនឹងចក្រពត្តិការពារឯករាជ្យជាតិនិងបូរណភាពទឹកដី ។ យកល្អ អាជ្ញាធរវៀតណាមគួរតែរៀនសូត្រតាមរយៈបទពិសោធន៍នេះជាជាងបញ្ចេញកំហឹងវាយប្រហារមកលើចិនដែលផ្តល់ជំនួយតែបន្តិចបន្តួចមកឲ្យកម្ពុជានោះ ។

**(នៅមានត)**

# ស្វែងរកឪពុក

សូមអរគុណចំពោះការឆ្លើយតបនិងសំណូមពររបស់ខ្ញុំ ។ ឧត្តម សំណាត វ៉ាន់ថង និងខ្ញុំបន្តការទាក់ទងគ្នាជាប់ជានិច្ច ។ អ្នកទាំងអស់មានប្រពន្ធកូនហើយឥឡូវនេះ ។ ពេលវេលាកន្លងផុតទៅលឿនខ្លាំងណាស់មែនទេ? ខ្ញុំបានតាមដានការងាររបស់សម្លាញ់តាំងតែពីដំបូងមកម្ល៉េះ ប៉ុន្តែខ្ញុំមិនចង់រំខានសម្លាញ់ទេ ។

តើសម្លាញ់ និងគ្រួសារសុខសប្បាយជាទេ? ជាង១៥ឆ្នាំមកហើយ តាំងពីពេលដែលយើងបានបែកគ្នា នៅប្រទេសថៃ ។ ខ្ញុំបានជជែកលែងជាមួយ ហុង សុងតារា គាត់បានប្រាប់ខ្ញុំថាសម្លាញ់ក៏នៅប្រទេសកម្ពុជាដែរធ្វើការជាមួយអ៊ុនគាត់ ប៉ុន្តែដោយសារតែមូលហេតុផ្សេងៗទើបយើងទាំងពីរមិនដែលបានជួបគ្នា ។

ឈ្មោះពិតរបស់ឪពុកខ្ញុំគឺ ឈៀង គន្ធី ប៉ុន្តែនៅសម័យ ប៉ុល ពត គាត់បានប្តូរឈ្មោះទៅជា លឹម ឈរ វិញក្នុងគោលបំណងកុំឲ្យខ្មែរក្រហមរកគាត់ឃើញ ប៉ុន្តែនៅឆ្នាំ១៩៧៧ គាត់នៅតែត្រូវបានខ្មែរក្រហមរកឃើញដដែល ។ ឪពុករបស់ខ្ញុំមានស្រុកកំណើតនៅខេត្តតាកែវ កើតនៅក្នុងឆ្នាំ១៩២៩ ។ គាត់ធ្លាប់បានចូលបម្រើកងទ័ពអាណានិគមបារាំងនៅអំឡុងឆ្នាំ១៩៤៨ ។ ឪពុកខ្ញុំឈរជើងនៅថ្មពេជ្រ ខេត្តកំពង់ចាម រហូតដល់ពេលបារាំងដកចេញពីប្រទេសកម្ពុជា ហើយផ្តល់ឯករាជ្យឲ្យប្រទេសកម្ពុជាវិញ ។ ក្រោយមកគាត់ត្រូវផ្លាស់ទៅខេត្តកំពង់ស្ពឺ ក្រោយពីរដ្ឋប្រហារឆ្នាំ១៩៧០គាត់ផ្លាស់ទៅភ្នំពេញ ។ ក្នុងពេលនោះគាត់គឺជាវរសេនីយត្រីយ៍ក្នុងកងកាំភ្លើងធំ ។

បន្ទាប់ពីខ្មែរក្រហមចូលទីក្រុងភ្នំពេញយើងត្រូវបានជម្លៀសទៅខេត្តតាកែវ ដែលជាស្រុកកំណើតរបស់ឪពុកខ្ញុំ ។ បន្ទាប់មក ក្រុមគ្រួសាររបស់ខ្ញុំត្រូវជម្លៀសចេញធ្វើដំណើរតាមរថភ្លើងឆ្ពោះទៅកាន់ស្រុកស្វាយស៊ីសុផុន ខេត្តបាត់ដំបង ។ នៅចុងឆ្នាំ១៩៧៥ គ្រួសារខ្ញុំត្រូវបានអង្គការ«ចាត់» ឲ្យទៅភូមិបុសស្បូវ ស្រុកភ្នំស្រុក ។ ទៅដល់ទីនោះឪពុកខ្ញុំនៅតែប្រើឈ្មោះ លឹម ឈរ ដដែល ដោយសង្ឃឹមថា គ្មាននរណាម្នាក់ស្គាល់ពីប្រវត្តិរូបរបស់គាត់ឡើយ ។ ប៉ុន្តែសំណាងអាក្រក់មានមនុស្សមួយចំនួនដែលជម្លៀសមកពីស្រុកកំណើត ហើយដែលធ្លាប់រស់នៅក្នុងភូមិជាមួយគ្នាស្គាល់គាត់ ។ ដោយចង់បានគុណសម្បត្តិពីប្រធានភូមិ អ្នកទាំងនោះបានរាយការណ៍អំពីប្រវត្តិរបស់ឪពុកប្រាប់ប្រធានឈ្លបស្រុក ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ការខំប្រឹងប្រែងធ្វើការលាយជាមួយសំណាងល្អផងនោះ ឪពុករបស់ខ្ញុំត្រូវប្រធានឈ្លបទុកជីវិត រហូតដល់ខែមីនាឬ មិថុនា ឆ្នាំ១៩៧៧ ។ នៅយប់មួយប្រហែលជាម៉ោងដប់តាមដែលម្តាយខ្ញុំបានអធិប្បាយប្រាប់ថា ប្រធានក្រុមបានដើរសំដៅមកខ្ទមរបស់យើង ហើយប្រាប់ថាប្រធានភូមិឲ្យមកហៅទៅប្រជុំ ។ ម្តាយខ្ញុំក៏ដឹងភ្លាមថានេះប្រាកដជាដល់ទីបញ្ចប់ហើយ ប៉ុន្តែគាត់ពុំហ៊ានសួរឬធ្វើអ្វីទាំងអស់ ។ ចំណែកខ្ញុំនិងប្អូនស្រី នៅឯស្រែនៅឡើយ ។ ចាប់តាំងពីពេលនោះមកឪពុកខ្ញុំមិនដែលបានត្រឡប់មកផ្ទះវិញទេ ។ គ្រួសារខ្ញុំត្រូវឈ្លបហាមឲ្យលាក់ការណ៍សម្ងាត់នេះ ។ រៀងរាល់ថ្ងៃក្រុមគ្រួសាររបស់ខ្ញុំត្រូវបង្ខំឲ្យធ្វើការទ្វេមួយជាពីរដង ។

ប៉ុន្មានសប្តាហ៍ក្រោយមកអ្នកស្រុកប្រាប់ខ្ញុំថា ឃើញឪពុកខ្ញុំនៅទីរួមស្រុកភ្នំស្រុកចម្ងាយប្រហែលជា៥គីឡូម៉ែត្រពីភូមិបុសស្បូវ ។ ប៉ុន្តែក្នុងសម័យ ប៉ុល ពត មានពាក្យចចាមអារាមច្រើនណាស់ ហើយពិបាកនឹងបញ្ជាក់ការពិតទៀតផងដូចសម្លាញ់ដឹងស្រាប់ហើយថា យើងពុំអាចជជែកវែកញែកគ្នាច្រើនទេ បានតែនិយាយខ្សឹបៗតិចៗមួយមិត្តជិតដិតប៉ុណ្ណោះ ។

ខ្ញុំដឹងថាឱកាសដែលឪពុកខ្ញុំអាចមានជីវិតនោះគឺសឹងតែគ្មានទៅហើយ ។ ប៉ុន្តែខ្ញុំគ្រាន់តែចង់ទទួលបាននូវការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីបទពិសោធន៍ដ៏ឈឺចាប់នេះ ។ លើសពីនេះបន្ទាប់ពីខ្ញុំបានអានទស្សនាវដ្តីស្វែងរកការពិតរបស់សំឡាញ់លេខ៩ ចុះខែកញ្ញា ឆ្នាំ២០០០ ត្រង់អត្ថបទរណ្តៅសាកសពនៅខេត្តបន្ទាយមានជ័យ ។ ខ្ញុំយល់ថា ប្រហែលជាមានឯកសារឬភ័ស្តុតាងមួយចំនួនដែលអាចផ្តល់ជាពន្លឺចំពោះអ្វីដែលបានកើតឡើងចំពោះឪពុករបស់ខ្ញុំ ។ ជាពិសេសគឺលោក ឈុំ រួម ដែលជាចៅហ្វាយស្រុករង ហើយជាអតីតអ្នកទោសខ្មែរក្រហមម្នាក់នៅស្រុកភ្នំស្រុក ។ ក្រុមទស្សនាវដ្តីរបស់សម្លាញ់ បានសម្ភាសរួចម្តងហើយ ។ ប្រហែលគាត់អាចជួយយើងបាន បើយើងអាចជួបធ្វើការជាមួយគាត់ ។

សម្លាញ់ អរគុណច្រើនចំពោះការយកចិត្តទុកដាក់ស្រាវជ្រាវទៅលើបញ្ហានេះ ហើយបើត្រូវការអ្វីបន្ថែមសូមប្រាប់ឲ្យខ្ញុំបានដឹងផង ។ សូមទទួលការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**លីឡា**

# តាមរកបងប្រុសដែលបាត់ខ្លួន

សូមអរគុណចំពោះលិខិតរបស់សម្លាញ់ ។ ខ្ញុំបានអានលិខិតរបស់សម្លាញ់នេះដោយក្តីសោកសៅបំផុត ពីព្រោះមានមនុស្សជាច្រើនបានឆ្លងកាត់ព្រឹត្តិការណ៍មិនគួរឲ្យជឿនេះ ដែលបានកែប្រែជីវិតរបស់យើងរាល់គ្នា មិនគិតអំពីអាយុ ភេទ និងឋានៈក្នុងសង្គមសេដ្ឋកិច្ចឡើយ ។ ខ្ញុំមានការសោកស្តាយខ្លាំងណាស់ ដែលបានដឹងថាបងស្រីរបស់សម្លាញ់ម្នាក់ត្រូវពួកខ្មែរក្រហមសម្លាប់យ៉ាងព្រៃផ្សៃនិងដោយគ្មានក្តីមេត្តា ។

ខ្ញុំដឹងហើយសូមចែករំលែកនូវការឈឺចាប់និងទុក្ខសោករបស់សម្លាញ់ ដែលសម្លាញ់បានទ្រាំទ្រស៊ើរពេញមួយជីវិតទៅហើយ ។ ទស្សនៈរបស់សម្លាញ់ចំពោះបញ្ហាជីវិត អំពីប្រជាជនកម្ពុជា និងថ្នាក់ដឹកនាំរបស់កម្ពុជា នឹងមិនដូចពីមុនទៀតឡើយ ។ ខ្ញុំនិយាយបែបនេះពីព្រោះខ្ញុំមានអាយុប្រហាក់ប្រហែលសម្លាញ់ដែរ ប៉ុន្តែករណីខ្ញុំគឺខុសពីសម្លាញ់ ។ ខ្ញុំពុំអាចដឹងថាតើការរស់នៅមានសភាពបែបណាទេ ក្នុងទម្ងន់នៃរបបខ្មែរក្រហមនេះ ។ ខ្ញុំគឺប្រជាជនមួយរូបក្នុងចំណោមប្រជាជនខ្មែរមួយចំនួនទៀត ដែលបានភៀសខ្លួនមុនគេទៅកាន់ប្រទេសថៃ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ ដោយបន្សល់ទុកនូវឪពុកខ្ញុំនិងបងប្អូនចំនួន៦នាក់ទៀតនៅក្នុងស្រុកយើង ។ សព្វថ្ងៃក្នុងចំណោមអ្នកទាំង៧រូបនោះគឺនៅរស់តែម្នាក់ប៉ុណ្ណោះ ។ ប្រសិនបើខ្ញុំនៅក្នុងប្រទេសខ្ញុំប្រហែលជាខ្ញុំត្រូវស្លាប់ដែរហើយ...។ អ្វីដែលពិបាកបំផុតសម្រាប់រូបខ្ញុំនោះគឺថាតើខ្ញុំត្រូវស្វែងរកបងប្អូនរបស់ខ្ញុំដែលបានបាត់ខ្លួនតាមវិធីណា ។ កន្លងមកខ្ញុំបានទទួលដំណឹងតាមរយៈរបាយការណ៍ច្បាស់ការមួយថា ឪពុករបស់ខ្ញុំព្រមទាំងប្អូនស្រីម្នាក់និងបងប្រុសពីរនាក់បានស្លាប់បាត់បង់ជីវិតទៅហើយ ។ ប៉ុន្តែខ្ញុំនៅសល់បងប្រុសពីរនាក់ទៀត ដែលប្រហែលជានៅមានជីវិតនៅឡើយ ហើយដែលកំពុងរស់នៅក្នុងប្រទេសកម្ពុជា ។ បងប្រុសខ្ញុំប្រហែលធ្លាក់ខ្លួនពិការដោយព្រឹត្តិការណ៍ផ្សេងៗដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាកន្លងមក ទើបគ្មានលទ្ធភាពតាមរកខ្ញុំ ។ ភាពមិនច្បាស់លាស់ថាតើបងប្រុសខ្ញុំនៅរស់ឬក៏ស្លាប់នោះ ធ្វើឲ្យខ្ញុំមានអារម្មណ៍តានតឹងខ្លាំងណាស់ ។ តើសម្លាញ់មានយោបល់អ្វីខ្លះទេ អំពីកន្លែងនិងមធ្យោបាយដែលអាចធ្វើឲ្យខ្ញុំដឹងថា បងប្រុសខ្ញុំស្លាប់ឬនៅរស់? ប្រសិនបើគាត់នៅមានជីវិតរហូតមកដល់ឆ្នាំនេះ គាត់មានអាយុប្រហែល៤០ឆ្នាំហើយ ។

កន្លងមកសម្លាញ់បានបង្ហាញនូវអំពើមនុស្សធម៌ជាច្រើនសន្ធឹកសន្ធាប់និងឆន្ទៈដ៏មោះមុតរបស់សម្លាញ់ក្នុងការប្រមែប្រមូលនូវព័ត៌មានយ៉ាងច្រើនសម្រាប់ប្រជាជនកម្ពុជានិងពិភពលោកទាំងមូលដែលមិនដែលជួបប្រទះ ។

នៅទីបញ្ចប់ ខ្ញុំសូមជូនពរឲ្យសម្លាញ់និងបុគ្គលិកទាំងអស់ទទួលបាននូវជោគជ័យទៅអនាគត ។ ខ្ញុំដឹងច្បាស់ណាស់ថាមាតាបិតាទាំងអស់នៅទីនេះពិតជាមានអំណួតខ្លាំងណាស់ បើមានកូនប្រុសម្នាក់ដូចជាសម្លាញ់អីចឹង ។ សូមបន្តធ្វើការងារដ៏ប្រពៃនេះតទៅទៀត ខ្ញុំសង្ឃឹមថាយើងទាំងពីរនឹងបានជួបគ្នានៅពេលខ្ញុំទៅលេងកម្ពុជានៅថ្ងៃណាមួយ ។

សូមទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។ **នេរុ**



# សមមិត្ត ទុយ ឬក៏មិនមែន?



ទុយ

## ប្រវត្តិរូបសមមិត្ត ទុយ

◆គីម ទន ឈ្មោះបដិវត្តន៍ហៅថា ទុយ កើតឆ្នាំមមី ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៥៣ ជនជាតិខ្មែរ វណ្ណភាពៈ អនុធនសិស្សថ្នាក់ក្រោម ។

◆កើតនៅក្នុងភូមិទ្រាក្រោម ឃុំទ្រា ស្រុក៥៤ តំបន់៣៣ ភូមិភាគនិរតី ខេត្តតាកែវ ។

◆ចូលបដិវត្តន៍នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ១៩៧៣ ។

◆ចូលជាសម្ព័ន្ធយុវកក នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៥ ។

◆ឆ្នាំ១៩៦៨-៦៩ សិក្សានៅវិទ្យាល័យកោណ្ឌិន អង្គប្រីយ៍ តាកែវ ខេត្តតាកែវ ។ ពីសង្គមចាស់រៀនបានត្រឹមថ្នាក់ទី៥ ។ បានរៀនសូត្រវគ្គនយោបាយ៥ដង ។

◆មុនក្លាយយុទ្ធជនសួរចម្លើយនៅមន្ទីរស-២១ ធ្លាប់ទទួលតំណែងជាយុទ្ធជនវរៈ១០៣តំបន់(៣៣) មេពួកនៅវរៈ១១២ បន្ទាប់មកជាយុទ្ធជនមេពួក មេក្រុម និងអនុកង អនុសេនាតូចនៅក្នុងវរៈ១៨៣ (ពល៧០៣) ។

◆ឪពុកឈ្មោះ គីម ទូន វណ្ណភាពៈ កសិករកណ្តាលក្រោម ។

◆ម្តាយឈ្មោះ សំ ម៉ុត វណ្ណភាពៈ កសិករកណ្តាលក្រោម ។

◆មានបងបីនាក់ ប្រុស២ ស្រី១ៈ ឈ្មោះ គីមផុន (ប្រុស), គីមភុន (ប្រុស) និងបងស្រីឈ្មោះ គីម អោ ។




អៀម ចាន់ អ្នកទោសគុកទួលស្លែងដែលនៅមានជីវិត ក្រោយឆ្នាំ១៩៧៩ (បច្ចុប្បន្នៈ ស្លាប់ដោយជំងឺ)

ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the truth. Number 22, October 2001.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; Canadian International Development Agency (CIDA) through the Civil Society Fund; the Royal Danish Government and the Royal Netherlands Government, *The Hague*.